ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប

## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខែមេសា ឆ្នាំ២០១៦








# មាតិកា

I- សេចក្តីផ្តើម ........ 1
II- គោលនយោបាយនិងយុទ្ធសាស្រ្តសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ........ 2
III- លទ្ធផលជារួម ........ 6
IV- លទ្ធផលតាមកម្មវិធី ........ 9
១. លទ្ធផលនៃផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........ 9
២. ការបង្កើនផលិតភាពលើដំណាំកៅស៊ូ ........ 23
៣. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ........ 27
៤. លទ្ធផលនៃផ្នែកជលផល ........ 32
៥. លទ្ធផលនៃផ្នែកព្រៃឈើ ........ 35
៦. ការផ្តល់សេវាកម្មគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 39
IV- បញ្ហាប្រឈម ........ 60
V- ទិសដៅអនុវត្តឆ្នាំ២០១៦-២០១៧ ........ 61
១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........ 61
២. ផែនការផលិតកម្មដំណាំកៅស៊ូ ........ 62
៣. ផែនការផលិតកម្មសត្វនិងសុខភាពសត្វ ........ 63
៤ ផែនការផ្នែកជលផល ........ 64
៥ ផែនការផ្នែកព្រៃឈើ ........ 65
VI- សេចក្តីសន្និដ្ឋាន ........ 65

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥-២០១៦
# និងទិសដៅអនុវត្តឆ្នាំ២០១៦-២០១៧

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**" ដែលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនរួមមាន÷ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនទិន្នផលដំណាំនិងបន្សុំាការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិព្រៃឈើនិងជលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្ម និងការបង្កើនចំណូលជាតិ។

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ ផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេស ការពង្រីកកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដីដើម្បីបង្កើនជីជាតិនិងទិន្នផល ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារ។

ថ្មីៗនេះ ក្រសួងបានប្រកាសដាក់ឱ្យប្រើប្រាស់នូវឯកសារ "**គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**" ដើម្បីឱ្យកសិករនិងសហគមន៍កសិករទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។

បន្ថែមលើនេះ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី "**ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ**" បរិមាណអង្ករនាំចេញបានកើនឡើងទៅកាន់ទីផ្សារអន្តរជាតិ និងអង្ករពូជស្រូវផ្ការំដួលត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។

សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ មានការចូលរួមពីផ្នែកឯកជន ក្នុងការធ្វើវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដែលបានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរឱ្យកត់សម្គាល់។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឲ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើសនិងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ក៏ត្រូវបានឡាយព្រះហស្ថលេខាពី **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ និងត្រូវបានទីស្តីការគណៈរដ្ឋមន្ត្រីចុះហត្ថលេខាកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ អនុញ្ញាតឲ្យធ្វើការចែកផ្សាយ ដែលច្បាប់នេះជាឧបករណ៍សម្រាប់អនុវត្តឲ្យមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍផ្នែកផលិតកម្មសត្វនិងសុខភាពសត្វនៅកម្ពុជាផងដែរ។

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយ និងអាចចាប់ត្រីបានច្រើនជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទសរុបបានចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព។ ការងារនេះត្រូវបានបណ្តាប្រទេសក្នុងសហគមន៍អាស៊ានទទួលស្គាល់ និងរៀនសូត្រធ្វើជាបទពិសោធន៍ ដែលនេះគឺជាមោទនភាពមួយសម្រាប់កម្ពុជាយើង។ សព្វថ្ងៃនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងខិតខំអនុវត្តទិសស្លោក “សហគមន៍នេសាទគ្មានបទល្មើស” ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង ថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញអំពីការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា តាមរយៈការអនុវត្តអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤។ នៅពេលថ្មីៗនេះ ក្រសួងក៏សូមសម្តែងនូវការអបអរសាទរ និងគាំទ្រចំពោះសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅភាគឦសាន្តនៃប្រទេស។

## II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម

### ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ គឺជាឯកសារផែនការគោលនយោបាយនិងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវ ដែលបានកំណត់ច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម

ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាព របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ និងបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំសម្រាប់អនុវត្ត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ទៅតាមអភិក្រមក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ការកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ "*ជំរុញកំណើនកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារនិងគ្រប់គ្រងធនធានធម្មជាតិព្រៃឈើនិងជលផលប្រកបដោយចីរភាព*"។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតកម្មវិធីយុទ្ធសាស្ត្រចំនួន៥ ដូចខាងក្រោមនេះ÷

**កម្មវិធីទី ១÷ បង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម**

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន២០និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

**កម្មវិធីទី ២÷ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**

ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ ផលិតផលសត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៩។

**កម្មវិធីទី ៣÷ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

បង្កើនការការពារ និងអភិរក្សធនធានជលផល ដោយលុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង១០០សហគមន៍នេសាទ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន១៥%រៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១១។

**កម្មវិធីទី ៤÷ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព**

បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពី ព្រៃឈើ ជំរុញការដាំឈើឱ្យបាន២៥.០០០ហ.តក្នុងមួយឆ្នាំ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហ.ត ក្នុងមួយឆ្នាំ និងសហគមន៍ព្រៃឈើឱ្យបាន៣២សហគមន៍ក្នុង១ឆ្នាំ។ កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៨។

**កម្មវិធីទី ៥÷ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាល

សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១២ និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ កិច្ចការជាច្រើននឹងត្រូវអនុវត្ត និងត្រូវសម្រេចឱ្យបាននាពេលខាងមុខ។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងផ្នែកនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តនូវបណ្តាសកម្មភាពអាទិភាពទាំងឡាយ ដូចមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ។ ជាមួយគ្នានេះ បណ្តាដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមអនុវត្តការងារតាមជំនាញរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចបាននូវទិសដៅដែលបានកំណត់នេះ។ បន្ថែមលើនេះ ផែនការយុទ្ធសាស្រ្តនេះមានលក្ខណៈពហុវិស័យសង្គតភាព និងបំពេញឱ្យគ្នាជាមួយផែនការ និងគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល រួមមាន យុទ្ធសាស្រ្តចតុកោណ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យ និងគោលដៅអភិវឌ្ឍន៍សហវត្សរ៍ជាដើម។

ផ្អែកលើផែនការយុទ្ធសាស្រ្តនេះ ការរៀបចំនិងអនុវត្តតាមប្រព័ន្ធ “អភិក្រមផ្អែកតាមកម្មវិធី (Programme Based Approach)” ត្រូវបានជំរុញនិងលើកទឹកចិត្តឱ្យអនុវត្ត ដោយត្រូវបញ្ចូលគ្នានូវធនធាន ដែលមានទាំងថវិកាជាតិនិងថវិកាពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចបាននូវគោលដៅរួមគ្នា។ ជាងនេះទៀត ការកសាងផែនការយុទ្ធសាស្រ្តថវិកា និងថវិកាកម្មវិធីគឺចាំបាច់ត្រូវអនុវត្តឱ្យស្របទៅនឹងផែនការយុទ្ធសាស្រ្តនេះផងដែរ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំពុងរៀបចំកសាង “ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍កសិកម្មខេត្តឆ្នាំ២០១៦-២០២០” និងគ្រោងរៀបចំកសាង “ផែនការមេស្តីពីការអភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ២០៣០” ។

## ២. ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ **“គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥”** នៅដើមខែមិថុនា ឆ្នាំ២០១៥ កន្លងទៅនេះ ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ពង្រីកការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានេះ បានកំណត់ច្បាស់អំពីស្ថាប័ននាំមុខ និងស្ថាប័នទទួលខុសត្រូវ ព្រមទាំងបានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយ និងផែនការសកម្មភាពសំខាន់ៗពាក់ព័ន្ធផលិតកម្មកសិ-ឧស្សាហកម្ម រួមមាន (ទី១)-ការពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល និងការផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (ទី២)-បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងការអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ (ទី៣)-រៀបចំសម្រួលយន្តការដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាឡូជីស្ទិក លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម (ទី៤)-កំណត់នូវមុខងារទំនិញអាទិភាព ដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ និងរៀបចំផែនការសកម្មភាពជាក់លាក់គាំទ្រការអភិវឌ្ឍវិស័យនេះ។

ចំណុចគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងការជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយដែលបានដាក់ឱ្យអនុវត្តនេះ គឺការតម្រង់ទិសការអភិវឌ្ឍតំបន់កែច្នៃកសិផល តំបន់កែច្នៃនិងផលិតផលសង្ហារឹម តំបន់កែច្នៃផលិតសម្ភារអំពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីផលិតផលដំណាំ សត្វ និងជលផល និងការអភិវឌ្ឍសួនកសិ-ឧស្សាហកម្មសម្រាប់គោលដៅនៃការប្រមូលផ្តុំកសិផល ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុក

និងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍកសិឧស្សាហកម្មនោះគឺ ការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃកសិផល ស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិតជាមួយអ្នកប្រមូលទិញ តាមយន្តការ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ដើម្បីធានាការផ្គត់ផ្គង់កសិផលប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រមូលផ្តុំនូវសក្តានុពលក្នុងការរៀបចំផែនការសកម្មភាព ដើម្បីចូលរួមចំណែកជំរុញការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ដោយផ្តល់លើវិធានការជាយុទ្ធសាស្ត្រចំនួន៤គឺ÷ ១. វិធានការជំរុញការទាក់ទាញវិនិយោគក្នុងវិស័យកសិកម្ម ដែលពាក់ព័ន្ធនឹងការកំណត់តំបន់សក្តានុពលផលិតកម្មកសិកម្ម ការបង្កើតតំបន់កសិឧស្សាហកម្មកែច្នៃកសិផល ២. វិធានការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម សំដៅពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ៣. វិធានការពាក់ពន្ធ័នឹងការកែលម្អបរិស្ថាននិយ័តកម្ម ដែលមានការពាក់ព័ន្ធនឹងការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ និង ៤. វិធានការសម្របសម្រួលគោលនយោបាយ ដែលផ្តោតជាសំខាន់លើយន្តការសម្របសម្រួល ពិសេសយន្តការច្រកចេញចូលតែមួយ ការចរចាការតម្រូវនានា ពិសេសកិច្ចការអនាម័យនិងភូតគាមអនាម័យ ដើម្បីសម្រួលការនាំចេញ ... ។ល។

**អភិក្រមយុទ្ធសាស្ត្រ "PPPP" ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា**
**"Public Private Producer Partnership – PPPP"**




ក្រសួងនឹងយកចិត្តទុកដាក់លើវិធានការពង្រីក និងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម និងពង្រឹងសមត្ថភាពសហគមន៍កសិកម្មឱ្យមានលក្ខណៈជាអាជីព ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជន ក្នុងគ្រប់ខ្សែសង្វាក់តម្លៃកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករខ្នាតតូច ទៅនឹងទីផ្សារតាមអភិក្រម "**ភាពជាដៃគូក្នុងចំណោម រដ្ឋ–ឯកជន–ផលិតករ** (Public Private Producer Partnership - PPPP ឬ 4P)"។

បន្ថែមលើនេះទៀត ក្រសួងនឹងបន្តលើកកម្ពស់វិធានអនាម័យ និងភូតគាមអនាម័យ (SPS) ដោយយកចិត្តទុកដាក់ទៅលើយន្តការ ក្របខណ្ឌគតិយុត្ត និងបច្ចេកវិទ្យា ព្រមទាំងពង្រីកនិងពង្រឹងសមត្ថកិច្ចត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកទ្វារព្រំដែន ដើម្បីសម្រួលពាណិជ្ជកម្ម សមាហរណកម្មសេដ្ឋកិច្ច និងទទួលបានទីផ្សារផលិតផលកសិកម្មក្នុងតំបន់និងអន្តរជាតិ។

## III- លទ្ធផលជារួម

នៅក្នុងឆ្នាំ២០១៥នេះ ស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតដូចរដូវវស្សាឆ្នាំកន្លងទៅ និងបានជួបប្រទះនូវគ្រោះធម្មជាតិ ពិសេសគឺគ្រោះរាំងស្ងួត ដែលបង្កឲ្យមានផលប៉ះពាល់ដោយកង្វះទឹកពីដើមរដូវ រហូតដល់កណ្តាលរដូវ ក្នុងរាជធានី ខេត្តចំនួន១៦ ដូចជា ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្តាល ភ្នំពេញ ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង តាកែវ ឧត្តរមានជ័យ សៀមរាប ប៉ៃលិន និងក្រចេះ។ ស្ថានភាពការប្រែប្រួលមិនអំណោយផលនៃអាកាសធាតុនេះ បានបណ្តាលឲ្យរាំងស្ទះដល់ការងារបង្កបង្កើនផល និងផ្ទៃដីដាំដុះត្រូវបានធ្លាក់ចុះបន្តិចធៀបនឹងឆ្នាំកន្លងទៅ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រើប្រាស់គ្រប់មធ្យោបាយនិងបានផ្តល់សម្ភារកសិកម្ម ដើម្បីជួយអន្តរាគមន៍ក្នុងពេលជួបប្រទះនូវគ្រោះធម្មជាតិ មានដូចជា÷ ពូជស្រូវ ពូជបន្លែ ពូជសត្វ បសុឱសថ វ៉ាក់សាំង និងមធ្យោបាយអន្តរាគមន៍ផ្សេងៗទៀតដែលចាំបាច់ និងបានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ ដោយយកចិត្តទុកដាក់ណែនាំដល់ប្រជាកសិករ អនុវត្តនូវវិធានការទប់ស្កាត់ការបាត់បង់ក្រោយពេលប្រមូលផល ទាំងបរិមាណនិងគុណភាពស្រូវ។ ក្រសួងបានអនុវត្តការងារវាយតម្លៃទិន្នផល និងបរិមាណផលស្រូវបានច្បាស់លាស់តាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវរដូវប្រាំង និងជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរថ្នាក់ក្រោមជាតិ សម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង។ បន្ថែមពីនេះ ក្រសួងបានខិតខំផ្សព្វផ្សាយបច្ចេកទេសដល់កសិករ ការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ជំរុញប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ និងការប្រើប្រាស់ឧបករណ៍ព្រោះ ដើម្បីកាត់បន្ថយបរិមាណគ្រាប់ពូជ និងថ្លៃដើមផលិតកម្ម។

លើសពីនេះទៀត បញ្ហាផលិតភាពទាបនៃផលិតកម្មកសិកម្ម ពិសេសផលិតកម្មដំណាំស្រូវ ជាកង្វល់មួយដែលត្រូវប្រឹងប្រែងដោះស្រាយ ហើយបញ្ហានេះមានការពាក់ព័ន្ធដល់បញ្ហាថ្លៃស្រូវ។ ក្រសួងបានមើលឃើញពីបញ្ហានេះ និងបានខិតខំជំរុញការបង្កបង្កើនផលស្រូវរបៀបទំនើបតាមបែបស៊ីជម្រៅជាប្រពលវប្បកម្ម ដើម្បីឱ្យទទួលបានទិន្នផលខ្ពស់ និងគុណភាពល្អ ដោយប្រើប្រាស់យន្តូបនីយកម្ម និងបច្ចេកវិទ្យាថ្មីៗ ស្របតាមចរន្តសកលភាវូបនីយកម្ម។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ព្រៃឈើនិងជលផល សំដៅជំរុញលើកកម្ពស់ផលិតភាពកសិកម្ម ទាំងបរិមាណនិងគុណភាព ដោយធានាបានសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជា ការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយបានចីរភាព។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាននិងកំពុងស្រូបទាញនូវទុនវិនិយោគពីអ្នកវិនិយោគទាំងក្នុងនិងក្រៅប្រទេសកាន់តែច្រើនឡើងជាលំដាប់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ទោះជួបប្រទះនូវកត្តាអវិជ្ជមានខ្លះៗក៏ដោយ។

## ១. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល ២៨,៦% (ថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៥។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ ២៩,៧% និងវិស័យសេវាកម្មប្រហែល ៤១,៧%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពី៣៤,៦%-២៨,៦% ក្នុងចន្លោះឆ្នាំ២០១១-២០១៥ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានការកើនឡើង។




**<u>ប្រភពទិន្នន័យ</u>**÷ ក្រសួងផែនការឆ្នាំ២០១៥

នៅឆ្នាំ២០១៥នេះ ការចូលរួមចំណែកនៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុប (GDP) រួមមាន÷ ផ្នែកដំណាំ ១៥,៨% ផ្នែកផលិតកម្មសត្វ ៣% ផ្នែកជលផល ៥,៩% និងផ្នែកព្រៃឈើ ១,៨%។ ជាការកត់សម្គាល់ ផលិតកម្មដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងផលិតកម្មកសិកម្ម។ ផលិតកម្មសត្វ គឺជាមុខព្រួញសំខាន់មួយទៀត ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុកនិងនាំចេញ ដែលផ្នែកនេះត្រូវជំរុញអភិវឌ្ឍន៍ឱ្យបានខ្លាំងក្លាផងដែរ។




| | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|
| ដំណាំ | 20.6% | 20.1% | 18.7% | 17.2% | 15.8% |
| ផលិតកម្មសត្វ | 4.2% | 3.9% | 3.6% | 3.3% | 3.0% |
| ផលិតកម្មជលផល | 7.2% | 7.2% | 7.0% | 6.4% | 5.9% |
| ផលិតកម្មព្រៃឈើ | 2.6% | 2.4% | 2.3% | 2.0% | 1.8% |

**<u>ប្រភពទិន្នន័យ</u>**÷ ក្រសួងផែនការឆ្នាំ២០១៥

## ២. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

ពិនិត្យជារួមយើងសង្កេតឃើញថា នៅក្នុងវិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជា (%) របស់ផលិតកម្មដំណាំគ្រប់ប្រភេទនាឆ្នាំ២០១៥ មានចំនួនជាងពាក់កណ្ដាលពោលគឺកើនដល់៦០% នៃផលិតផលសរុបរបស់វិស័យកសិកម្ម។ ផលិតកម្មនេសាទបានចូលរួមចំណែកបន្ទាប់ពីដំណាំ គឺមានប្រមាណ២២% ផលិតកម្មសត្វបានចូលរួម១១% និងអាជីវកម្មព្រៃឈើប្រមាណ៧%។




ប្រភពទិន្នន័យ: ក្រសួងផែនការឆ្នាំ២០១៥

## ៣. ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០០៩និងឆ្នាំ២០១៤

ក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចប្រទេសកម្ពុជាកម្លាំងពលកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់គឺ÷ (ទី១)ពលកម្មក្នុងវិស័យកសិកម្ម (ទី២)ពលកម្មក្នុងវិស័យឧស្សាហកម្ម និង (ទី៣)ពលកម្មក្នុងវិស័យសេវាកម្ម។ ជាការសង្កេត ពលកម្មក្នុងវិស័យកសិកម្មបាននិងកំពុងធ្លាក់ចុះគួរឱ្យកត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០០៩ មានចំនួន៥៧,៦%នៃពលកម្មសរុប ហើយមានការថយចុះមកត្រឹមតែ៥៤,២%ឆ្នាំ២០១០។ ដោយឡែកឆ្នាំ២០១១ កម្លាំងពលកម្មក្នុងវិស័យកសិកម្មមានការកើនឡើងដល់៥៥,៨% និងបន្តថយចុះមកត្រឹមតែ៤៨,៧%នៅឆ្នាំ២០១៣។ នាឆ្នាំ២០១៤ កម្លាំងពលកម្មមានចំនួនត្រឹមតែ៤៥,៣%ប៉ុណ្ណោះ។ ចរន្តនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។ ពលកម្មក្នុងវិស័យឧស្សាហកម្មមានតែ១៥,៩%នៅឆ្នាំ២០០៩ និងកើនដល់១៦,៩%ឆ្នាំ២០១១ ១៩,៩%នៅឆ្នាំ២០១៣ និងមានការកើនបន្តដល់២៤,៣%នៅឆ្នាំ២០១៤។ ចំពោះពលកម្មក្នុងវិស័យសេវាកម្មមានចំនួន២៦,៥%ឆ្នាំ២០០៩ និងកើនដល់៣០,៤%នៅឆ្នាំ២០១៤ (ប្រភពព័ត៌មានពីក្រសួងផែនការ)។

**តារាងប្រៀបធៀបកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**

| កម្លាំងពលកម្ម | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៩ | | | | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៤ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | ភ្នំពេញ | ទីប្រជុំជន | ជនបទ | កម្ពុជា | ភ្នំពេញ | ទីប្រជុំជន | ជនបទ |
| ចំនួនពលកម្មសរុប (ពាន់នាក់) | ៧.៤៦៩ | ៦៨៦ | ៧៣៥ | ៦.០៤៨ | ៨.២៣៥ | ១.០៥៩ | ៩៥៧ | ៦.២២០ |
| កសិកម្ម (%) | ៥៧,៦ | ១,៩ | ២៤,០ | ៦៨,០ | ៤៥,៣ | ២,៥ | ១៧,០ | ៥៦,៩ |
| ឧស្សាហកម្ម (%) | ១៥,៩ | ២១,២ | ១៧,៨ | ១៥,០ | ២៤,៣ | ២៨,២ | ២៥,៤ | ២៣,៥ |
| សេវាកម្ម (%) | ២៦,៥ | ៧៦,៩ | ៥៨,៣ | ១៧,០ | ៣០,៤ | ៦៩,៣ | ៥៧,៦ | ១៩,៦ |
| ផ្សេងៗ | - | - | - | - | 0,១ | - | 0,១ | 0,១ |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## IV- លទ្ធផលតាមកម្មវិធី

ជាក់ស្តែងក្នុងឆ្នាំទី២នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចសមិទ្ធផលតាមកម្មវិធី ដូចតទៅ÷

### ១. លទ្ធផលនៃផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

#### ក. ផលិតកម្មដំណាំស្រូវ

នៅក្នុងឆ្នាំ២០១៥នេះ ស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានភ្លៀងធ្លាក់ច្រើននៅចុងរដូវវស្សា។ ជាមួយគ្នានេះដែរ កសិករបានជួបប្រទះនូវគ្រោះធម្មជាតិ (រាំងស្ងួតដើមរដូវនិងទឹកជំនន់ពាក់កណ្តាលរដូវ) ដែលជះឥទ្ធិពលអវិជ្ជមានដល់ការងារបង្កបង្កើនផល។ ស្ថានភាពនៃអាកាសធាតុបែបនេះ បានបណ្តាលឱ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំស្រូវរដូវវស្សាមួយចំនួន។

ជាលទ្ធផលជាក់ស្តែង ផលិតកម្មដំណាំស្រូវក្នុងឆ្នាំ២០១៥-២០១៦ អនុវត្តបានលើផ្ទៃដីចំនួន៣.០៥១.៤១២ហ.ត។ ផ្ទៃដីអាចប្រមូលផលបានមានចំនួនប្រមាណ៣.០២៥.៦៣០ហ.តនិងបរិមាណផលសរុបទទួលបានចំនួន៩.៣៣៥.២៨៤តោន។ ទិន្នផលមធ្យមប្រចាំឆ្នាំ២០១៥ ទទួលបានមានចំនួន៣,០៨៥តោន/ហ.ត។ អតិរេកស្បៀងគិតជាអង្ករមានចំនួនប្រមាណ ២.៩៧៥.៨០៩តោន ឬស្មើនឹង ៤.៦៤៩.៧០២តោនស្រូវ។

រីឯលទ្ធផលនៃការងារបង្កបង្កើនផលស្រូវវស្សានិងប្រាំងសម្រាប់ឆ្នាំ២០១៥-២០១៦មានលម្អិតដូចខាងក្រោម÷

- **ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥**

ជាមួយនឹងមូលបញ្ហាទាំងឡាយដូចបានរៀបរាប់ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំជំរុញលើការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៥ ដោយទទួលបានលទ្ធផលដូចខាងក្រោម÷

- ○ ផ្ទៃដីភ្ជួររាស់សរុបចំនួន៣.០៧៥.៣៤១ហ.ត (ក្នុងនោះភ្ជួររាស់ដោយគោក្របីចំនួន៥៤៩.២១៩ហ.ត ស្មើនឹង ១៧,៨៦% និងគ្រឿងយន្តចំនួន២.៥២៦.១២២ហ.ត ស្មើនឹង៨២,១៤%) លើសឆ្នាំមុនចំនួន៩៥.២២៤ហ.ត
- ○ ផ្ទៃដីសាបសរុបចំនួន៧០.១២១ហ.ត តិចជាងឆ្នាំមុនចំនួន៤៣.២៤១ហ.ត
- ○ ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៥៦១.៩៥៧ហ.ត ស្មើនឹង៩៩,៨០% នៃផែនការ២.៥៦៧.១៣០ហ.ត តិចឆ្នាំមុនចំនួន២.៦១៥ហ.ត រួមមាន÷
  - ស្រូវស្រាលចំនួន៥៨៥.៣៤៥ហ.ត(ក្នុងនោះស្រូវបង្កើនរដូវចំនួន១៦០.៦៩០ហ.ត) តិចជាងឆ្នាំមុន៧៥.៧៦១ហ.ត
  - ស្រូវកណ្តាលចំនួន១.៣១២.៨៤៣ហ.ត លើសឆ្នាំមុន៥៦.៥៨៤ហ.ត
  - ស្រូវធ្ងន់ចំនួន៥៨០.២២៧ហ.ត លើសឆ្នាំមុន២៩.៦៤៧ហ.ត
  - ស្រូវចម្ការចំនួន៣៦.៧៨៣ហ.ត តិចជាងឆ្នាំមុន៧.៣០៥ហ.ត
  - ស្រូវឡើងទឹកចំនួន៤៦.៧៥៩ហ.ត តិចជាងឆ្នាំមុនចំនួន៥.៧៨០៣ហ.ត។
- ○ ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីសរុបចំនួន២.៥៣៦.១៧៥ហ.ត តិចជាងឆ្នាំមុនចំនួន១.៨០១ហ.ត ដោយទទួលបានបរិមាណផលប្រមាណ៧.១៧០.៦៨៤តោន លើសឆ្នាំមុនចំនួន២៧.១៦៣តោន។ ទិន្នផលជាមធ្យម **២,៨២៧តោន/ហ.ត** (ឆ្នាំមុនទិន្នផលមធ្យម២,៨១៥តោន/ហ.ត)។

- **ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦**
  - – ផ្ទៃដីអនុវត្តបានមានចំនួន៤៨៩.៤៥៥ហ.ត តិចជាងឆ្នាំមុន១.៤៨០ហ.ត
  - – ផ្ទៃដីប្រមូលផលសម្រេចបានចំនួន៤៨៩.៤៥៥ហ.ត តិចជាងឆ្នាំមុន១.៤០៥ហ.ត
  - – បរិមាណផលទទួលបានចំនួន២.១៦៤.៦00តោន តិចជាងឆ្នាំមុន១៦.២៩៦តោន
  - – ទិន្នផលទទួលបានប្រមាណ៤,៤២២តោន/ហ.ត (ឆ្នាំមុនទទួលបាន៤,៤៤៣តោន/ហ.ត)។

ក្រាហ្វិកបង្ហាញអំពីផ្ទៃដីដាំដុះដំណាំស្រូវឆ្នាំ២០១១-២០១៥




ក្រាហ្វិកបង្ហាញអំពីផ្ទៃដីប្រមូលផលដំណាំស្រូវឆ្នាំ២០១១-២០១៥




- ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ (ស្រូវរដូវវស្សា)
  - ផ្ទៃដីប៉ះពាល់ដោយគ្រោះធម្មជាតិ÷ ប៉ះពាល់លើផ្ទៃដីសរុបចំនួន២៥៣.០២៩ហ.ត ក្នុងនោះរាំងស្ងួតចំនួន ២៥២.១៨៩ហ.ត សត្វល្អិតចំនួន៨៤០ហ.ត។
  - ផ្ទៃដីខូចខាតដោយគ្រោះធម្មជាតិ÷ ខូចខាតលើផ្ទៃដីសរុបចំនួន២៥.៧៨២ហ.ត ដោយរាំងស្ងួត។

**តារាងផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ២០១១-២០១៥**

| បរិយាយ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ប្រៀបធៀបកើន/ថយ ២០១៥/២០១៤ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត) | 2,968,529 | 3,007,545 | 3,052,420 | 3,055,507 | 3,051,412 | **-0.13%** |
| ផ្ទៃដីប្រមូលផល (ហ.ត) | 2,766,617 | 2,980,297 | 2,968,967 | 3,028,836 | 3,025,630 | **-0.11%** |
| ទិន្នផល (តោន/ហ.ត) | 3.173 | 3.117 | 3.163 | 3.079 | 3.085 | **0.22%** |
| បរិមាណផល (តោន) | 8,779,365 | 9,290,940 | 9,389,961 | 9,324,416 | 9,335,284 | **0.12%** |
| **បរិមាណអង្ករសល់** | 2,780,328 | 3,031,017 | 3,090,452 | 3,013,783 | 2,975,809 | **-1.26%** |
| **គិតជាស្រូវសល់** | 4,344,263 | 4,735,964 | 4,828,832 | 4,709,036 | 4,649,702 | **-1.26%** |

ក្រាហ្វិកបង្ហាញអំពីបរិមាណផលដំណាំស្រូវឆ្នាំ២០១១-២០១៥



ក្នុងរយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ ការងារបង្កបង្កើនផលស្រូវមានការកើនឡើងជាលំដាប់ទាំងផ្ទៃដី និងបរិមាណផល គឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចម្ការ ការកែលម្អបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានទិន្នផលខ្ពស់។ ដោយឡែកក្នុងឆ្នាំ២០១៥ ទោះបីជាផ្ទៃដីដាំដុះមានការថយចុះចំនួន០,១៣% និងផ្ទៃដីប្រមូលផលថយចុះចំនួន០,១១%ក៏ដោយ បរិមាណផលស្រូវសរុបមានការកើនឡើងប្រមាណ០,១២% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៤ ដោយសារទិន្នផលមានការកើនឡើង០,២២%។

## ខ. ពិពិធកម្មដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន៩៣១.៥៨១ហ.ត តិចជាងឆ្នាំមុនចំនួន២២.០១៦ហត និងទទួលបានបរិមាណផលសរុបចំនួន១៥.០៦៥.១៨៦តោន លើសឆ្នាំមុនចំនួន៣៣៧.៩២៣តោន ក្នុងនោះ÷

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន៧៩៦.៥០០ហ.ត (រដូវវស្សា៦៩២.០៣២ហ.ត និងរដូវប្រាំង១០៤.៤៦៨ហ.ត) និងមានបរិមាណផលចំនួន១៤.២០៧.៩២៨តោន
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១៣៥.០៨១ហ.ត(រដូវវស្សា១២០.២៤៩ហ.តនិងប្រាំង១៤.៨៣២ហ.ត) ទទួលបានបរិមាណផលសរុបចំនួន៨៥៧.២៥៨តោន។

ជាការកត់សម្គាល់ឃើញថា ផ្ទៃដីផលិតកម្មនិងផលិតភាពមានការកើនឡើងព្រមគ្នា ដែលនេះឆ្លុះបញ្ចាំងអំពីការវិវត្តជាវិជ្ជមាន នៅក្នុងប្រព័ន្ធផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម តាមរយៈការធ្វើប្រពលវប្បកម្ម ដោយប្រើប្រាស់បច្ចេកទេសសមស្រប និងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មត្រូវបានពង្រីក។

## ១.២. ការផលិតនិងផ្សព្វផ្សាយពូជដំណាំ

ពូជជាកត្តាគន្លឹះមួយដ៏សំខាន់ក្នុងការកំណត់គុណភាព និងផលិតភាពផលិតកម្មដំណាំ។ បណ្តាវិធានការពាក់ព័ន្ធការងារស្រាវជ្រាវនិងផលិតពូជដំណាំដែលមានគុណភាពល្អ ត្រូវបានជំរុញយ៉ាងសកម្មដើម្បីអភិវឌ្ឍន៍ផ្នែកនេះ សំដៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ឱ្យបានកាន់តែទូលំទូលាយ និងស្របតាមលក្ខខណ្ឌភៅក្យេត្រ-បរិស្ថាននៃតំបន់ដាំដុះនីមួយៗ។ គួរឱ្យកត់សម្គាល់ផងដែរថា បច្ចុប្បន្ននេះ ទាំងផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ ក៏ដូចជាសហគមន៍កសិករ បាននិងកំពុងចូលរួមយ៉ាងសកម្មជាមួយអង្គភាពជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការលើកកម្ពស់ការងារនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ បានចូលរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបទ និងទម្លាប់ក្នុងចំណោមប្រជាកសិករស្តីពីការប្រើប្រាស់ពូជនៅក្នុងផលិតកម្មគួរឱ្យកត់សម្គាល់។ ជាក់ស្តែងតាមករណីសិក្សាលើដំណាំស្រូវ ការប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ អាចជួយបង្កើនទិន្នផលបានប្រមាណពី១៥%ទៅ២០% ហើយជាទូទៅ ស្រូវដែលមានភាពសុទ្ធខ្ពស់ទទួលបានតម្លៃខ្ពស់។ តាមការអនុវត្តគម្រោងប្រើប្រាស់ថវិកាតាមកម្មវិធី គម្រោងប្រព័ន្ធស្បៀងបម្រុងកម្ពុជា និងដោយមានកិច្ចសហការអនុវត្តគម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានា គ្រាប់ពូជដំណាំមានគុណភាព ត្រូវបានផលិតនិងបានផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ចំនួន២.៨៣៨,១៥តោន ក្នុងនោះគ្រាប់ពូជស្រូវផលិតបានចំនួន២.៨៦០,០២តោន គ្រាប់ពូជដំណាំរួមផ្សំផលិតបានចំនួន៣៦,៥១តោន និងពូជដំណាំឧស្សាហកម្មផលិតបានចំនួន៧,១១តោន (សណ្តែកបាយ សណ្តែកសៀង ពោត)។

**តារាងផលិតកម្មនិងការផ្សព្វផ្សាយគ្រាប់ពូជដំណាំឆ្នាំ២០១៥**

| គ្រាប់ពូជដំណាំ | ចំណាត់ថ្នាក់គ្រាប់ពូជ | បរិមាណ (តោន) | ផ្សេងៗ |
|---|---|---|---|
| ដំណាំស្រូវ | គ្រាប់ពូជស្រូវសុទ្ធអនុញ្ញាត (certified seeds) | ១៤៨,០២ | ថវិកាកម្មវិធី៤៧តោន គម្រោង TSSD ៣៦,៤តោន គម្រោង RIAPIP ៥០,៩តោន និងគម្រោង Rice SDP ១៣,៧២តោន |
| | គ្រាប់ពូជស្រូវសុទ្ធល្អ (Good Seed) | ២.៦៤៦,៥១ | ប្រព័ន្ធស្បៀងបម្រុង១.៥៤២,៨តោន គម្រោង TSSD៧៤៤,៨តោន គម្រោង Rice SDP ៣៣៨,៩១តោន និងគម្រោង PADEE ២០តោន |
| ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម | | ៤៣,៦២ | ថវិកាតាមកម្មវិធី និងគម្រោងប្រព័ន្ធស្បៀងបម្រុងកម្ពុជា |

## ១.៣. ការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម

ការងារអប់រំនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្មចម្បងៗ ត្រូវបានជំរុញអនុវត្តតាមរយៈ (១)សកម្មភាពបណ្តុះបណ្តាលនៅក្នុងថ្នាក់ បណ្តុះបណ្តាលជាក់ស្តែងនៅទីវាល ឬសាលារៀនស្រែកសិករ អនុវត្តស្រែបង្ហាញ ដំណើរការទិវាស្រែ និងទស្សនៈកិច្ចសិក្សា (២)ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មតាមប្រព័ន្ធសាធារណៈ (៣)ការបោះពុម្ពនិងចែកចាយឯកសារបច្ចេកទេសកសិកម្ម (៤)ការរៀបចំសន្និបាតកសិករប្រចាំឆ្នាំ និង(៥)បណ្តាញសង្គម។ ក្នុងឆ្នាំ២០១៥ មន្ត្រីបច្ចេកទេសថ្នាក់ក្រោមជាតិ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ក្រុមប្រឹក្សាឃុំ និងកសិករប្រមាណ**២៩.២១៤នាក់** ក្នុងនោះស្ត្រីចំនួន **១១.៦៧៣នាក់** ស្មើនឹង**៣៩,៥%** ទទួលបានចំណេះដឹងបន្ថែមអំពីបច្ចេកទេសរៀបចំដី បច្ចេកទេសដាំដុះដំណាំស្រូវ ដំណាំសាកវប្បកម្មនិងដំណាំឧស្សាហកម្ម ការការពារដំណាំ ការអនុវត្តកសិកម្មល្អ បច្ចេកវិទ្យាក្រោយប្រមូលផល ការវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ដី ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការប្រើប្រាស់ថែទាំនិងជួសជុលគ្រឿងយន្ត ឧបករណ៍និងសម្ភារកសិកម្ម ការអភិវឌ្ឍសហគមន៍ ច្បាប់សហគមន៍កសិកម្ម និងផែនការអាជីវកម្មនិងការគ្រប់គ្រងសហគមន៍កសិកម្ម។ គិតត្រឹមដំណាច់ឆ្នាំ២០១៥នេះ នៅទូទាំងប្រទេសមានកសិករសរុបចំនួន**៩.៩២៧នាក់** ទទួលបានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពឱ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយភូមិ-ឃុំ ក្នុងនោះ÷ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិចំនួន**៨.៧៩២នាក់** (ស្ត្រីចំនួន៨៤៣នាក់ ស្មើនឹង៩,៥%) និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំចំនួន**១.១៣៥នាក់** (ស្ត្រីចំនួន៤៦៩នាក់ ស្មើនឹង៤១%)។

ព្រមជាមួយនេះ ដើម្បីពង្រីកការទទួលបាននូវព័ត៌មាននិងចំណេះដឹងបច្ចេកទេសកសិកម្ម សកម្មភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្មក៏ត្រូវបានជំរុញតាមរយៈការបោះពុម្ព និងចែកចាយឯកសារបច្ចេកទេស**៥៧.៧៣២ច្បាប់** ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសារធារណៈ ដូចជាទូរទស្សន៍ និងវិទ្យុបានចំនួន៦៨ប្រធានបទ និងការផ្សព្វផ្សាយតាមបណ្តាញសង្គម (Facebook Page)។

ដោយឡែក សន្និបាតកសិករគឺជាវិធីសាស្ត្រមួយក្នុងការលើកទឹកចិត្តកសិករ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ព្រមទាំងគំនិតច្នៃប្រឌិតថ្មីៗដល់កសិករដ៏ទៃនិងអ្នកពាក់ព័ន្ធនានា។ សន្និបាតកសិករទូទាំងប្រទេស ត្រូវបានរៀបចំជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ២០១០ ហើយមកទល់ឆ្នាំ២០១៥ ជាសន្និបាតលើកទី៧ មានកសិករចូលរួមប្រកួតប្រជែងដណ្តើមជ័យលាភីសរុបចំនួន

៨៦២នាក់ (ឆ្នាំ២០១០ចំនួន១៤៩នាក់ ឆ្នាំ២០១១ចំនួន១៨៦នាក់ ឆ្នាំ២០១២ចំនួន១៣៨នាក់ ឆ្នាំ២០១៣ចំនួន១៥៣នាក់ ឆ្នាំ២០១៤ចំនួន១១៦នាក់ និងឆ្នាំ២០១៥ចំនួន១២០នាក់)។ កសិករទទួលជ័យលាភីសរុបទូទាំងប្រទេសមានចំនួន១៩៥នាក់ (ស្ត្រី២៨នាក់ស្មើនឹង១៤%) ដែលក្នុងនោះកសិករជ័យលាភីលេខ១មានចំនួន៣៩នាក់ (ស្ត្រីចំនួន៥នាក់)។ កសិករទទួលបានជ័យលាភីលេខ១ទាំង៣៩នាក់នោះមកពីរាជធានី-ខេត្តចំនួន១៩ ដែលក្នុងនោះខេត្តតាកែវទទួលបានជ័យលាភីលេខ១ច្រើនជាងគេគឺ៦នាក់ ខេត្តបាត់ដំបងមានចំនួន៥នាក់ ខេត្តកណ្តាលមានចំនួន៤នាក់ ខេត្តកំពង់ឆ្នាំងនិងខេត្តកំពង់ចាមមានចំនួន៣នាក់ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកោះកុង និងខេត្តព្រៃវែងមានចំនួន២នាក់ និងរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ ខេត្តត្បូងឃ្មុំ ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តកំពង់ស្ពឺមានចំនួន១នាក់ៗ។

## ១.៤. ការចងក្រងនិងចុះបញ្ជីសហគមន៍កសិកម្ម

ដោយមានការចូលរួមសហការពីដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ការអភិវឌ្ឍសហគមន៍កសិកម្មក៏បាននិងកំពុងទទួលបានការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមត្ថភាព ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំក្នុងភាពជាដៃគូជាមួយផ្នែកឯកជននានា ទទួលបានទាំងបច្ចេកវិទ្យាថ្មីនិងឥណទាន និងធានាស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារក្នុងស្រុកនិងក្រៅស្រុក ជាពិសេសជំរុញការអភិវឌ្ឍសហគមន៍កសិកម្មឱ្យក្លាយជាសហ-គ្រាសកសិកម្មជនបទ សំដៅលើកកម្ពស់សេដ្ឋកិច្ច-សង្គមជនបទ។ ការចងក្រងនិងចុះបញ្ជីសហគមន៍កសិកម្មបានចាប់ផ្តើមក្នុងឆ្នាំ២០០៣ ហើយមកទល់ចុងឆ្នាំ២០១៥ នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន៧៥០សហគមន៍ មានសមាជិកសរុបចំនួន៧៨.១២៦នាក់ (ស្ត្រីចំនួន៤៧.៣៩៤នាក់ ឬស្មើនឹង៦១%) ហើយមានតម្លៃភាគហ៊ុនសរុបចំនួន២២.១៨៦,១៩លានរៀល និងដើមទុនសរុបចំនួន៣៦.០៩១លានរៀល។ រាជធានី ខេត្តដែលបានចងក្រងនិងចុះបញ្ជីសហគមន៍កសិកម្មជូនប្រជាកសិករបានច្រើនជាងគេគឺ ខេត្តតាកែវមានចំនួន៨៨ និងខេត្តបាត់ដំបងមានចំនួន៧៤។ ភាគច្រើននៃខេត្តផ្សេងៗទៀតមានសហគមន៍កសិកម្មចន្លោះពី១០ដល់៤៥ ហើយបណ្តាខេត្តដែលមានសហគមន៍កសិកម្មតិចជាងគេគឺ ខេត្តកែប មណ្ឌលគីរី ស្ទឹងត្រែង កោះកុង ព្រះសីហនុ ត្បូងឃ្មុំ និងរាជធានីភ្នំពេញ។

**ក្រាហ្វិកបង្ហាញអំពីកំណើនសហគមន៍កសិកម្មទូទាំងប្រទេសពីឆ្នាំ២០០៣-២០១៥**



ក្រាហ្វិកបង្ហាញអំពីចំនួនសហគមន៍កសិកម្មបានបង្កើតក្នុងនីមួយៗ




ក្រាហ្វិកបង្ហាញអំពីសហគមន៍កសិកម្មតាមបណ្ដារាជធានី ខេត្តនីមួយៗឆ្នាំ២០១៥




## ១.៥. ការចារគ្រឿងយន្តកសិកម្ម

បច្ចុប្បន្នការប្រើប្រាស់គ្រឿងយន្តនិងឧបករណ៍កសិកម្មកំពុងមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា។ ជាក់ស្តែងក្នុងឆ្នាំ២០១៥-២០១៦នេះ ផ្ទៃដីភ្ជួររាស់សម្រេចបានសរុបប្រមាណ៣,៥២លានហិកតា ក្នុងនោះ ភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មសម្រេចបាន២,៩៧លានហិកតា ស្មើនឹង៨៤%។

ក្រាហ្វិកបង្ហាញអំពីការប្រៀបធៀបស្ថិតិផ្ទៃដីភ្ជួររាស់ឆ្នាំ២០១២-២០១៥



ជាការកត់សម្គាល់ ការប្រើប្រាស់គ្រឿងយន្តនិងឧបករណ៍កសិកម្ម មានការកើនឡើងបើធៀបនឹងឆ្នាំ២០១៤ ក្នុងនោះមាន ម៉ាស៊ីនបូមទឹក ម៉ាស៊ីនច្រូតស្រូវ ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវ ក៏មាននិន្នាការកើនឡើងផងដែរ។ ទាំងអស់នេះបញ្ជាក់ថា ខ្សែសង្វាក់ផលិតកម្មនិងកែច្នៃផលិតផលកសិកម្មកំពុងត្រូវបានធ្វើទំនើបភាវូបនីយកម្មជាបណ្តើរៗ ដែលជាកត្តាគន្លឹះមួយចូលរួមដោះស្រាយបញ្ហាកង្វះខាតកម្លាំងពលកម្មនៅទីជនបទ ដែលកម្លាំងពលកម្មមួយចំនួនធំត្រូវបានស្រូបយកដោយវិស័យឧស្សាហកម្មនិងសេវាកម្ម និងលើកកម្ពស់ផលិតភាពនិងគុណភាពផលិតផលកសិកម្ម។

**ក្រាហ្វិកបង្ហាញអំពី ការប្រៀបធៀបគ្រឿងយន្តកសិកម្មពីឆ្នាំ ២០១២-២០១៥**




## ១.៦. ការនាំចេញផលិតផលកសិកម្ម

ក្នុងឆ្នាំ២០១៥ ការជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារតំបន់និងពិភពលោក សម្រេចបានចំនួន ៦៦មុខ (ឆ្នាំ២០១៤មានតែ៤៧មុខ) មានបរិមាណសរុប**៤.១៥៧.២៥២,៧២តោន** ដែលមានកំណើន**២០%** ធៀបនឹងលទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៤។

**ក្រាហ្វិកបង្ហាញអំពីស្ថានភាពនៃការនាំចេញផលិតផលកសិកម្មពីឆ្នាំ២០១០-២០១៥**




ការនាំចេញអង្ករសម្រេចបានចំនួន៥៣៨.៣៩៦តោន កើនឡើងចំនួន១៥១.៣៣៥តោន (ស្មើនឹង៣៩,១%) ធៀបនឹងឆ្នាំ២០១៤ ក្នុងនោះអង្ករក្រអូបគ្រប់ប្រភេទមានចំនួន២៧៤.៦៧១តោន (ស្មើនឹង៥១%) អង្ករសគ្រប់ប្រភេទមានចំនួន២២១.៨៦២តោន និងអង្ករចំហុយចំនួន៤១.៨៦៣តោន។

**ការនាំចេញតាមប្រភេទអង្ករ**




**ការនាំចេញតាមប្រភេទអង្ករក្រអូប**




អង្ករត្រូវបាននាំចេញទៅកាន់ទិសដៅចំនួន៦០ប្រទេស ក្នុងនោះសហគមន៍អឺរ៉ុប២៦ប្រទេស អាស៊ាន០៤ប្រទេស និងទិសដៅផ្សេងទៀត៣០ប្រទេស។ ប្រទេសដែលជាទីផ្សារអង្ករធំៗទាំង០៥របស់កម្ពុជារួមមាន÷ (១). ប្រទេសចិនចំនួន**១១៦. ៦៣៩តោន** (២). ប្រទេសបារាំងចំនួន**៧៥. ២៧៧តោន** (៣). ប្រទេសប៉ូឡូញចំនួន**៥៨. ៤១០តោន** (៤). ប្រទេសណែតដឺឡែនចំនួន**៥៨. ៤១០តោន** និង(៥). ប្រទេសម៉ាឡេស៊ីចំនួន**៥៤. ៩១៤តោន**។

ទំហំនៃការនាំចេញកសិផលទៅកាន់ទីផ្សារប្រទេសចិនក្នុងឆ្នាំ២០១៥ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ជាក់ស្តែងការនាំចេញផលិតផលដំឡូងមីសរុបចំនួន២១២. ៦១៣តោន (ក្នុងនោះ ចំណិតដំឡូងមីក្រៀមចំនួន១៤៩. ៤១២តោន ម្សៅដំឡូងមីចំនួន២៧. ០៣៥តោន និងកាកសំណល់ដំឡូងមីចំនួន៣៦.១៦៦តោន) គឺកើនជិតទ្វេដងបរិមាណនាំចេញសរុបក្នុងឆ្នាំ២០១៤ ដែលមានចំនួនតែ១១៩. ៥៩៧តោន។ ព្រមជាមួយគ្នានេះ ក្រុមហ៊ុនចំនួន០៥បន្ថែមទៀតក៏ត្រូវបានត្រួតពិនិត្យវាយតម្លៃ និងចុះបញ្ជីជាក្រុមហ៊ុនមានលក្ខណៈសម្បត្តិអាចនាំចេញដំឡូងមីក្រៀមរបស់កម្ពុជាទៅកាន់ប្រទេសចិន។ ដូច្នេះមកទល់ពេលនេះ មានក្រុមហ៊ុនចំនួន៦៧ ត្រូវបានពិនិត្យវាយតម្លៃនិងចុះបញ្ជីទទួលស្គាល់ជាក្រុមហ៊ុននាំចេញចំណិតដំឡូងមីក្រៀមទៅកាន់ទីផ្សារប្រទេសចិន។

ទីផ្សារផលិតផលកសិកម្មកម្ពុជានៅក្នុងប្រទេសចិននឹងត្រូវបានពង្រីកបន្ថែមទៀតក្នុងពេលខាងមុខនេះ ក្រោយពេលដែលពិធីសារចំនួន៣ទៀតត្រូវបានអនុវត្តពេញលេញរួមមាន÷ ពិធីសារស្តីពីការនាំចេញផលិតផលពោតកម្ពុជាទៅកាន់ប្រទេសចិន ពិធីសារស្តីពីនាំចេញផ្លែចេក ស្វាយ និងសណ្តែកសៀងកម្ពុជាទៅកាន់ប្រទេសចិន និងពិធីសារស្តីពីការនាំចេញអង្ករទៅប្រទេសចិន ដែលឯកសារពាក់ព័ន្ធទាំង៣នេះត្រូវបានចុះហត្ថលេខារួចហើយ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័ក នៃប្រទេសចិនកំឡុងពេលកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាននៅប្រទេសមីយ៉ានម៉ាក្នុងឆ្នាំ២០១៤។ បន្ថែមលើនេះ ក្រសួងក៏បានចុះហត្ថលេខាពិធីសារស្តីពីការនាំចេញផ្លែស្វាយទៅកាន់សាធារណរដ្ឋកូរ៉េផងដែរ។

## ១.៧. ការអភិវឌ្ឍបច្ចេកវិទ្យាដំណាំកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានអគ្គនាយកដ្ឋានកសិកម្មជាអង្គភាពជំនាញ បានពិសោធន៍ជ្រើសរើសពូជដំណាំឆ្លើយតបនឹងទីផ្សារ ដាំអភិរក្សពូជដំណាំ ថែរក្សានូវគុណភាពគ្រាប់ពូជនៃពូជដំណាំ សម្រិតសម្រាំងគ្រាប់ពូជដំណាំ បច្ចេកវិទ្យាដាំដុះ ថែទាំ និងការទុកដាក់ក្រោយពេលប្រមូលផល។ ជាក់ស្តែងការងារជាច្រើនត្រូវបានអនុវត្តនិងផ្តល់លទ្ធផលសំខាន់ៗរួមមាន÷

- **ពិសោធន៍បន្សាំលើស្រែកសិករនិងវាយតម្លៃពូជស្រូវឆ្លើយតបនឹងទីផ្សារ**÷ពិសោធន៍នេះត្រូវបានអនុវត្តនៅខេត្តតាកែវចំនួន៦ពិសោធន៍ ខេត្តកំពង់ឆ្នាំងចំនួន៥ពិសោធន៍ ខេត្តពោធិ៍សាត់ចំនួន៥ពិសោធន៍ និងខេត្តបាត់ដំបង

ចំនួន៥ពិសោធន៍ ដោយប្រើប្រាស់ពូជស្រូវចំនួន១៤ ដែលពូជស្រូវចំនួន១៣ពូជមានប្រភពពីវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) រួមមានពូជ IR 04L186, IR 09L337, IR 10L149, IR 87741-29-1-1-4, IR 87753-5-1-6-4, IR 87753-5-2-1-3, IR 87759-10-1-2-2, IR 87759-12-2-1-2, IR 87759-7-1-2-2, IR 87760-28-1-1-2, IR 87761-66-2-3-2, IR 87761-53-1-1-4, និង IR04L168 និងពូជស្រូវជលសារជាកសិណ។ តាមរយៈលទ្ធផលនៃការធ្វើពិសោធន៍បានបង្ហាញឃើញថា ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន៦ពូជគឺពូជ **Chul'sa, IR 04L186, IR 10L149, IR 09L337, IR 87741-29-1-1-4 និងពូជ IR 09A102** មានអាយុកាលខ្លី ផ្តល់ទិន្នផលខ្ពស់ មានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត និងមានទំរង់គ្រាប់អង្កររវែងនិងថ្លាល្អ។

**ការដាំអភិរក្សពូជ÷** បានដាំបន្សុទ្ធពូជពោតក្រហម២៧ពូជ ដាំសាកល្បងពូជពោតបង្កាត់២៨០ពូជ និងដាំគ្រាប់ពូជពោតសុទ្ធនៃជម្រើសវិទ្ធូរបស់ស្រឡាយពូជពោតក្រហមចំនួន២លើក។ លើសពីនេះ បានដាំអភិរក្សាពូជសណ្តែកសៀង សណ្តែកបាយ ពោតស ពោតក្រហម កប្បាស ដំឡូងមី និងដីធ្លី ចំនួន១០៧ពូជ នៅកសិដ្ឋានផលិតពូជដំណាំតំបន់ដីខ្ពស់ចំការលើ ស្ថានីយពិសោធន៍កសិកម្មបន្ទាយដែក និងស្ថានីយពិសោធន៍កសិកម្មវាលរេញ។

- **ពិសោធន៍ប្រៀបធៀបពូជដង្កូវនាងចំនួន៥ពូជ÷** គឺពូជ Gumokjam, Baeokjam, Hanseangjam, Korea yellow ជាពូជនាំចូលពីសាធារណរដ្ឋកូរ៉េក្នុងឆ្នាំ២០១៣ ២០១៤ និងឆ្នាំ២០១៥ និងពូជក្នុងស្រុក Gold silk លើទិន្នផលសរសៃសូត្រ។ លទ្ធផលបង្ហាញថាពូជ Hanseangjam ផ្តល់សរសៃសូត្រ ២៣,១៤ភាគរយ ធៀបនឹងទម្ងន់សំបុកនាង ពូជ Gumokjam ផ្តល់បរិមាណសរសៃសូត្រ ២២,៨៧ភាគរយធៀបនឹងទម្ងន់នៃសំបុកដង្កូវនាង ពូជ Baeokjam ផ្តល់បរិមាណសរសៃសូត្រ២២,៨៥ភាគរយ ធៀបនឹងទម្ងន់សំបុកនាង។ ជារួម ពូជដង្កូវនាងនាំចូលពីប្រទេសកូរ៉េទាំង៣ពូជ ផ្តល់បរិមាណសរសៃសូត្រខ្ពស់ខ្លាំងធៀបនឹងពូជក្នុងស្រុក Gold Silk និងពូជនាំចូល Korean Yellow។

**ក្រាហ្វិកបង្ហាញអំពីទិន្នផលសរសៃសូត្រតាមពូជនីមួយៗគិតជា (%)**




- **ការគ្រប់គ្រងជីជាតិដីក្នុងប្រព័ន្ធផលិតកម្មដំណាំស្រូវជាមូលដ្ឋាន**

បានសហការជាមួយទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ (IAEA) ដើម្បីសិក្សាពីការប្រើប្រាស់បច្ចេកទេសអ៊ីសូតូប 15N ដើម្បីគ្រប់គ្រង និងកែលម្អជីជាតិដីនៅក្នុងប្រព័ន្ធដាំដុះដំណាំស្រូវជាមូលដ្ឋាន។ ជាក់ស្តែងចាប់ពីឆ្នាំ២០១៤ បានធ្វើពិសោធន៍ស្រាវជ្រាវដោយប្រើប្រាស់បច្ចេកទេសអ៊ីសូតូប 15N ចំនួន៣ពិសោធន៍ រួមមាន÷ ១).ការសិក្សាការស្រូបយក

អាសូតដោយដំណាំស្រូវវស្សា និងប្រសិទ្ធភាពនៃការប្រើប្រាស់ជីអាសូត ២).ការសិក្សាកំណត់បរិមាណអាសូតដោយការចាប់យកអាសូតពីបរិយាកាសដោយដំណាំសណ្តែកបាយ (មានចំនួន០៣ពូជផ្សេងៗគ្នាដែលមានលក្ខណៈសេដ្ឋកិច្ច) និង ៣). ការសិក្សាកំណត់បរិមាណសារធាតុអាសូតដែលស្រូបពីកាកសំណល់សរីរាង្គសណ្តែកបាយ (ការពិសោធន៍ស្រាវជ្រាវនេះកំពុងដំណើរការ)។

- **សិក្សាស្រាវជ្រាវ និងពិសោធន៍ឧបករណ៍និងសម្ភារកសិកម្មមួយចំនួនបាននិងកំពុងអភិវឌ្ឍន៍ ៖**

ការសិក្សាស្រាវជ្រាវនិងសាកពិសោធន៍ចង្ក្រានដុតអង្កាម ដុតអុស និងកាកសំណល់កសិកម្មផ្សេងៗទៀត ដោយប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ (Solar) និងដោយប្រើកង្ហារ ការសិក្សានិងគូរប្លង់ឧបករណ៍គាស់ដំឡូងជ្វាបំពាក់ពីក្រោយគោយន្ត ការផលិតម៉ាស៊ីនចិញ្ច្រាំមែកឈើ ការផលិតឡដុតចំបើងចល័ត ការផលិតនិងសាកពិសោធន៍ចង្ក្រានដុតអង្កាមពីរប្រភេទនិងម៉ាស៊ីនញែកគ្រាប់អង្ករ ការផលិតនិងសាកពិសោធន៍ឡដុតអង្កាមយកខ្យល់ក្តៅសម្រាប់សំងួតស្រូវ និងការផលិត ម៉ាស៊ីនដាំស្រូវបំពាក់ជាមួយត្រាក់ទ័រ និងបំពាក់ជាមួយគោយន្ត។

### ១.៨. ការធានាបញ្ជ្រាបយេនឌ័រក្នុងផលិតកម្មកសិកម្ម

ក្នុងទិសដៅចូលរួមគាំទ្រអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម បាននិងកំពុងដំណើរការសកម្មភាព ធ្វើសមាហរណកម្មការងារយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពប្រចាំឆ្នាំតាមរយៈការបើកវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងយេនឌ័រក្នុងការងារផលិតកម្ម ដោយផ្តោតជាសំខាន់លើកសិករជាស្ត្រីតាមមូលដ្ឋាន ដើម្បីឱ្យពួកគាត់ទទួលបានចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាយេនឌ័រនិងអំពីតួនាទី និងភារកិច្ចរបស់ពួកគាត់ក្នុងដំណើរការអភិវឌ្ឍវិស័យកសិកម្ម។ ជាលទ្ធផល ទទួលបានវគ្គបណ្តុះបណ្តាលកសិករចូលរួមចំនួន១.២០០នាក់ស្តីពីយេនឌ័រក្នុងការងារផលិតកម្មកសិកម្ម។

### ១.៩. ការគ្រប់គ្រងសម្ភារៈកសិកម្ម

បច្ចុប្បន្ននេះតម្រូវការប្រើប្រាស់សម្ភារកសិកម្ម មានការកើនឡើងជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពអភិវឌ្ឍន៍ផលិតកម្មកសិកម្មនៅក្នុងប្រទេស ដែលធ្វើឱ្យបរិមាណសម្ភារកសិកម្មនាំចូល និងបរិមាណសម្ភារកសិកម្មដែលផលិតលាយផ្សំនៅក្នុងស្រុកត្រូវបានកើនឡើង។ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រមិនយកពន្ធ ឬកំណត់អត្រាពន្ធសូន្យលើការនាំចូលសម្ភារកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួតប្រជែងទីផ្សារសម្ភារកសិកម្មដោយស្មើភាព ដែលអាចឱ្យកសិករទិញសម្ភារកសិកម្មប្រកបដោយគុណភាព និងមានតម្លៃថោក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំពង្រឹងលើការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្មដែលបានចុះបញ្ជិកាត្រឹមត្រូវ ព្រមទាំងពង្រឹងការត្រួតពិនិត្យអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មនៅតាមបណ្តារាជធានី ខេត្ត ឱ្យបានសមស្របតាមនីតិវិធី។

ក្រុមហ៊ុនបានស្នើសុំលិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មក្នុងឆ្នាំ២០១៥ មានចំនួន១៧៥ក្រុមហ៊ុន រួមមាន÷

| | | |
|---|---|---|
| – ថ្នាំកសិកម្ម | : | ២៧.៨០៤,៨២៩តោន និង៧២០.៧៤០លីត្រ |
| – ជីកសិកម្ម | : | ៧៩៧.៩៤២,០៤៩តោន និង១៤.២០០លីត្រ |
| – ចំណីសត្វ-ចំណីបន្ថែម | : | ៤០៨.៣៥៩តោន |
| – វត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វ | : | ៣៨១.៥៤៣តោន |
| – បសុឱសថ | : | ២.៣៨២,៧៩៤តោន |
| – បរិក្ខាបសុពេទ្យ | : | ១៣៣មុខ |
| – គ្រាប់ពូជ | : | ៤.៦២៣,០៦០តោន។ |

ចំពោះការងារផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹង មានសកម្មភាពមួយចំនួនត្រូវបានអនុវត្តដូចជា÷

- ✓ បានរៀបចំកិច្ចប្រជុំការងារនីតិកម្មកសិកម្មប្រចាំឆ្នាំ២០១៤ ស្តីពីការរៀនសូត្របទដ្ឋានគតិយុត្តពាក់ព័ន្ធនីតិវិធីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដែលបានប្រព្រឹត្តទៅកាលពីខែកុម្ភៈ ឆ្នាំ២០១៥ ដោយមានអ្នកចូលរួមចំនួន៩២នាក់
- ✓ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារនីតិកម្មកសិកម្មប្រចាំឆមាសទី១ឆ្នាំ២០១៥ ដែលបានប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ២០១៥ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃនាយកដ្ឋាននីតិកម្មកសិកម្ម ព្រមទាំងថ្នាក់ដឹកនាំមន្ទីរកសិកម្ម និងប្រធានការិយាល័យនីតិកម្មកសិកម្មនៃមន្ទីរកសិកម្មរាជធានីខេត្ត ដែលមានសមាសភាពចូលរួមសរុបចំនួន៧៧នាក់
- ✓ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម" ដែលបានប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៥ ដោយមានអ្នកចូលរួមចំនួន១៤០នាក់
- ✓ បានបើកវគ្គបណ្តុះបណ្តាលស្តីពី "គោលការណ៍ណែនាំរបស់អាស៊ានស្តីពីបទដ្ឋានគតិយុត្តិក្នុងការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ (BCA)" ដោយសហការជាមួយអង្គការ GIZ ដែលមានសិក្ខាកាមចូលរួមចំនួន១៨នាក់
- ✓ បានធ្វើសិក្ខាសាលាផ្សព្វផ្សាយនូវច្បាប់ស្តីពី "ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម" នៅខេត្តត្បូងឃ្មុំ មណ្ឌលគិរី ព្រះសីហនុ កំពត កំពង់ស្ពឺ ព្រះវិហារ សៀមរាប កំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង រតនគិរី និងស្ទឹងត្រែង មានសិក្ខាកាមចូលរួមសរុបចំនួន៦១៦នាក់
- ✓ សហការជាមួយមន្ទីរកសិកម្មខេត្ត រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើជាគ្រូឧទ្ទេសនាមដល់អាជីវករលក់ដុំលក់រាយសម្ភារកសិកម្ម នៅខេត្តកំពង់ចាម (វគ្គទី៦) មណ្ឌលគិរី (វគ្គទី១) កណ្តាល (វគ្គទី១១) បន្ទាយមានជ័យ (វគ្គទី៦) ស្វាយរៀង (វគ្គទី៨) ដោយមានសិក្ខាកាម ចូលរួមសរុបចំនួន២៨៥នាក់។

### ១.១០. ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំកសិកម្ម

ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំកសិកម្ម គឺជាការងារចាំបាច់ក្នុងការអនុវត្តកម្មវិធីទីមួយ÷ បង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។ នាដំណាច់ឆ្នាំ២០១៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាជាអង្គភាពជំនាញបានបង្កើតពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃពូជដំណាំដែលបានបញ្ចេញ រួមទាំងផ្សព្វផ្សាយពូជទាំងនោះនិងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ ថែទាំ និងប្រមូលផល រួមទាំងចងក្រង បោះពុម្ព និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ ព្រមទាំងឯកសារបច្ចេកវិទ្យា ជូនដល់កសិករនិងអ្នកពាក់ព័ន្ធទូទាំងប្រទេស ដោយទទួលបាននូវលទ្ធផលសំខាន់ៗរួមមាន÷

– **ផលិតកម្មគ្រាប់ពូជដំណាំ÷** រាល់ពូជដំណាំដែលក្រសួងបានបញ្ចេញជូនកសិករប្រើប្រាស់ត្រូវបានធានានូវភាពសុទ្ធរបស់វា តាមរយៈការផលិតគ្រាប់ពូជសុទ្ធគ្រឹះ (Foundation seed) ផ្គត់ផ្គង់តាមការបញ្ជាទិញរបស់ក្រុមហ៊ុនឯកជន សហគមន៍កសិកម្ម និងគម្រោងអភិវឌ្ឍន៍នានាដែលអនុវត្តដោយអង្គភាពជំនាញរបស់ក្រសួង និងអង្គការផ្សេងៗ ដើម្បីផលិតនិងផ្គត់ផ្គង់បន្តជូនកសិករ។ នាឱកាសទស្សនាពិព័ណ៌របស់ក្រសួងក្នុងទិវាស្រូវ-អង្ករ រៀបចំដោយសហព័ន្ធស្រូវ-អង្ករកម្ពុជា ដែលប្រារព្ធនៅអូតែលសុខាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានបញ្ជាក់ថា ដើម្បីធានានូវភាពសុទ្ធរបស់ពូជដំណាំដែលក្រសួងបានបញ្ចេញ ក្រសួងត្រូវតែបន្តផលិតគ្រាប់ពូជសុទ្ធគ្រឹះផ្គត់ផ្គង់ជូនអតិថិជន ដើម្បីផលិតគ្រាប់ពូជចំណាត់ថ្នាក់បន្តបន្ទាប់ទៀតផ្គត់ផ្គង់ជូនកសិករដាំដុះ។ ក្នុងរដូវវស្សានិងដើមរដូវប្រាំងឆ្នាំ២០១៦នេះ ក្រសួងនឹងផ្តល់គ្រាប់ពូជស្រូវសុទ្ធគ្រឹះរបស់ពូជស្រូវមានគុណភាពល្អប្រណីតពីរពូជ គឺពូជដំណើប

ស្បៃមង្គល និងផ្ការំដួលប្រាំងដែលទើបបញ្ចេញថ្មីដល់មន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ឱ្យផលិតគ្រាប់ពូជសុទ្ធអនុញ្ញាតិ ដើម្បីយកទៅផ្សព្វផ្សាយជូនដល់កសិករនិងអ្នកពាក់ព័ន្ធ។



**សម្តេចតេជោ ហ៊ុន សែន ពិនិត្យស្រូវ–អង្ករបស់ពូជស្រូវល្អៗដែលក្រសួងបានបញ្ចេញ និងផ្តល់អនុសាសន៍ឱ្យក្រសួងត្រូវបន្តផលិតគ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជដំណាំដែលក្រសួងបានបញ្ចេញផ្គត់ផ្គង់ដល់វិស័យឯកជននិងអ្នកពាក់ព័ន្ធដើម្បីផលិតគ្រាប់ពូជចំណាត់ថ្នាក់បន្តទៀតផ្គត់ផ្គង់ជូនកសិករ ផលិតកម្មគ្រាប់ពូជរុក្ខជម្រើសវិទ្ធ គ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជស្រូវ និងដំណាំផ្សេងៗទៀត នៅវិទ្យាស្ថានស្រាវជ្រាវកាឌី**

– **ការបញ្ចេញពូជដំណាំថ្មីៗ÷** ក្រៅពីពូជស្រូវ ផ្ការំដួលប្រាំង និងខា១៤ ព្រមទាំងពូជពោតដំណើប ស៊ីអឹម១ ដែលបានបញ្ចេញនាដើមឆ្នាំ២០១៥ ក្រសួងក៏បានបញ្ចេញពូជស្រូវថ្មីមួយទៀតឈ្មោះ ខា១៥ ដែលជាពូជស្រូវស្រាលមិនប្រកាន់រដូវ មានប្រភពដើមពីអ៊ីរី (IR04N155)។ ពូជនេះជាមធ្យមមានអាយុកាល១០០ថ្ងៃ កម្ពស់១ម៉ែត្រ ប្រវែងគ្រាប់អង្ករ៧មីលីម៉ែត្រ បន្ទារគ្រាប់២,១មីលីម៉ែត្រ មានកម្រិតអាមីឡូស២១,៦% និងទិន្នផលមធ្យមទាំងរដូវប្រាំង និងវស្សា ៤តោន/ហិកតា ព្រមទាំងធន់ទ្រាំមធ្យមទៅនឹងមមាចត្នោត។ ពូជស្រូវខា១៥ អាចផ្តល់ផលរហូតដល់៧,៤តោន/ហិកតា។

– **ការអភិរក្សពូជដំណាំ÷** បានចុះកិច្ចព្រមព្រាងអភិរក្សពូជដំណាំរយៈពេលយូរនៅរដ្ឋបាលអភិវឌ្ឍន៍ជនបទកូរ៉េ និងបានយកពូជស្រូវចំនួន២១៧បញ្ជីកទៅរក្សាទុករយៈពេលយូរនៅធនាគាពន្ធុប្រទេសកូរ៉េ។ ទន្ទឹមនឹងនេះ ពូជដំណាំថ្មីៗទៀតចំនួន៣២៤សំណាកត្រូវបានប្រមូលទុក ដោយក្នុងនោះ ពូជត្រសក់ស្រូវនិងម្ទេសជិត១០០សំណាកបានដាំវាយតម្លៃ។ គិតជារួមត្រឹមដំណាច់ឆ្នាំ២០១៥នេះ ពូជដំណាំសរុបចំនួន៣៣ប្រភេទដែលរួមមានស្រូវចំនួន៦.៦៤៥បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន៣២ប្រភេទរួមមាន១.២៥៥បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន៧.៩០០បញ្ជីក/សំណាកបានអភិរក្សនៅក្នុងធនាគារពន្ធុរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) សម្រាប់ប្រើប្រាស់ក្នុងកិច្ចអភិវឌ្ឍន៍ពូជដំណាំ។




**ពិធីចុះកិច្ចព្រមព្រាងអភិរក្សពូជដំណាំរយៈពេលយូរ និងការដាក់បញ្ចូលពូជស្រូវទៅក្នុងធនាគារពន្ធុនៅរដ្ឋបាលអភិវឌ្ឍន៍ជនបទនៃសាធារណរដ្ឋកូរ៉េ ព្រមទាំងការដាំវាយតម្លៃពូជដំណាំសម្រាប់អភិរក្សនិងប្រើប្រាស់នៅវិទ្យាស្ថានកាឌី**

– **ឥទ្ធិពលនៃការដាំដុះដំឡូងមីលើគុណភាពដី÷** លទ្ធផលនៃការសិក្សានៅបីទីតាំងពិសោធន៍បានបង្ហាញថា ដំឡូងមី បានផ្តល់ទិន្នផលមើមស្រស់ជាមធ្យម២៧ត/ហត ចំពោះការមិនដាក់ជី និងពី៣១–៣៣ត/ហត ចំពោះការដាក់ជី

NPK តាមកម្រិតផ្សេងៗគ្នា។ ចំណែកកម្រិតជាតិម្សៅមានពី២៧–២៩% ដោយមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងបច្ច័យជីឡើយ។ ក្រោយពេលដាំដំឡូងមីយើងសង្កេតឃើញថា តម្លៃ pH ដីមានកំណើនប្រហែល០,២ឯកត្តា តម្លៃកាបោនសរីរាង្គ (C) មានកំណើនប្រមាណ០,២៧– ០,៦២% និងផូស្វ័រ (P) មានកំណើនប្រហែល ១,៨៦ –៤,៣៤មក្រ/គក្រ បើធៀបនឹងតម្លៃមុនពេលដាំ។ ចំពោះតម្លៃអាសូតសរុប (N) និងប៉ូតាស្យូម (K) ហាក់ដូចជាពុំមានការប្រែប្រួលគួរឱ្យកត់សម្គាល់នៅឡើយសម្រាប់ការដាំដុះដំឡូងមីក្នុងឆ្នាំទី១។



**ការចុះពិនិត្យតាមដានស្ថានភាពលូតលាស់របស់ដំណាំដំឡូងមីក្នុងពិសោធន៍លើចម្ការកសិករ និងការតម្លើងស្ថានីយអាកាសធាតុស្វ័យប្រវត្តិក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។**

– **ការបាត់បង់ក្រោយពេលប្រមូលផលរបស់បន្លែស្ពៃតឿ÷** លទ្ធផលនៃការសិក្សាបានបង្ហាញថា ស្ពៃតឿដែលកសិករដាំនៅស្រុកស្អាងនិងដឹកមកលក់ឱ្យអ្នកប្រមូលទិញក្នុងស្រុក ហើយអ្នកប្រមូលទិញក្នុងស្រុកយកមកលក់ឱ្យអ្នកប្រមូលទិញនៅផ្សារនាគមាស និងជាចុងក្រោយដឹកយកទៅលក់ដល់ទីផ្សារខេត្តសៀមរាប ត្រូវបានរលួយខូចអស់ប្រមាណ ៣០% និងស្រកទម្ងន់អស់២,៥%។

- **ឧបករណ៍ដាំបង្កប់គ្រាប់ពូជស្រូវ÷** ឧបករណ៍នេះ ត្រូវបានកែច្នៃឱ្យបានសមស្របតាមលក្ខខណ្ឌប្រទេសកម្ពុជា ហើយលទ្ធផលដែលទទួលបានពីការសាកល្បងរបស់កសិករចំនួន២៣នាក់ បានបង្ហាញថា ទិន្នផលស្រូវដាំដោយឧបករណ៍នេះជាមធ្យមមាន៣,២៥ត/ហត ដែលខ្ពស់ជាងការព្រោះដោយដៃប្រមាណ០,៤៥ត/ហត។ ក្រៅពីផ្តល់ទិន្នផលខ្ពស់ដោយសារស្រូវដុះលូតលាស់បានល្អ និងស្មើគ្នាជាជួរស្រួលដើរថែទាំ ឧបករណ៍នេះក៏ជួយកាត់បន្ថយបរិមាណគ្រាប់ពូជពី១២០–១៥០គក្រ/ហតមក៦០–៨០គក្រ/ហតផងដែរ។

**ក្រាហ្វិកបង្ហាញអំពីភាគរយផ្ទៃដីដាំដុះពូជស្រូវបញ្ចេញដោយក្រសួងក្នុងខេត្តចំនួន៨នារដូវវស្សាឆ្នាំ២០១៥**



– **ការដាំដុះពូជស្រូវដែលបញ្ចេញដោយក្រសួង÷** លទ្ធផលនៃការធ្វើអង្កេតជាមួយកសិករប្រមាណ២.០០០គ្រួសារ នៅខេត្តចំនួន៨ (តាកែវ ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងកំពង់ចាម) បានបង្ហាញថា ក្នុងរដូវវស្សាឆ្នាំ២០១៤ ផ្ទៃដីស្រែប្រមាណ៥០%បានដាំពូជស្រូវផ្ការំដួល ១០%ពូជស្រូវរាំងជ័យ ៦%ពូជស្រូវបញ្ចេញដ៏ទៃទៀត ២៩%ពូជស្រូវប្រពៃណី និង៥%ពូជស្រូវនាំចូលផ្សេងៗទៀត។ ជាសរុប ក្នុងរដូវវស្សាឆ្នាំ២០១៤ កសិករនៅខេត្តទាំង៨ បានដាំដុះពូជស្រូវដែលបញ្ចេញដោយក្រសួងប្រមាណ៦៦%នៃផ្ទៃដី។

– **ការប្រើប្រាស់គ្រឿងយន្តក្នុងដំណាំស្រូវ÷** ទន្ទឹមនឹងលទ្ធផលខាងលើនោះដែរ ក្នុងការរៀបចំដីស្រែ មានកសិករប្រមាណ១៧%នៅប្រើប្រាស់គោក្របី ៦១%ប្រើប្រាស់គោយន្ត និង២២%ប្រើប្រាស់ត្រាក់ទ័រ។ មូលហេតុសំខាន់របស់កសិករដែលនៅប្រើប្រាស់គោក្របី គឺអត់មានលទ្ធភាពទិញឬជួល (៣១%) ដីស្រែមានទំហំតូចពេក (២១%) ចង់បានដីលាមកសត្វដាក់ដំណាំ (១៣%) និងផ្សេងៗទៀត (៣៦%)។ ដោយឡែក ចំពោះការច្រូតកាត់វិញ មានកសិករដែលច្រូតកាត់ដោយដៃក្នុងស្រែប្រាំងប្រមាណ១០% ស្រែដើមរដូវវស្សាប្រមាណ១៩% និងស្រែវស្សាប្រមាណ៤២%។ កសិករដែលប្រើម៉ាស៊ីនច្រូតផ្តួលដើមក្នុងស្រែដើមរដូវវស្សាមានច្រើនជាងគេ (១៦%) ស្រែប្រាំង (១១%) និងស្រែវស្សាតិចជាងគេ (៧%)។ ម៉ាស៊ីនច្រូតកាត់ដោយកុំបៃមានការពេញនិយមខ្លាំង គឺរហូតដល់៨០% ចំពោះស្រែប្រាំង៦៤%ចំពោះស្រែដើមរដូវវស្សា និង៥១%ចំពោះស្រូវវស្សា។

**ក្រាហ្វិកបង្ហាញពី ការប្រើប្រាស់មធ្យោបាយរៀបចំដីស្រែ (%)**




**ក្រាហ្វិកបង្ហាញពីការប្រើប្រាស់មធ្យោបាយប្រមូលផលស្រូវ (%)**




– **ការបោះពុម្ពផ្សាយអត្ថបទវិទ្យាសាស្ត្រ÷** បានសរសេរនិងបោះពុម្ពអត្ថបទនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ និងសៀវភៅសន្និសីទនានាបានចំនួន៩អត្ថបទ ក្នុងនោះ ក្នុងស្រុក១អត្ថបទ និងក្រៅស្រុក៨អត្ថបទ។

– **អាហារូបត្ថម្ភរបស់អង្ករសពូជស្រូវផ្ការំដួល÷** តារាងខាងក្រោមនេះ បង្ហាញនូវលទ្ធផលនៃការវិភាគអាហារូបត្ថម្ភ (Nutrition value) បន្ថែមនៅមន្ទីរពិសោធន៍បរទេសដែលធ្លាប់វិភាគកន្លងមក បំពេញលើការខ្វះខាត។

**អាហារូបត្ថម្ភមានក្នុងអង្ករសម្រិត (WR) និងអង្ករសម្រូប (BR) របស់ពូជស្រូវផ្ការំដួល**

| No | Parameter | Unit | Phka Rumduol | | No | Parameter | Unit | Phka Rumduol | |
|---|---|---|---|---|---|---|---|---|---|
| | | | WR | BR | | | | WR | BR |
| 1 | Fe | mg/kg | 2.35 | 11.20 | 10 | Vitamin A | ppm (mg/kg) | ND | ND |
| 2 | Carbohydrate | g/100g | 79.10 | 75.90 | 11 | Vitamin B2 | ppm (mg/kg) | 0.70 | 2.67 |
| 3 | Dietary fiber | g/100g | 1.99 | 3.82 | 12 | Vitamin B3 | ppm (mg/kg) | 1.60 | 10.16 |
| 4 | Energy | kcal/100g | 356 | 366 | 13 | Vitamin B6 | ppm (mg/kg) | ND | ND |
| 5 | Protein | g/100g | 7.32 | 8.22 | 14 | Vitamin C | ppm (mg/kg) | ND | ND |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 6 | Total fat | g/100g | 1.16 | 3.29 | 15 | Vitamin D | mcg/kg | ND | 36.00 |
| 7 | Cholesterol | mg/100g | ND | ND | 16 | Vitamin E | ppm (mg/kg) | ND | 5.00 |
| 8 | Polyunsaturated fat | g/100g | 0.40 | 1.03 | 17 | Vitamin K1 | ppm (mg/kg) | ND | ND |
| 9 | Thiamine | ppm (mg/kg) | 0.81 | 2.39 | 18 | Vitamin B12 | mcg/kg | ND | ND |

ND = មិនអាចកំណត់បាន

## ២. ការបង្កើនផលិតភាពលើដំណាំកៅស៊ូ

កៅស៊ូធម្មជាតិបានដាំជាលើកដំបូងនៅកម្ពុជានាឆ្នាំ១៩១០ នៅស្រុកព្រៃនប់។ រហូតដល់ឆ្នាំ១៩២១ ទើបមានការដាំជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំដោយក្រុមហ៊ុនវិនិយោគរបស់បារាំង នៅក្នុងខេត្តកំពង់ចាមនិងក្រចេះ។ មកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីជាង៦៤.០០០ហិកតា ក្នុងនោះ ផ្ទៃដីចៀរមានជាង៣៩.០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូបានជាង៥០.០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។

នៅឆ្នាំ២០១៥នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន៣៨៨.៩៥៥ហិកតា បើធៀបទៅនឹងឆ្នាំ២០១៤មានចំនួន៣៥៧.៨០៩ហិកតា កើនឡើងចំនួន៣១.១៤៦ហិកតា ស្មើ៨,៧០%។ ផ្ទៃដីកៅស៊ូទាំងនេះ ត្រូវបានបែងចែកជា០២ផ្នែក គឺ÷ ផ្ទៃដីក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២៣៩.១០២ហិកតា ស្មើនឹង៦១,៤៧%នៃផ្ទៃដីកៅស៊ូសរុប និងកៅស៊ូគ្រួសារមានចំនួន១៤៩.៨៥៣ហិកតា ស្មើនឹង៣៨,៥៣ %នៃផ្ទៃដីកៅស៊ូសរុប។

### តារាងផលិតកម្មកៅស៊ូ២០១៤-២០១៥

| | ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០១៤ | ២០១៥ | ២០១៥/២០១៤ (∆%) |
|---|---|---|---|---|---|---|
| 1 | ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្ម | ពាន់ហ.ត | 217,5 | 239,1 | 10,0 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 140,3 | 149,9 | 6,8 |
| | | **សរុប** | **ពាន់ហ.ត** | **357,8** | **389,0** | **8,7** |
| 2 | ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្ម | ពាន់ហ.ត | 29,3 | 34,7 | 18,7 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 61,3 | 76,5 | 24,8 |
| | | **សរុប** | **ពាន់ហ.ត** | **90.6** | **111,2** | **22,8** |
| 3 | ផលិតផលកៅស៊ូ | កសិឧស្សាហកម្ម | ពាន់តោន | 34,0 | 39,3 | 15,6 |
| | | កៅស៊ូគ្រួសារ | ពាន់តោន | 63,1 | 87,6 | 38,8 |
| | | **សរុប** | **ពាន់តោន** | **97.1** | **126,9** | **30,7** |

## ក្រាហ្វិកបង្ហាញអំពី ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១១-២០១៥




ទោះបីជាថ្លៃកៅស៊ូមានការចុះយ៉ាងខ្លាំង និងមានកត្តាអវិជ្ជាមានមួយចំនួន ដែលបានជួបប្រទះកន្លងមកក៏ពិតមែន តែជារួមលទ្ធផលបានសម្រេចទៅតាមគោលដៅដែលគ្រោងទុក។ ទាំងអស់នេះ គឺកើតឡើងដោយការខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការបង្កើនលទ្ធភាព និងសមត្ថភាពក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូត្រូវតែយកចិត្តទុកដាក់ និងត្រូវជំរុញបន្ថែមទៀត ដើម្បីរួមចំណែកដោយជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

### គ. ការងារផលិតកម្មនិងនិហរ័ណកៅស៊ូ

ឆ្នាំ២០១៥នេះ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន១១១.២៣២ហ.ត. ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៤ មានចំនួន៩០.៥៤៥ហ.ត. កើនទ្បើងចំនួន២០.៦៨៧ហិកតា ស្មើនឹង២២,៨៤%។ ផលិតផលកៅស៊ូសម្រេចបានចំនួន១២៦.៨៦១តោន ធៀបនឹងឆ្នាំ២០១៤ ចំនួន៩៧.០៥៤តោន កើនទ្បើងចំនួន២៩.៨០៧តោន ស្មើនឹង៣០,៧១%។ ទិន្នផលជាមធ្យមមានចំនួន១.១៤១គ.ក្រ./ហ.ត. ធៀបនឹងឆ្នាំ២០១៤ ដែលមានចំនួន១.០៧២គ.ក្រ./ហ.ត កើនទ្បើង៦៩គ.ក្រ./ហ.ត ស្មើនឹង៦,៤៤%។

## ក្រាហ្វិកបង្ហាញអំពី ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុបឆ្នាំ២០១១-២០១៥




ការនាំចេញកៅស៊ូឆ្នាំ២០១៥ សម្រេចបានចំនួន១២៨.០៤៧តោន ស្មើនឹងទឹកប្រាក់ជាង១៥៤លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៤ ដែលការនាំចេញមានចំនួន១០០.១៥១តោន កើនទ្បើងចំនួន២៧.៨៩៦តោន ស្មើនឹង២៧,៨៥%។ ស្ថានភាពតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិបានបន្តធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០១៥ ដែលមិនធ្លាប់មានក្នុងរយៈពេល៧ឆ្នាំកន្លងមកនេះ ពិសេសតម្លៃកៅស៊ូនាំចេញកម្ពុជាជាមធ្យមនៅសល់តែ១.២០៣ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹង

ឆ្នាំ២០១៤ ដែលតម្លៃមធ្យម១.៥៣៩ដុល្លារអាមេរិកក្នុងមួយតោន ថយចុះ៣៣៦ដុល្លារអាមេរិកក្នុងមួយតោន ស្មើនឹង ២១,៨៣%។ កត្តានេះបានធ្វើឱ្យផលចំណូលសរុបថយចុះផងដែរ ទោះបរិមាណនាំចេញកើនលើសឆ្នាំ២០១៤ក៏ដោយ។

**ក្រាហ្វិកបង្ហាញអំពី ផលិតកម្ម និងបរិមាណកៅស៊ូនាំចេញ**




នៅក្នុងឆ្នាំ២០១៥នេះ រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូមានសរុបចំនួន១២០កន្លែង ក្នុងខេត្តចំនួន៩ (កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី ឧត្តរមានជ័យ និងព្រះវិហារ) គឺកើនឡើងចំនួន ២២កន្លែង ស្មើនឹង២២% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៤ ដែលមានតែ៩៨កន្លែង។ ក្នុងចំណោមរោងចក្រ សិប្បកម្មចំនួន១២០កន្លែង មានរោងចក្រកែច្នៃកៅស៊ូដុំ (TSR) ចំនួន៣៦កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed smoked sheet) និងសិប្បកម្មកែច្នៃជ័រកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (ADS: Air-dried sheet) មានចំនួន៨០កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤កន្លែង។

## ខ. ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ

នៅក្នុងឆ្នាំ២០១៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអង្គភាពជំនាញបានចុះបើកវគ្គផ្សព្វផ្សាយ បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដូចជា÷

- វគ្គបណ្តុះបណ្តាលការបើកមុខចៀរដំបូង និងបច្ចេកទេសចៀរជ័រកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារនៅខេត្តគោលដៅគឺ ខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី បានចំនួន០២វគ្គ ដោយមានកសិករចូលរួមសរុប៨៨នាក់/គម្រោងសរុប។ វគ្គបណ្តុះបណ្តាលនេះ កសិករបានទទួលចំណេះដឹងទាំងមេរៀនទ្រឹស្តី និងការអនុវត្តចៀរជ័រលើដើមកៅស៊ូជាក់ស្តែងនៅនឹងកន្លែង សំដៅធ្វើឱ្យការយកផលរបស់ពួកគាត់មានរយៈពេលយូរអង្វែងទទួលបានទិន្នផលខ្ពស់ និងត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសចៀរជ័រកៅស៊ូ។

- វគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ នៅខេត្តគោលដៅទាំង៦ គឺខេត្តបាត់ដំបង ប៉ៃលិន មណ្ឌលគិរី ក្រចេះ រតនគិរី និងស្ទឹងត្រែង ដោយមានកសិករចូលរួមសរុប៣៦៥នាក់/គម្រោងសរុប ៣៦០នាក់ (៦០នាក់/វគ្គ)។ កសិករដែលបានចូលរួមទទួលបានឯកសារមេរៀន និងស្តាប់ការធ្វើបទបង្ហាញរបស់វាគ្មិន និងឆ្លើយបំភ្លឺរាល់ចម្ងល់ និងសំណួរនានាតាមមេរៀននីមួយៗ ដើម្បីឱ្យកសិករអ្នកដាំកៅស៊ូទទួលបានចំណេះដឹងនេះ យកទៅអនុវត្តលើការជ្រើសរើសពូជ ការងារដាំដុះនិងថែទាំ ការព្យាបាលជំងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស សំដៅឱ្យទទួលបានលទ្ធផលល្អ។

- វគ្គផ្សព្វផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារចំនួន០៤លើកនៅខេត្តគោលដៅចំនួន០២ គឺកំពង់ចាមនិងត្បូងឃ្មុំ ដោយមានម្ចាស់កៅស៊ូគ្រួសារចូលរួមសរុបចំនួន ២១១នាក់/ គម្រោងសរុប២០០នាក់

- វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូបានចំនួន០៣វគ្គ ដល់មន្ត្រីកសិកម្មខេត្តគោលដៅរួមមាន ខេត្តព្រះវិហារ ស្ទឹងត្រែង និងកំពង់ធំ ដោយមានមន្ត្រីកសិកម្មខេត្តចូលរួមសរុបចំនួន៧៥នាក់/ គម្រោងសរុប៦០នាក់ (២០នាក់/ វគ្គ)។ វគ្គបណ្តុះបណ្តាលនេះ សំដៅបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីកសិកម្មខេត្ត ឲ្យក្លាយជាមន្ត្រីបង្គោលលើជំនាញកៅស៊ូ និងក្លាយជាអ្នកផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូ ជាពិសេសកសិករកៅស៊ូគ្រួសារ ដើម្បីជំរុញអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព

- វគ្គផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូចំនួន០១លើកនៅខេត្តកំពង់ចាម ដល់ម្ចាស់រោងចក្រសិប្បកម្មកែច្នៃជ័រកៅស៊ូ មកពីខេត្តគោលដៅចំនួន៧គឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ធំ និងស្ទឹងត្រែង ដោយមានម្ចាស់រោងចក្រសិប្បកម្មចូលរួមសរុបចំនួន៤១នាក់/ គម្រោងសរុប៤០នាក់

- វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រព្យាករណ៍ការផ្គត់ផ្គង់កៅស៊ូធម្មជាតិដល់មន្ត្រីរាជការ និងនិយោជិតចម្ការកៅស៊ូកសិឧស្សាហកម្មចំនួន១លើក ដោយមានអ្នកចូលរួមសរុប២៥នាក់។

- វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាកម្មវិធីដល់មន្ត្រីរាជការចំនួន២លើក ដោយមានអ្នកចូលរួមសរុប ៣០នាក់/១លើក។

## គ. ការងារពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ

ចងក្រងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារនៅខេត្តស្ទឹងត្រែង បានចំនួន០១សហគមន៍ ដោយការចងក្រងនេះមាន០៣ដំណាក់កាល មានក្រុមប្រឹក្សាភិបាលចំនួន០៧រូប និងគណៈកម្មាធិការត្រួតពិនិត្យចំនួន០៥រូប។ ការបង្កើតសហគមន៍នេះ គឺដើម្បីលើកកម្ពស់អំណាចចរចាទីផ្សាររបស់ប្រជាកសិករ កាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្ម របស់ប្រជាកសិករជាសមាជិកសហគមន៍ផលិតកសិផល ឬផ្តល់សេវាកម្មណាដែលកសិករម្នាក់ៗមិនអាចធ្វើបាន ទទួលបានព័ត៌មានទីផ្សារ និងពង្រីកឱកាសទីផ្សារកសិផលរបស់កសិករ លើកកម្ពស់គុណភាពកសិផល ឬផលិតផលរបស់កសិករ និងបង្កើនប្រាក់ចំណូលគ្រួសាររបស់កសិករជាសមាជិកសហគមន៍។

## ឃ. ការងារពិសោធស្រាវជ្រាវកៅស៊ូ

ការស្រាវជ្រាវបាននិងកំពុងអនុវត្តទៅលើកិច្ចការមួយចំនួនដូចជា÷ (១). ស្រាវជ្រាវបង្កាត់ពូជ តាមដាន បញ្ចូលទិន្នន័យគ្រប់ឡូត៍ពិសោធន៍ក្លូនទាំងនៅខាងក្នុងនិងខាងក្រៅស្ថានីយ៍ សរុបចំនួន២៦ឡូត៍ពិសោធន៍ និងបង្កើតឡូត៍ពិសោធន៍ក្លូនទ្រង់ទ្រាយធំបានចំនួនមួយឡូត៍ពិសោធន៍ នៅក្រុមហ៊ុនចម្ការកៅស៊ូទ្រីភាពបឹងទន្លេម្រេច មានក្លូនចំនួន០៨ (២). ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម បានបង្កើតនិងតាមដានទិន្នន័យពិសោធន៍ចំនួន១៤ ចម្ការពិសោធន៍ (៣). ការស្រាវជ្រាវអំពីការដាំដុះនិងការពារ ដោយតាមដាននិងប្រមូលទិន្នន័យនៃឥទ្ធិពលនៃដំណាំគម្រប ជី ដង់ស៊ីតេដាំ ប៉ារ៉ាម៉ែត្រក្សេត្របរិស្ថាន ទៅលើការលូតលាស់និងទិន្នផលដើមកៅស៊ូ (៤). តាមដាន ស្រង់ បញ្ចូល និងវិភាគទិន្នន័យសរីរវិទ្យាទឹកជ័រ។

បាននិងកំពុងអនុវត្តផ្នែកមន្ទីរពិសោធន៍យថាប្រភេទរួមមាន÷ (១). ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន ៣២៥ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រ CSR ចំនួន១៣៩ភាគសំណាក (២). ការរៀបចំធ្វើតេស្តនិងរបាយការណ៍វិភាគលទ្ធផល នៃការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកចំនួន៤លើក ដើម្បីវាយតម្លៃសមត្ថភាព

មន្ទីរពិសោធន៍មូលដ្ឋាន សម្រាប់ឈានទៅការទទួលស្គាល់ជាផ្លូវការ (៣). ធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA បានចំនួន២លើក ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ ចំពោះកៅស៊ូ TSR (៤). ការអនុវត្តនិងបំពេញតម្រូវការវិញ្ញាបនបត្រទទួលស្គាល់ស្តង់ដារអន្តរជាតិ ISO/IEC17025:2005 ស្តីពីតម្រូវការទូទៅ សម្រាប់សមត្ថភាពមន្ទីរពិសោធន៍ធ្វើតេស្តនិងព្យាសកម្ម (calibration) ឧបករណ៍របស់មន្ទីរពិសោធន៍យថាប្រភេទ (៥). ចុះត្រួតពិនិត្យនិងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋានបានចំនួន០២ដង ក្នុងគោលបំណងរក្សាសុពលភាពនៃការចុះបញ្ជិកា ការអនុញ្ញាតសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងការទទួលស្គាល់ជាផ្លូវការ មន្ទីរពិសោធន៍មូលដ្ឋានពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

## ៣. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

### ៣.១. ការងារផលិតកម្មសត្វ

#### ក. ស្ថិតិសត្វ

ការចិញ្ចឹមសត្វគ្រប់ប្រភេទ (ទាំងការចិញ្ចឹមសត្វលក្ខណៈគ្រួសារនិងជាលក្ខណៈពាណិជ្ជកម្ម) សរុបមានចំនួន ៤៥.៣០៩.៦៨៨ក្បាល មានកំណើន៥,៨៦ភាគរយ ជ្រូកមានចំនួន២.៧៧៥.៦១៤ក្បាល កើនបាន១,៤៦ភាគរយ បក្សីមានចំនួន៣៤.៥១៩.០៧២ក្បាល កើន៩,២៣ភាគរយ គោ ក្របីចំនួន៣.៤២២.៩៣៧ក្បាល ថយចុះ៤,៩៧ភាគរយ និងកម្លាំងអូសទាញមានចំនួន១.១៣២.០៩៧ក្បាល ថយចុះ៩,៤២ភាគរយ។ ស្ថិតិសត្វនេះ ជាស្ថិតិសត្វដែលសល់ពីការពិឃាតនិងការនាំចេញ។ មានការកត់សម្គាល់ថា ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានការកើនឡើង ដោយកសិដ្ឋានចិញ្ចឹមសត្វមានចំនួនរហូតដល់២.៨៥៦កន្លែង កើន២១ភាគរយ ចំណែកឯចំនួនសត្វមាន៨.១៧០.៥២៥ក្បាល កើន២៨,៩៧ភាគរយ ក្នុងនោះជ្រូកកើន១១.៤៤ភាគរយ បក្សីកើន២៩.៩៩ភាគរយ និងគោកើនចំនួន១០៦.១១ភាគរយ។

**តារាងប្រៀបធៀបស្ថិតិសត្វចិញ្ចឹមឆ្នាំ២០១៥/២០១៤**

| ប្រភេទសត្វ | ឆ្នាំ២០១៤ (ក្បាល) | ឆ្នាំ២០១៥ (ក្បាល) | កើន/ថយ (ក្បាល) | កើន/ថយ (ភាគរយ) |
|---|---|---|---|---|
| គោ | ៣.០៥៩.៩២៧ | ២.៩១៦.៧០៩ | -១៤៣.២១៨ | -៤,៦៨ |
| ក្របី | ៥៤១.៨៥៩ | ៥០៦.២២៨ | -៣៥.៦៣១ | -៦,៥៨ |
| គោ ក្របី | ៣.៦០១.៧៨៦ | ៣.៤២២.៩៣៧ | -១៧៨.៨៤៩ | -៤,៩៧ |
| កម្លាំងអូសទាញ | ១.២៤៩.៨១៧ | ១.១៣២.០៩៧ | -១១៧.៧២០ | -៩,៤២ |
| ជ្រូក | ២.៧៣៥.៧១៧ | ២.៧៧៥.៦១៤ | ៣៩.៨៩៧ | ១,៤៦ |
| បក្សី | ៣១.៥៨៣.៦៥៧ | ៣៤.៥១៩.០៧៣ | ២.៩៣៥.៤១៦ | ៩,២៩ |
| សេះ | ៩.១៦១ | ៧.៦៨៩ | -១.៤៧២ | -១៦,០៧ |
| ចៀម | ២៣៨ | ៤០៩ | ១៧១ | ៧១,៨៥ |
| ពពែ | ១៨.២៥៦ | ២៨.៨៦៨ | ១០.៦១២ | ៥៨,១៣ |
| ដំរី | ៦៣ | ៦៤ | ១ | ១,៥៩ |
| **សរុប** | **៤២.៨០០.៤៨១** | **៤៥.៣០៩.៦៨៨** | **២.៥០៩.២០៧** | **៥,៨៦** |

**តារាងស្ថិតិសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មឆ្នាំ ២០១៤-២០១៥**

| ប្រភេទសត្វ | ឆ្នាំ២០១៤ | | ឆ្នាំ២០១៥ | | ប្រៀបធៀបឆ្នាំ២០១៤-២០១៥ | | | |
|---|---|---|---|---|---|---|---|---|
| | | | | | កសិដ្ឋាន | | ចំនួនសត្វ (ក្បាល) | |
| | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | កើន/ថយ | ភាគរយ (%) | កើន/ថយ | ភាគរយ (%) |
| គោ ក្របី | ៤០ | ៦.៤៧៨ | ៨៦ | ១៣.៣៥២ | ៤៦ | ១១៥ | ១.០២៩ | ១០៦,១១ |
| ជ្រូក | ៣៨៥ | ៣៧៤.៨៩៤ | ៥០០ | ៤១៧.៧៧៥ | ១១៥ | ២៩,៨៧ | ១៦.៨៩៤ | ១១,៤៤ |
| បក្សី | ១.៩៣៤ | ៥.៩៥៣.៦៣០ | ២.២៧០ | ៧.៧៣៩.៣៩៨ | ៣៤៤ | ១៧,៣៧ | ១.៧៨៥.៧៦៨ | ២៩,៩៩ |
| **សរុប** | **២.៣៥៩** | **៦.៣៣៥.០០២** | **២.៨៥៦** | **៨.១៧០.៥២៥** | **៤៩៧** | **២១,០៧** | **១.៨៣៥,៥២៣** | **២៨,៩៧** |

## ខ. ការគ្រប់គ្រងកាកសំណល់សត្វ

ការគ្រប់គ្រងកាកសំណល់សត្វ ប្រព្រឹត្តទៅតាមរូបភាពបង្កើតឡជីវឧស្ម័នគ្រួសារ (ចំពោះការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ) និងការណែនាំឲ្យធ្វើអាងជីវឧស្ម័ន។ ការសងសង់ឡជីវស្ម័នគ្រួសារមានចំនួន២.២៩២ឡ ក្នុងនោះ ឡជីវឧស្ម័នក្រោមគម្រោងកិច្ចសហប្រតិបត្តិការកម្ពុជា-ចិនមានចំនួន២៥០ឡ។ សរុបឡជីវឧស្ម័នគ្រួសារដែលបានសាងសង់ដោយមានការទទួលខុសត្រូវពីនាយកដ្ឋានផលិតកម្មនិងបសុពេទ្យាបាល មានចំនួន២៣.៩៣៩ឡ។ ស្ថានីយ និងកសិដ្ឋានចិញ្ចឹមសត្វធំៗមានអាងជីវឧស្ម័ន មានសមត្ថភាពផលិតអគ្គិសនី ដែលមិនគ្រាន់តែប្រើប្រាស់ក្នុងកសិដ្ឋានរបស់ខ្លួនតែប៉ុណ្ណោះទេ ក៏ប៉ុន្តែបានលក់ចែកចាយដល់ប្រជាពលរដ្ឋនៅជុំវិញកសិដ្ឋានថែមទៀតផង។

## គ. ការកែលម្អពូជសត្វ

ពូជសត្វត្រូវបានយកចិត្តទុកដាក់ធ្វើការស្រាវជ្រាវ ជ្រើសរើស និងបង្កាត់ពូជ ដែលកិច្ចការនេះអនុវត្តទាំងផ្នែកសាធារណៈនិងផ្នែកឯកជន។ ផ្នែកសាធារណៈនាយកដ្ឋានផលិតកម្មនិងបសុពេទ្យាបាល មានស្ថានីយចិញ្ចឹមជ្រូកបង្ហាញចិន-កម្ពុជា បានផលិតនិងលក់ចែកចាយពូជជ្រូកជូនកសិករទូទាំងប្រទេស សម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ បន្ថែមលើសពីនេះ ស្ថានីយចិញ្ចឹមគោភ្នំតាម៉ៅកំពុងផលិតមេជីវិតគោ សម្រាប់ធ្វើការបង្កាត់ពូជដោយសិប្បនិមិត្ត។ ដើម្បីធ្វើការកែលម្អពូជ ក្រសួងបានអនុញ្ញាតឲ្យនាំចូលរូបធាតុសេនេទិកពូជសត្វដែលមានផលិតភាពខ្ពស់ ឆាប់ធំធាត់ ផ្តល់ប្រសិទ្ធភាពខ្ពស់ ជំរុញនិងលើកកម្ពស់ការបង្កាត់ពូជដោយសិប្បនិមិត្ត ជំរុញការជ្រើសរើសពូជសត្វល្អៗដែលមានក្នុងស្រុក និងការអភិរក្សពូជសត្វ ធនធានសេនេទិកក្នុងស្រុកផងដែរ។ ពូជមាន់ ទា ក៏ត្រូវបានអភិវឌ្ឍជាបណ្តើរៗ ជាពិសេសការផលិតនិងការផ្សព្វផ្សាយពូជរបស់ក្រុមហ៊ុន កសិដ្ឋានឯកជន ក៏ដូចជាការផលិតពូជដោយកសិករខ្នាតតូចនិងខ្នាតមធ្យម។

## ឃ. ការផលិតចំណីសត្វនិងការត្រួតពិនិត្យចំណីសត្វ

ផលិតកម្មចំណីសត្វត្រូវបានយកចិត្តទុកដាក់ ទាំងក្នុងកម្រិតផលិតកម្មជាលក្ខណៈគ្រួសារ និងកម្រិតពាណិជ្ជកម្ម។ កសិករចិញ្ចឹមសត្វនៅស្ទើរតែគ្រប់រាជធានី ខេត្ត ជាពិសេសខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ចាម ត្បូងឃ្មុំ និងតាកែវ ត្រូវបានផ្តល់ពូជដំណាំចំណីសត្វ ដែលរួមមានពូជឃឹងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មូឡាតូ ប៉ាសប៉ាលូម ស៊ីម្ពូង។ល។ នាយកដ្ឋានផលិតកម្មនិងបសុពេទ្យាបាល បានផ្តល់នូវបច្ចេកទេសដាំដុះ បច្ចេកទេសថែទាំនិងច្រូតកាត់។ បន្ថែមពីនេះកសិករចិញ្ចឹមសត្វទាំងនេះ បានទទួលការបណ្តុះបណ្តាលបច្ចេកទេសកែច្នៃចំណីសត្វដូចជាធ្វើផ្អកស្មៅ ផ្អកពោតផ្អកស្លឹកដំឡូងមី និងចំបើងផ្លាប់ជាមួយជីអ៊ុយរ៉េ។ ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅក៏មានតួនាទីយ៉ាងសំខាន់ក្នុងការផលិត និងផ្តល់ពូជដំណាំចំណីសត្វ និងពូជស្មៅជាច្រើនប្រភេទ សម្រាប់ចែកចាយដល់ការិយាល័យផលិតកម្មនិងបសុពេទ្យាបាលខេត្ត និងកសិករដើម្បីដាំសម្រាប់សត្វ។

ចំពោះផលិតកម្មចំណីសត្វបែបពាណិជ្ជកម្មឆ្នាំ២០១៥ មានរោងចក្រផលិតចំណីសត្វធំៗចំនួន០៨រោងចក្រ កំពុងដំណើរការ ដែលផលិតចំណីសត្វផ្សំស្រេចប្រមាណ១លានតោនក្នុងមួយឆ្នាំ។ រោងចក្រទាំងនោះ មានដូចជារោងចក្ររបស់ក្រុមហ៊ុនស៊ីភីខេមបូឌៀ បេតាហ្គ្រូ អេហ្វជី អេស អាគ្រីម៉ាស្ទ័រ គ្រីនហ្វីត វើលវេត ញូហូប និងដីហ្វៃរ។ រោងចក្រចំនួន០៧ផលិតចំណីផ្សំស្រេចសម្រាប់ជ្រូក មាន់ ទា ដោយឡែកក្រុមហ៊ុនដីហ្វៃរជាក្រុមហ៊ុនផលិតចំណីសត្វកំដរ (ឆ្កែ ឆ្មា) សម្រាប់នាំចេញទៅសហរដ្ឋអាមេរិកនិងទីផ្សារអឺរ៉ុប។

ចំពោះការគ្រប់គ្រងគុណភាព សុវត្ថិភាពចំណីសត្វ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានចុះវាយតម្លៃ និងយកវត្ថុវិភាគចំណីសត្វ សារធាតុផ្សំ ដើម្បីវិភាគគុណភាព សុវត្ថិភាពមុនអនុញ្ញាតឲ្យចុះបញ្ជិកា។ ជាមួយនោះ បានចុះពិនិត្យនិងសិក្សាវាយតម្លៃរោងចក្រផលិតចំណីសត្វ ដើម្បីឲ្យរោងចក្រទាំងនោះអនុវត្តនិងផលិតបាននូវចំណីសត្វ ដែលមានគុណភាព មានសុវត្ថិភាព និងអនុវត្តល្អប្រសើរផលិតកម្មចិញ្ចឹមសត្វ (GAHP) មិនគ្រាន់តែសម្រាប់ប្រើប្រាស់លក់ចែកចាយនៅកម្ពុជា តែក៏សម្រាប់ការនាំចេញ។

## ៣.២.ការងារបសុព្យាបាល

### ក. ស្ថានភាពជំងឺសត្វៈ

ក្នុងឆ្នាំ២០១៥នេះ ជំងឺសត្វកើតតិចតួច និងគ្រប់គ្រងមិនឲ្យមានការរាលដាលខ្លាំងក្លា។ ជំងឺសត្វដែលកើតឡើងគួរកត់សម្គាល់មានជំងឺអុតក្តាម សារទឹក ជ្រូកត្រចៀកខៀវ និងជំងឺផ្តាសាយបក្សី។ ជំងឺទាំងនេះបណ្តាលឲ្យគោ ក្របីឈឺចំនួន៥១.២៤៣ក្បាល (១,៥០%) និងងាប់ចំនួន១.៨៨៦ក្បាល (០,០៦%) ជ្រូកឈឺ១២១.៥៦៣ក្បាល (៥,២៩%) ងាប់ ១៤.៥៨៦ក្បាល (០,៦៣%) បក្សីឈឺ៤១២.៤៧៦ក្បាល (១,៦៣%) និងងាប់១២២.៥៣២ក្បាល (០,៤៨%)។

### ខ. ការចាក់ថ្នាំការពារជំងឺឆ្លងសត្វៈ

នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ធ្វើអន្តរាគមន៍ចាក់ថ្នាំ ការពារជំងឺគោក្របីរបស់កសិករ ចំពោះជំងឺសារទឹក អុតក្តាម និងបូសខ្យល់ ដោយឡែកចំពោះជ្រូកនិងបក្សី អង្គភាពនេះធ្វើការផ្សព្វផ្សាយ និងជំរុញឲ្យកសិករ អ្នកចិញ្ចឹមសត្វអនុវត្តដោយខ្លួនឯង។ ការចាក់វ៉ាក់សាំងសារទឹកក្នុងជួរកសិករអនុវត្តបាន១.៤៥៩.៣២១ក្បាល (៤២,៨០%) អុតក្តាមចំនួន ៤៤.៤៧៨ក្បាល (១,៣០%) និងបូសខ្យល់១៩.៩៩៤ក្បាល (០,៥៩%)។ ចំពោះជ្រូកនិងបក្សី កសិករនិងអ្នកចិញ្ចឹមសត្វបានធ្វើការចាក់វ៉ាក់សាំងការពារជំងឺក្នុងបរិមាណគួរកត់សម្គាល់។

**ទិដ្ឋភាពការងារចាក់ថ្នាំការពារជំងឺសាទឹកគោក្របីជូនកសិករ**



### គ. ការធ្វើជីវសុវត្ថិភាព

នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានចុះអនុវត្តវិធានជីវសុវត្ថិភាព និងបាញ់ថ្នាំសម្លាប់មេរោគបានចំនួន ៣៩.០៨៨លើក ក្នុងនោះ នៅតាមកសិដ្ឋានចិញ្ចឹមសត្វ និងកន្លែងចិញ្ចឹមសត្វ២១.៦៨៧លើក ទីផ្សារ១.៧២៦លើក តាមផ្ទះប្រជាជនដែលចិញ្ចឹមសត្វ និងកន្លែងចិញ្ចឹមទា១២.១១២លើក តាមសត្តឃាតដ្ឋាន១.៥១១លើក លើមធ្យោបាយដឹកជញ្ជូន និងកន្លែងស្តុកសត្វ២៣៧លើក និងកន្លែងផ្ទះជំងឺសត្វ១.៥១១លើក។

### ឃ. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ៖

ការធ្វើចរាចរសត្វនិងផលិតផលសត្វនាំចូល នាំចេញ នាំឆ្លងកាត់ និងចរាចរក្នុងស្រុក មានការកើនឡើងដោយសារកំណើននៃតម្រូវការសាច់ សត្វ ផលិតផលសត្វ និងការធ្វើពាណិជ្ជកម្ម។ ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ប្រព្រឹត្តទៅតាមបច្ចេកទេសដូចជា ការត្រួតពិនិត្យអនាម័យកន្លែងចិញ្ចឹម កន្លែងផលិត កន្លែងប្រមូលផ្តុំសត្វ និងកន្លែងផលិតសត្វ ការយកវត្ថុវិភាគនិងការធ្វើវិភាគ និងចេញវិញ្ញាបនបត្រអនាម័យសត្វនិងផលិតផលសត្វ។

**ការនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ**

| ល.រ | នាំចូល | ចំនួនសត្វ និងផលិតផល | នាំចេញ | ចំនួនសត្វ និងផលិតផល | នាំឆ្លងកាត់ | ចំនួនសត្វ និងផលិតផល |
|---|---|---|---|---|---|---|
| ១ | ជ្រូកសាច់រស់ | ៤៩៣.៦០០ក្បាល | គោ ក្របីរស់ | ៧.៣៣៥ក្បាល | គោ ក្របី | ១៦.៨៣៥ក្បាល |
| ២ | ជ្រូកពូជមេ បា | ៧.៧២៧ក្បាល | ជ្រូកមេ បា | ២.០២១ក្បាល | ជ្រូកសាច់ | ១៤៦.៧៥០គ.ក្រ |
| ៣ | កូនមាន់ពូជ | ៣.២៤៥.៩៨២ក្បាល | កូនជ្រូកពូជ | ១៣.៣០៥ក្បាល | ទារស់ | ៩៦០.០០០ក្បាល |
| ៤ | មាន់រស់ | ១.៤៥១.៧៥០ក្បាល | ស្វាក្តាម | ៤.១៨០ក្បាល | ពពែ | ១២.០០០ក្បាល |
| ៥ | ចៀម និងពពែ | ៧៨០ក្បាល | ស្បែកគោ ក្របី | ២.២២១.១២២គ.ក្រ | | |
| ៦ | សាច់គោ ចៀម | ៣៩០.៥៦៤គ.ក្រ | ចំណីឆ្កែ | ១.៦៥១.៨៥៥គ.ក្រ | | |
| ៧ | សាច់មាន់ | ២៥៣.៨៦៥គ.ក្រ | ស្បែកឆ្កែ | ១.០០០គ.ក្រ | | |
| ៨ | សាច់គ្រួច | ៦៤.០០០គ.ក្រ | រោមទា | ៦៣.៤៩៨គ.ក្រ | | |
| ៩ | សាច់ជ្រូក | ៤៨.៥០០ក្បាល | ស្បែកជ្រូក | ៣២.៧០៨គ.ក្រ | | |
| ១០ | សាច់ក្របី | ២.៨០០ក្បាល | | | | |
| ១១ | ស្បែកជ្រូក | ៨៣.១០០គ.ក្រ | | | | |
| ១២ | ប្រហ៊ុម៉ាស | ៩.៦០៥គ.ក្រ | | | | |
| ១៣ | សាច់ទ្រូងមាន់ | ៨៦៩.០៨៤គ.ក្រ | | | | |
| ១៤ | ស្បែកគោផ្សំចំណីឆ្កែ | ២.២៦៤.៣៣០គ.ក្រ | | | | |
| ១៥ | គោពូជ | ៥.៣៩៩ក្បាល | | | | |
| ១៦ | ទារស់ | ១០០.០០០ក្បាល | | | | |

### ង. ការបង្ក្រាបបទល្មើសសត្វនិងផលិផលសត្វ៖

នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានចុះត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វចំនួន២៥៦លើក និងធ្វើការផាកពិន័យបានចំនួន៥៨លានរៀល។

### ច. ភ្នាក់ងារសុខភាពសត្វភូមិ៖

នៅឆ្នាំ២០១៥ ភ្នាក់ងារសុខភាពសត្វភូមិមានចំនួន១២.២២១នាក់ ថយចុះចំនួន១,៣៣% ដោយសន្ទតមកពីការចំណាកស្រុកក្នុងប្រទេស។

## ៣.៣. ការងារសុខភាពសាធារណៈ

### ក. ការបង្កើតសត្តឃាតដ្ឋាន

រហូតមកដល់ចុងឆ្នាំ២០១៥ មានសត្តឃាតដ្ឋានចំនួន១៤៤កន្លែង ក្នុងទូទាំងប្រទេសដែលរួមមានប្រភេទ “ក” ចំនួន ៦កន្លែង (គោ១កន្លែង ជ្រូក១កន្លែង មាន់១កន្លែង និងគោជ្រូក០៣កន្លែង) និងប្រភេទ “ខ” មានចំនួន១៣៨កន្លែង (គោ ១៤កន្លែង ជ្រូក២៥កន្លែង មាន់១កន្លែង និងគោជ្រូក៩៨កន្លែង) ត្រូវបានទទួលការអនុញ្ញាតឲ្យបង្កើតដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល។

**ខ. ចំនួនសត្វពិឃាតៈ** ចំនួនសត្វពិឃាតក្នុងសត្តឃាតដ្ឋានមានចំនួនដូចខាងក្រោមៈ

| ល.រ | សត្តឃាតដ្ឋាន | ចំនួនក្បាល |
|---|---|---|
| ១ | គោ | ១០៦.៣៦២ |
| ២ | ក្របី | ៤.២៣៥ |
| ៣ | ជ្រូក | ៨៣៨.៦៩៩ |
| ៤ | មាន់ | ៧១៣.១៤៥ |

### គ. ការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសាច់ៈ

បានចាត់មន្ត្រីចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន និងអនាម័យមុនពិឃាតអនាម័យសាច់ក្រោយពិឃាតនៅសត្ត-ឃាតដ្ឋាន និងកន្លែងតាំងលក់។ ក្នុងឆ្នាំ២០១៥ មានមន្ត្រីបសុពេទ្យជាង២០០នាក់ប្រចាំការនៅសត្តឃាតដ្ឋាន ដើម្បីពិនិត្យសត្វនិងសាច់នៅសត្តឃាតដ្ឋាននិងមន្ត្រីមួយចំនួនទៀតត្រួតពិនិត្យនៅកន្លែងតាំងលក់។

### ឃ. ការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាលលើការងារសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ៈ

អនុក្រឹត្យនិងប្រកាសទាក់ទងការងារសត្តឃាតដ្ឋាន ទាំងលើទិដ្ឋភាពច្បាប់និងទិដ្ឋភាពបច្ចេកទេស ដូចជាការពិឃាត និងការធ្វើអាជីវកម្មសត្វ ការត្រួតពិនិត្យអនាម័យសត្វ ការស្នើសុំច្បាប់អនុញ្ញាតត្រូវបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់មន្ត្រីអង្គភាពផលិតកម្មនិងបសុព្យាបាល (ចំនួនជាង២០០នាក់) ក្រសួងស្ថាប័ន ជំនាញពាក់ព័ន្ធនិងផ្នែកឯកជន (ម្ចាស់សត្តឃាតដ្ឋាន អាជីវករ អ្នកប្រមូលទិញសត្វ)។ បន្ថែមលើសពីនេះ បានចុះពិនិត្យនិងវាយតម្លៃឲ្យបង្កើតសត្តឃាតដ្ឋានថ្មីចំនួន៧កន្លែង និង២កន្លែងឲ្យបន្តសុពលភាព។

### ង. ការរៀបចំយុទ្ធសាស្ត្រសម្រាប់បង្ការ ទប់ស្កាត់ជំងឺស្វ៊ីណូសៈ

ដោយសហការជាមួយអង្គការពិភពលោកផ្នែកជំងឺសត្វ (OIE) និងអង្គការសុខភាពពិភពលោក (WHO)ក្រសួងបានរៀបចំសេចក្តីព្រាងស្តីពីផែនការយុទ្ធសាស្ត្រសម្រាប់បង្ការ និងទប់ស្កាត់ជំងឺស្វ៊ីណូស។ ឯកសារនេះ ត្រូវធ្វើការពិគ្រោះយោបល់បន្តទៀតជាមួយអង្គការទាំពីរខាងលើ។

## ៣.៤. ការស្រាវជ្រាវបសុព្យាបាលនិងផលិតកម្ម

### ក. វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

វិទ្យាស្ថានមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអង្កេត តាមដាន ឃ្លាំមើល សិក្សាស្រាវជ្រាវ វិភាគរកមេរោគនិងធ្វើរោគវិនិច្ឆ័យជំងឺប្រកបដោយប្រសិទ្ធភាពលើជំងឺជាច្រើនប្រភេទ។ នៅក្នុងឆ្នាំ២០១៥ វិទ្យាស្ថានបានទទួលនិងវិភាគចំនួន ៣.៧៣៧វត្ថុវិភាគ ក្នុងនោះវត្ថុវិភាគផ្នែកវីរុសសាស្ត្រចំនួន១.១៤៦វត្ថុវិភាគ បាក់តេរីសាស្ត្រ១.០១៨វត្ថុវិភាគ បរ៉ាស៊ីតសាស្ត្រ៧៦០វត្ថុវិភាគ លោហិតសាស្ត្រ៧៥៧វត្ថុវិភាគ និងផ្នែកសរីរោគសាស្ត្រ៥៦វត្ថុវិភាគ។ វិទ្យាស្ថានប្រមូលពត៌មានវិភាគពិតមាន ស្តីពីជំងឺសត្វនៅក្នុងប្រទេស ក៏ដូចជាធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការ OIE, FAO, WHO និងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល ដែលមានវិទ្យាស្ថានប៉ាស្ទ័រ នាយកដ្ឋានប្រយុទ្ធប្រឆាំងជំងឺឆ្លង និងបានចុះអង្កេតតាមដាន និងប្រមូលព័ត៌មាន ស្តីពីជំងឺសត្វនៅទូទាំងប្រទេស បានប្រជុំនិងបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការអង្កេតតាមដាន និងស្រាវជ្រាវជំងឺសត្វដល់មន្ត្រីបច្ចេកទេស រាជធានី ខេត្ត បានចំនួន៤៥៥នាក់។

**ខ.វិទ្យាស្ថានស្រាវជ្រាវសេនេទិក និងផលិតកម្មសត្វ:**

ក្នុងគោលបំណងស្រាវជ្រាវនិងផ្សព្វផ្សាយពូជ ស្ថានីយចិញ្ចឹមគោភ្នំតាម៉ៅ ធ្វើការពិសោធន៍និងផលិតមេជីវិតគោ និងផ្សព្វផ្សាយស្មៅ ចំណីសត្វច្រើនប្រភេទដល់ការការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត និងប្រជាពលរដ្ឋ។ បន្ថែមលើសពីនេះ វិទ្យាស្ថានបាននិងកំពុងរៀបចំ និងបំពាក់ឧបករណ៍ សម្ភារ សារធាតុគីមី រ៉េអាទីហ្វ ដើម្បីធ្វើការវិភាគគុណភាពនិងកាកសំណល់ចំណីសត្វ។

## ៣.៥. ការងារផ្សព្វផ្សាយផលិតកម្មនិងបសុព្យាបាល

ឆ្នាំ២០១៥ បានធ្វើការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាន សារាចរណែនាំបច្ចេកទេសបង្ការ ការពារជំងឺឆ្លងសត្វ និងជំងឺស្វ័ណូសនិងបច្ចេកទេសចិញ្ចឹមសត្វ តាមគ្រប់រូបភាពដល់អ្នកពាក់ព័ន្ធទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ជាពិសេសកសិករចិញ្ចឹមសត្វ។ បន្ថែមលើសពីនេះ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានបោះពុម្ភសៀវភៅឯកសារបច្ចេកទេស ខិតប័ណ្ណ ផ្ទាំងរូបភាព ផលិតស្ពតវីដេអូ ផ្សព្វផ្សាយជាច្រើនផងដែរ។

# ៤. លទ្ធផលនៃផ្នែកជលផល

នៅក្នុងឆ្នាំ២០១៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលជលផលជាសេនាធិការ បានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងនិងបង្កើតតំបន់អភិរក្សជលផល ការបង្ក្រាបបទល្មើសនេសាទ ការអភិវឌ្ឍវារីវប្បកម្ម ការបង្កើតស្រះជម្រកត្រី ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយជាដើម។ល។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀត ដែលបានរៀបចំត្រូវបានពិនិត្យកែសម្រួលនិងអនុម័ត ដើម្បីដាក់ឱ្យអនុវត្ត ធានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក្រសួងក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផលដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល។

ទន្ទឹមនឹងការរីកចម្រើនខាងលើនេះ យើងអាចវាយតម្លៃបានថា ការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ដែលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទ ជាលក្ខណៈគ្រួសារ និងធ្វើជាតំបន់អភិរក្សជលផល កំពុងបានផ្តល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋទូទាំងប្រទេស តាមរយៈការនេសាទតាមគ្រួសារដែលមានប្រជានេសាទប្រមាណ១,៥លាននាក់កំពុងចូលរួម។ ម៉្យាងទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល ដើម្បីដាក់ឱ្យអនុវត្តស្របតាមការអភិវឌ្ឍជាក់ស្តែងរបស់ព្រះរាជាណាចក្រកម្ពុជា។

ចំពោះសកម្មភាពការងារនិងលទ្ធផលសំខាន់ៗមួយចំនួនទៀតដែលសម្រេចបានក្នុងឆ្នាំ២០១៥នេះ មានដូចខាងក្រោម÷

## ៤.១. ការអភិវឌ្ឍសហគមន៍នេសាទ

រហូតមកដល់ឆ្នាំ២០១៥នេះ បង្កើតសហគមន៍នេសាទបានចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រ៣៩ ដែលមានសមាជិកសរុបចំនួន៣៣២.១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា១៤៧.៥១៨ គ្រួសារ។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៣៧៧ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ សហគមន៍នេសាទចំនួន១៧ បានរៀបចំសំណុំឯកសារស្នើសុំចុះបញ្ជីបន្ថែមទៀត និងសហគមន៍នេសាទចំនួន១៩ កំពុងដំណើរការចុះហត្ថលេខានៅថ្នាក់ក្រោមជាតិ។ ដោយឡែក ក្នុងឆ្នាំ២០១៥នេះ មានសហគមន៍នេសាទចំនួន៨៥ ត្រូវបានពង្រឹងសមត្ថភាពបន្ថែមតាមការចាំបាច់។

### ៤.២. ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅផ្នែកជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេស មានកន្លែងអភិរក្សជលផលថ្មីចំនួន៥៨កន្លែង សរុបទូទាំងប្រទេសមានចំនួន៥៦១កន្លែង (សហគមន៍៤៦៧កន្លែង)។ ក្នុងឆ្នាំ២០១៥នេះ បានបោះបង្គោលបេតុងបានចំនួន៤៦ដើម និងសាងសង់ស្នាក់ការបណ្តែតទឹកចំនួន៤ និងស្នាក់ការបេតុងបានចំនួន៣ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀត មានដូចខាងក្រោម÷

- អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន៣.៨៣១ហិកតា នៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន៧៥ហិកតា
- រៀបចំអន្លង់ត្រីមេពូជបានចំនួន១៨កន្លែង នៅតំបន់មេគង្គលើ
- បានលែងកូនត្រីនិងកូនបង្កងចំនួន៤,៥លានក្បាល ទៅក្នុងអាងទឹកធម្មជាតិ
- បានអភិរក្សធនធានជលផលកំពុងរងគ្រោះថ្នាក់ដូចជា អណ្តើកសរសៃ កន្ទាយក្បាលកង្កែប ផ្សោតទឹកសាប និងផ្សោតទឹកប្រៃ អណ្តើកសមុទ្រ សេះសមុទ្រ។ល។ ដែលធ្វើឱ្យចំនួនកើនឡើងចន្លោះពី១០-១៥%។

### ៤.៣. ការបង្ក្រាបបទល្មើសជលផល

ដោយមានបទបញ្ញា០១បប និងច្បាប់ជលផលជាបង្អែក មន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់បានសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ជាពិសេសបានយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលមិនឱ្យមានការលួចចូលធ្វើនេសាទអាណាធិបតេយ្យឡើយ។ ប៉ុន្តែទោះជាខិតខំយ៉ាងណាក៏ដោយ ដែននេសាទដ៏ធំធេងនោះ ក៏មិនទាន់អាចទប់ស្កាត់នូវបទល្មើសនេសាទបាន១០០%នៅឡើយដែរ។

លទ្ធផលជាក់ស្តែង គឺបង្ក្រាបបទល្មើសបានចំនួន៣.៩៧៤ករណី ប្រៀបធៀបឆ្នាំមុនកើនឡើងចំនួន២៨៨ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន៣.៣៧៥ករណី ពិន័យអន្តរការណ៍ចំនួន៤១៨ករណី បញ្ជូនទៅតុលាការចំនួន១៨១ករណី ដាក់ពន្ធនាគារចំនួន៨៥នាក់ ប្រាក់ពិន័យ និងលក់វត្ថុតាងចំនួនជាង១,០១៧លានរៀល។

បានប្រជុំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍ថ្នាក់ដឹកនាំនៅតាមមូលដ្ឋានចំនួន២៨០វគ្គ អ្នកពាក់ព័ន្ធចូលរួមចំនួន១៧.៨៧៤នាក់ ក្នុងនោះស្ត្រីចំនួន៤.៥១១នាក់។

### ៤.៤. ការអភិវឌ្ឍន៍វារីវប្បកម្ម

- ការចិញ្ចឹមត្រីឆ្នាំ២០១៥ អនុវត្តបានចំនួន១៤៣.១៤៧តោន ស្មើនឹង៩៩,៤០% នៃផែនការ១៤៤.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន២៣.០៨៦តោន

- ការចិញ្ចឹមក្រពើឆ្នាំ២០១៥ អនុវត្តបានចំនួន២៩៨.៦៦៩តោន ស្មើនឹង១១៩,៤៧% នៃផែនការ២៥០.០០០ក្បាល បើប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន៨៣.១៦៩ក្បាល

- ការផលិតកូនត្រីពូជឆ្នាំ២០១៥ អនុវត្តបានចំនួន១៨០.៥លានកូន ស្មើនឹង១០០,២៨% នៃផែនការ១៨០លានកូន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន៦០.៥លានកូន

- កន្លែងភ្ញាស់ត្រីសរុបមានចំនួន៣០៧កន្លែង ក្នុងនោះមាន២៩៨កន្លែងជារបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់បច្ចេកទេសពីមន្ត្រីរដ្ឋបាលជលផល

- បានពិសោធន៍ឱ្យចំណីត្រីរ៉ស់ ដោយប្រភេទចំណីគ្រាប់ និងត្រីនុយ បានបង្ហាញថា ការប្រើប្រាស់ចំណីគ្រាប់មានការលូតលាស់លឿនជាងចំណីត្រីនុយ

- បានសាកល្បងភ្ញាស់ក្តាមសេះ ដោយទទួលបានកូនក្តាមចំនួន៨.០០០ក្បាល សម្រាប់លែងក្នុងធម្មជាតិ

- មានប្រជាពលរដ្ឋប្រមាណ៦២.០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៥៤នាក់ ជាគ្រូបង្គោល និងជា គ្រូផ្សព្វផ្សាយនៅមូលដ្ឋាន។

### ៤.៥. ការបង្កើតស្រះជម្រកត្រីសហគមន៍

អនុវត្តតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** កាលពីឆ្នាំ២០០៩ នៅខេត្តកែប មន្ត្រីរដ្ឋបាលជលផលគ្រប់ខេត្ត បានបង្កើតស្រះជម្រកត្រីសហគមន៍បាន៧៤៤កន្លែង គិតរហូតដល់ចុងឆ្នាំ២០១៥នេះ នៅខេត្តកំពង់ស្ពឺ មានចំនួនច្រើនជាងគេរហូតដល់១០៥កន្លែង។ សកម្មភាពនេះ ក៏បានធ្វើឱ្យផលត្រីតាមវាលស្រែកើនឡើងផងដែរ។

### ៤.៦. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព

ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព គឺជាការងារថ្មីដែលរដ្ឋបាលជលផលកំពុងផ្សព្វផ្សាយ ដើម្បីឱ្យគ្រប់កន្លែងផលិតនិងកែច្នៃត្រី ស្របតាមស្តង់ដារអនាម័យឱ្យបានត្រឹមត្រូវ ក្នុងន័យធានាសុខភាពសាធារណៈនិងទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាពភូមិ១ផលិតផលជលផល១ផងដែរ។ មិនតែប៉ុណ្ណោះ បានរៀបចំសេចក្តីព្រាងស្តីពីប្រព័ន្ធត្រួតពិនិត្យ និងសុវត្ថិភាពអាហារសម្រាប់ផល ផលិតផលជលផល សេចក្តីព្រាងគោលការណ៍ស្តីពីអនុវត្តអនាម័យល្អនិងការផលិតល្អ និងសេចក្តីប្រកាសស្តីពីវិធានគ្រប់គ្រងនិងត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផល ផលិតផលជលផល។

### ៤.៧. ការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា EU, FAO, JICA, MRC, NACA, CI, SEAFDEC, World Fish Center ជាដើម។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល និងប៉ុស្ទ័រជាច្រើនពាន់សន្លឹក។

### ៤.៨. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកជលផល

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល១០ឆ្នាំ (២០១០-២០១៩) បានរៀបចំឡើងដោយសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ជលផល ហើយត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តយល់ព្រមឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ដែលបានអនុវត្តជាង៤ឆ្នាំហើយ។ បច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យកែសម្រួលឯកសារនេះ ដើម្បីឱ្យសមស្របនិងអនុវត្តតាមសភាពការណ៍ជាក់ស្តែង។

### ៤.៩. ស្ថិតិជលផល

- ស្ថិតិផលនេសាទទឹកសាបឆ្នាំ២០១៥ អនុវត្តបានចំនួន៤៨៧.៩០៥តោន ក្នុងនោះមានដូចខាងក្រោម÷
  - នេសាទដាយត្រីរដូវនេសាទ២០១៥-២០១៦ អនុវត្តបានចំនួន១៣.៤២៦តោន ស្មើនឹង១១១,៨៨% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១.១៤១តោន
  - នេសាទគ្រួសារក្នុងដែននេសាទ២០១៥ អនុវត្តបានចំនួន៣៣៩.២៦៩តោន ស្មើនឹង៩៦,៩៣% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៣.៣៣១តោន
  - នេសាទគ្រួសារក្នុងវាលស្រែ២០១៥ អនុវត្តបានចំនួន១៣៥.២១០តោន ស្មើនឹង៩០,១៤% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ១៤.៩១០តោន
- ស្ថិតិផលនេសាទសមុទ្រឆ្នាំ២០១៥ អនុវត្តបានចំនួន១២០.៥០០តោន ស្មើនឹង១០៩,៥៥% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង២៥០តោន
- ស្ថិតិវារីវប្បកម្មឆ្នាំ២០១៥ អនុវត្តបានចំនួន១៤៣.១៤១តោន ស្មើនឹង៩៩,៤០% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង២៣.០៨៦តោន។

**ក្រាហ្វិកបង្ហាញអំពីស្ថិតិនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្ម២០១១-២០១៥**




## ៥. លទ្ធផលនៃផ្នែកព្រៃឈើ

### ៥.១. ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍

ឆ្នាំ២០១៥ ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រេចបានសរុប៥៧៤បង្គោល សរុបប្រវែង៩៣គ.ម ដែលក្នុងនោះដែនសមត្ថកិច្ចខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ បានបោះបង្គោលសរុបចំនួន១១២បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំបានចំនួន ១១២បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើក្រចេះបានចំនួន១៧៥បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើកោះកុងបានចំនួន១៧៥បង្គោល។ ប្រៀបធៀបនឹងឆ្នាំ២០១៤បានចំនួន ១.៤៧៣បង្គោល ដែលប្រើប្រាស់ថវិការដ្ឋ និងដៃគូរអភិវឌ្ឍន៍។

នៅឆ្នាំ១៩៦៥ ធនធានគម្របព្រៃឈើកម្ពុជាគ្របដណ្តប់ចំនួន៧៣,០៤% ធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស។ រដ្ឋបាលព្រៃឈើបានធ្វើការវាយតម្លៃអំពី បម្រែបម្រួលធនធានគម្របព្រៃឈើថ្នាក់ជាតិជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០១៤ ដោយគិតជាមធ្យមរយៈពេល៤ឆ្នាំធ្វើការវាយតម្លៃម្តង។ តាមលទ្ធផលវាយតម្លៃនេះឃើញថា ធនធានគម្របព្រៃឈើបានធ្លាក់ចុះជាបន្តបន្ទាប់ ពិសេសក្នុងអំឡុងពេលចុងក្រោយនេះ (ចុងឆ្នាំ២០១០-២០១៤)។

**ក្រាហ្វិកបង្ហាញអំពីបម្រែបម្រួលគម្របព្រៃឈើកម្ពុជាឆ្នាំ១៩៦៥-២០១៤**



### ផែនទីបង្ហាញអំពីបម្រែបម្រួលគម្របព្រៃឈើកម្ពុជាឆ្នាំ២០១០-២០១៤




## ៥.២. សហគមន៍ព្រៃឈើ

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន៤០សហគមន៍ព្រៃឈើ គ្របដណ្តប់លើផ្ទៃដីសរុបទំហំ១១.៦៩៥ហិកតា នៅក្នុងខេត្តស្វាយរៀង បាត់ដំបង ពោធិ៍សាត់ ស្ទឹងត្រែង និងព្រះវិហារ និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន២៨សហគមន៍ លើផ្ទៃដីទំហំ២៣.៥៣៦ហិកតា នៅខេត្តក្រចេះ កំពង់ធំ បាត់ដំបង រតនគិរី និងពោធិ៍សាត់

- បានពិនិត្យនិងកែសម្រួលលើសេចក្តីព្រាងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន៥០ នៅខេត្តស្ទឹងត្រែង កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងក្រចេះ និងបានផ្តល់ការយល់ព្រមលើផែនការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន៤៨កន្លែង គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ៣២.១៦២ហិកតា

- ចំនួនសហគមន៍ព្រៃឈើសរុបកើនដល់៤៩៩ ប្រៀបធៀបនឹងឆ្នាំ២០១៤ មានចំនួន៤៨៥។

### ក្រាហ្វិកបង្ហាញអំពីចំនួនសហគមន៍ឆ្នាំ២០១១-២០១៥




## ៥.៣. ការងារដាំដើមឈើ

– បានបណ្តុះកូនឈើចែកចាយជូនប្រជាជនសរុបចំនួន២.០៥២.៣៨១ដើម ក្នុងនោះបានមកពីថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើចំនួន២៥កន្លែង និងថ្នាលបណ្តុះកូនឈើសម្តេចតេជោចំនួន៤កន្លែង

– បានដាំដើមឈើសរុបចំនួន៤៦៩០ហត ក្នុងនោះ ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋបាលព្រៃឈើដាំដើមឈើបានចំនួន៤១៥ហិកតា ក្រុមហ៊ុនដាំឈើជាលក្ខណៈដៃគូ សហការជាមួយរដ្ឋបាលព្រៃឈើដាំឈើបានចំនួន១.៨៧៥ហិកតា និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដាំបានចំនួន២.៣៧០ហិកតា និងដាំក្នុងពិធីបុណ្យរុក្ខទិវាទូទាំងប្រទេសបាន៣០ហិកតា បើប្រៀបធៀបនឹងឆ្នាំ២០១៤ មានការថយចុះចំនួន៧៣២ហិកតា។

**ក្រាហ្វិកបង្ហាញអំពីផ្ទៃដីដាំដុះដើមឈើឆ្នាំ២០១១-២០១៥** (ហ.ត)




– បានប្រារព្ធពិធីបុណ្យរុក្ខទិវា នាថ្ងៃទី០៩ ខែកក្កដា នៅភូមិថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុក នៃខេត្តកំពង់ធំ លើផ្ទៃដីទំហំ១០ហិកតា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**។

### ៥.៤. ការងារស្រាវជ្រាវ និងបណ្តុះបណ្តាល

បានអនុវត្តនូវគម្រោងសិក្សាស្រាវជ្រាវចំនួន០៨ រួមមាន÷ (១). គម្រោងពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងការអភិរក្ស និងស្រាវជ្រាវព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តភាព (២). គម្រោងស្តារព្រៃឈើឡើងវិញក្រោយអាជីវកម្មនៅតំបន់បាក់ស្នា ខេត្តកំពង់ធំ (៣). គម្រោងសិក្សាស្រាវជ្រាវពីបម្រែបម្រួលវដ្តទឹកក្នុងតំបន់អាងទន្លេមេគង្គ (៤). គម្រោងច្រករបៀងអភិរក្សជីវចម្រុះនៅមហាអនុតំបន់មេគង្គ (៥). គម្រោងស្តារព្រៃឈើឡើងវិញនិងបង្កើតទីតាំងស្រាវជ្រាវនៅខេត្តសៀមរាប (៦). គម្រោងរៀបចំផែនការគ្រប់គ្រងព្រៃឈើនៅតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើ (៧). ការជំរុញការងារស្តារព្រៃឈើនៅកម្ពុជានិងវៀតណាមតាមរយៈការបង្កើតឡូត៍បង្ហាញ និងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយគ្រាប់ពូជ (៨). គម្រោងការរៀបចំផែនការគ្រប់គ្រងព្រៃឈើតាមតំបន់ទីជម្រាលស្ទឹងព្រែកត្នោតផ្អែកលើផែនទេសភាព។

### ៥.៥. ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

– បានទទួលសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃពីរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន២.១៨៩ករណី ក្នុងនោះសំណុំរឿងត្រូវពិន័យអន្តរការណ៍ចំនួន៦៤៣ករណី និងសំណុំរឿងត្រូវបញ្ជូនទៅតុលាការចំនួន១.៥៤៦ករណី។ ចំពោះវត្ថុតាងបទល្មើសព្រៃឈើ និងសត្វព្រៃដែលបានចាប់ឃាត់ និងដកហូតមានឈើមូល-ជ្រុង៩៩៦ម$^{៣}$ ឈើអារ ៤.៧០៥ម$^{៣}$ ឈើគ្រាក់គ្រញូង១១៣ម$^{៣}$ និង៥.៧៩២គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទ៤.០១៨ក្បាល និង២.៣៩៤គ.ក្រ និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។ ដីព្រៃឈើដែលបានកាប់រានចំនួន២.៧០៩ហិកតា ត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងបានដកហូតរណារយន្តបានចំនួន៤៨៦គ្រឿង។ ជារួម បើប្រៀបធៀបនឹងឆ្នាំ២០១៤ មានការថយចុះចំនួន២១១ករណី។

– បាននិងដំណើរការបញ្ចូលទូវរាល់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានព័ត៌មានបទល្មើសព្រៃឈើ (Case Tracking System-CTS)

– បានចុះពង្រឹងការអនុវត្តច្បាប់ចំនួន៣៨លើក នៅក្នុងខេត្តកោះកុង ព្រះសីហានុ កំពត កែប តាកែវ ត្បូងឃ្មុំ ក្រចេះ មណ្ឌលគីរី រតនគីរី ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ សៀមរាប និងឧត្តរមានជ័យ ដោយបានចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើបានជាច្រើនករណី។

**ក្រាហ្វិកបង្ហាញអំពីសំណុំរឿងបទល្មើសព្រៃឈើ**




## ៥.៦. ការងារអភិរក្សព្រៃឈើនិងសត្វព្រៃ

– បានពិគ្រោះយោបល់ចំនួន៥លើក លើការងារបង្កើតព្រៃការពារព្រៃឡង់ និងព្រៃការពារសៀមប៉ាង ជាមួយអាជ្ញាធរភូមិ ឃុំ ប្រធានសហគមន៍ព្រៃឈើ និងសមាជិកសហគមន៍សំខាន់ៗនៅក្នុងស្រុកសណ្ដាន់ខេត្តកំពង់ធំ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និងស្រុកព្រែកប្រសប់ខេត្តក្រចេះ

– បានបញ្ជូនសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកែសម្រួលទំហំតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

– បានរៀបចំអនុក្រឹត្យស្ដីពីការបង្កើតតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃព្រះរការ ដែលមានទំហំ៩២.១៣២ហិកតា ក្នុងខេត្តព្រះវិហារ

– បានចុះកំណត់តំបន់សក្ដានុពលសម្រាប់បង្កើតជាតំបន់ទេសចរធម្មជាតិនៅក្នុងព្រៃការពារសីមា

– បានថែរក្សាការពារសត្វព្រៃគ្រប់ប្រភេទចំនួន១.៣១១ក្បាល ក្នុងឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ (បក្សី៥១ប្រភេទ ថនិកសត្វ៤៤ប្រភេទ និងល្មូន១២ ប្រភេទ) សង្គ្រោះសត្វព្រៃគ្រប់ប្រភេទចំនួន១.៣១៧ក្បាល សត្វកើតថ្មី៧០ក្បាល ស្ដារលទ្ធភាពជីវសាស្ត្រ និងការដោះលែងទៅព្រៃធម្មជាតិវិញចំនួន១.២១២ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន២.៣២៣ក្បាល សាងសង់សំណង់ទ្រុងសត្វ និងសំណង់ផ្សេងៗបានជាច្រើនទៀត

– បានផ្ដល់ចំណីដល់សត្វត្មាតនៅខេត្តស្ទឹងត្រែង-ក្រចេះ ព្រៃការពារព្រះវិហារ ព្រៃការពារសៀមប៉ាង និងព្រៃការពារមណ្ឌលគីរី ដោយរាប់ឃើញត្មាតសរុបចំនួន២៣៥ក្បាល និងបានធ្វើការការពារសំបុកសត្វត្រយ៉ងចង្កំកសចំនួន៦២សំបុក ត្រដក់ត្បូចចំនួន១៦៨សំបុក រំពេរទន្លេចំនួន១៨សំបុក ត្មាតចំនួន៣១សំបុក ត្រយ៉ងយក្សចំនួន២៧សំបុក នៅខេត្តស្ទឹងត្រែង-ក្រចេះ ព្រៃការពារសៀមប៉ាង និងព្រៃការពារព្រះវិហារ។

### ៥.៧. ការងារខ្សែសង្វាក់ផលិតកម្មនិងពាណិជ្ជកម្ម

– បានធ្វើការសិក្សាអត្រាកែច្នៃកូនឈើចំនួន១៦ក្រុមហ៊ុន និងបានលើកសំណើសុំបង្កើតរោងម៉ាស៊ីនអារ កែច្នៃឈើជូនក្រុមហ៊ុនចំនួន១៧ និងពន្យារសុពលភាពជូនក្រុមហ៊ុនចំនួន២៣ក្រុមហ៊ុន។ បានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន៦ និងបានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន២

– បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃចំនួន៧ក្រុមហ៊ុន ព្រមទាំងអាជ្ញាប័ណ្ណនាំចូលផលិតផលឈើចំនួន៣ក្រុមហ៊ុន និងបានផ្តល់ការពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំណិតឈើអាកាស្យា និងប្រេងខ្យល់ចំនួន១ក្រុមហ៊ុន

– បានលើកសំណើសុំគោលការណ៍នាំចេញផលិតផលឈើកែច្នៃ និងអនុផលព្រៃឈើកែច្នៃចំនួន៨ក្រុមហ៊ុន និងសំណើសុំគោលការណ៍នាំចូលចំនួន៤ក្រុមហ៊ុន ព្រមទាំងសំណើសុំពន្យារសុពលភាពគោលការណ៍អាជ្ញាប័ណ្ណនាំចេញចំនួន១ ក្រុមហ៊ុន។

### ៥.៨. ការប្រមូលចំណូលពីផ្នែកព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរដ្ឋបាលព្រៃឈើ បានទទួលចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើ និងសេវាសាធារណៈចំនួន៣២.២៦៣.១៩១.២១៥រៀល ក្នុងនោះ បង់ចូលថវិការដ្ឋនិងមូលនិធិអភិវឌ្ឍព្រៃឈើជាតិមានចំនួន២៥.៤៨២.៣០៤.៧៧៤រៀល និងទូទាត់ប្រាក់រង្វាន់មានចំនួន៦.៧៨០.៨៨៦.៤៤១រៀល។

## ៦. ការផ្តល់សេវាកម្មគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៦. ១. លទ្ធផលសម្រេចបានលើការអនុវត្តគោលនយោបាយនិងការវិនិយោគឯកជន

#### ក. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨

ក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែកក្កដា ឆ្នាំ២០១៤។ ផ្អែកលើមូលដ្ឋាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ត្រូវមានឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ស្របជាមួយគ្នាដែរ។ នៅក្នុងផែនការយុទ្ធសាស្ត្រនេះ ក្រសួងបានកំណត់បាននូវកម្មវិធីថ្មីចំនួន៥ អនុកម្មវិធីថ្មីចំនួន៦៣ និងសកម្មភាពដែលត្រូវអនុវត្តចំនួនជាង៥០០សកម្មភាព។

ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តមានប្រសិទ្ធភាពខ្ពស់ កិច្ចប្រជុំពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធនានាត្រូវបានរៀបចំឡើងចំនួន៤លើក (លើកទី១នៅខែតុលា ឆ្នាំ២០១៤ លើកទី២នៅខែធ្នូ ឆ្នាំ២០១៤ លើកទី៣នៅខែមីនា ឆ្នាំ២០១៥ និងលើកទី៤នៅខែឧសភា ឆ្នាំ២០១៥) ដោយមានការចូលរួមពីថ្នាក់ដឹកនាំពីគ្រប់អង្គភាពជំនាញ មន្ទីរកសិកម្មខេត្ត តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការសង្គមស៊ីវិល សំដៅធ្វើយ៉ាងណាឱ្យឯកសារយុទ្ធសាស្ត្រនេះមានលក្ខណៈល្អប្រសើរ មានតម្លាភាព និងមានភាពរលូនក្នុងវិស័យរវាងអនុវិស័យឬផ្នែកនានា ក៏ដូចជាមានភាពរលូនជាមួយវិស័យពាក់ព័ន្ធនានាផងដែរ។

ពិនិត្យជារួម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ ត្រូវបានរៀបចំកសាងឡើង សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំសម្រាប់

អនុវត្តនិងជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ផែនការយុទ្ធសាស្រ្តនេះ ត្រូវបានផ្សព្វផ្សាយនិងដាក់ឱ្យប្រើប្រាស់កាលពីខែមករា ឆ្នាំ២០១៦ ហើយផែនការនេះគឺជាមូលដ្ឋានមួយដ៏រឹងមាំសម្រាប់ការកសាង “ផែនការយុទ្ធសាស្រ្តថវិកាបីឆ្នាំរំកិល” និង“ថវិកាកម្មវិធីប្រចាំឆ្នាំ” របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមកទល់ពេលនេះ ការងារទាំងអស់ត្រូវបានវាយតម្លៃថាទទួលបានជោគជ័យគួរជាទីពេញចិត្ត។

## ខ. ផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦

ផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ ជាពិសេសស្របតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០២ សរណន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦។

ផែនការយុទ្ធសាស្រ្តថវិកានេះ គឺជាឧបករណ៍និងជាយន្តការដ៏សំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងភាពសក្តិសិទ្ធនៃការប្រើប្រាស់ថវិកា ក្នុងក្របខណ្ឌនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការតម្រង់វិភាជថវិកាបម្រើឲ្យសកម្មភាពជាអាទិភាព ធ្វើយ៉ាងណាសម្រេចឲ្យបាននូវគោលនយោបាយជាយុទ្ធសាស្រ្ត និងជាអាទិភាព ក៏ដូចជាគោលនយោបាយរួម និងអនុសាសន៍គន្លឹះរបស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។

ទន្ទឹមនេះដែរ ផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦ បានផ្តោតជាសំខាន់លើការងារបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ពិសេសការងារស្រាវជ្រាវ ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការពង្រឹងសេវាកសិកម្មថ្នាក់ក្រោមជាតិឲ្យមានសមត្ថភាពបច្ចេកទេសប្រសើរជាងមុន និងជំរុញការអភិវឌ្ឍវិស័យផលិតកម្មសត្វ និងវារីវប្បកម្មឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង ដើម្បីសន្តិសុខស្បៀងនិងលើកស្ទួយកម្រិតជីវភាពប្រជាកសិករឲ្យរួចផុតពីភាពក្រីក្រ។ ផែនការយុទ្ធសាស្រ្តថវិកានេះ ក៏បានរួមបញ្ចូលផងដែរនូវការអនុវត្តគោលនយោបាយជាយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ។ លើសពីនេះទៀតនោះ កម្មវិធីជាយុទ្ធសាស្រ្តធំ២ទៀត ក៏ត្រូវបានបន្តរៀបចំនិងជំរុញឲ្យអនុវត្តសំដៅសម្រេចបាននូវការគ្រប់គ្រងធនធានធម្មជាតិ (ព្រៃឈើនិងជលផល) ប្រកបដោយចីរភាព។ ការកំណត់នូវសូចនាករនិងគោលដៅសូចនាករតាមកម្មវិធីនីមួយៗមានលក្ខណៈច្បាស់លាស់ជាងមុន ដែលបង្កភាពងាយស្រួលក្នុងការតាមដាននិងវាយតម្លៃលើរាល់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនានា ដែលបានប្រើប្រាស់ធនធានហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។

## គ. ការវិនិយោគឯកជន

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ដីសម្បទានសេដ្ឋកិច្ច ក្នុងគោលបំណងលើកទឹកចិត្ត និងទាក់ទាញការវិនិយោគឯកជនទាំងក្នុងនិងក្រៅប្រទេស សំដៅអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ជាលក្ខណៈប្រពលវប្បកម្មនិងពិពិធកម្ម ដែលរួមចំណែកដល់ការបង្កើតការងារនៅជនបទ លើកស្ទួយជីវភាពប្រជាពលរដ្ឋឱ្យមានលក្ខណៈប្រសើរឡើង បង្កើនការនាំចេញផលិតផលកសិកម្ម និងបង្កើនចំណូលរដ្ឋសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។

គិតមកទល់ឆ្នាំ២០១៥ ក្រុមហ៊ុនដែលបានចុះកិច្ចសន្យារួចជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងនៅមានសុពលភាពមានចំនួនសរុប១១៣ក្រុមហ៊ុន ស្ថិតនៅ១៧ខេត្ត លើផ្ទៃដីសរុបតាមកិច្ចសន្យាចំនួន១.០៩០.៣២២ហិកតា និងផ្ទៃដីអាជីវកម្ម-ផលិតកម្មសរុបចំនួន៧៣៥.៧៥៩ហិកតា។

- **ការងារឈូសឆាយដាំដុះ÷** ឈូសឆាយបានលើផ្ទៃដីចំនួន៣៨៨.៥១២ហិកតា ដាំដុះដំណាំកសិ-ឧស្សាហកម្ម បានចំនួន២៩៩.៧៦៣ហិកតា។

- **ការងារសាងសង់÷** សាងសង់ប្រព័ន្ធផ្លូវគ្រប់ប្រភេទសរុបចំនួន១០.៣៦៩គីឡូម៉ែត្រ

- **ការប្រើប្រាស់កម្លាំងពលកម្ម÷** ពលកម្មសរុបមានចំនួន៤៨.១០៥នាក់ ក្នុងនោះមានបុគ្គលិកខ្មែរចំនួន១៣.១៣៩នាក់ កម្មករខ្មែរចំនួន១២.៩៤៧នាក់ កម្មករអណ្តែតចំនួន២០.២៤១នាក់ និងអ្នកជំនាញបច្ចេកទេសបរទេសចំនួន១.៧៧៨នាក់។

ដោយឡែកក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចដែលមានទំហំផ្ទៃដីតូចជាង១.០០០ហិកតា បានចុះកិច្ចសន្យាជាមួយខេត្តមានចំនួន៣២ក្រុមហ៊ុនលើផ្ទៃដីចំនួន៣៦.៩៨៣ហិកតា។

- **ការងារឈូសឆាយដាំដុះ÷** ឈូសឆាយបានលើផ្ទៃដីចំនួន១៤.៤៨០ហិកតា ដាំដុះដំណាំកសិ-ឧស្សាហកម្មបានចំនួន ១១.០៧៩ហិកតា។

- **ការងារសាងសង់÷** សាងសង់ប្រព័ន្ធផ្លូវគ្រប់ប្រភេទសរុបចំនួន ៣៥៩គីឡូម៉ែត្រ

- **ការប្រើប្រាស់កម្លាំងពលកម្ម÷** ពលកម្មសរុបមានចំនួន២.៩៥៣នាក់ ក្នុងនោះមានបុគ្គលិកខ្មែរចំនួន២៣១នាក់ កម្មករខ្មែរចំនួន៧៣៦នាក់ កម្មករអណ្តែតចំនួន១.៩៧៨នាក់ និងអ្នកជំនាញបច្ចេកទេសបរទេសមួយចំនួនទៀត។

ក្រុមហ៊ុនដែលបានទទួលគោលការណ៍វិនិយោគមុនបទបញ្ជាលេខ០១បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលមានក្រុមហ៊ុនចំនួន១៣។ យោងតាមលិខិតលេខ១៧៥៥សជណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវបានរាជរដ្ឋាភិបាលនិរាករណ៍ចំនួន០៥ក្រុមហ៊ុនលើផ្ទៃដីសរុបចំនួន២៩.៥០១ហិកតា។ ក្រុមហ៊ុននៅសល់ចំនួន៨លើទំហំផ្ទៃដីចំនួន៥៤.៤៨៧ហិកតា បាននិងកំពុងអនុវត្តនីតិវិធីតាមខ្លឹមសារគោលការណ៍វិនិយោគរបស់រាជរដ្ឋាភិបាល។

**ស្ថានភាពក្រុមហ៊ុនបានលុបគោលការណ៍និងកិច្ចសន្យា÷**

ដោយក្រុមហ៊ុនមួយចំនួនមានភាពអសកម្ម លើកិច្ចដំណើរការគម្រោងវិនិយោគរបស់ខ្លួន រាជរដ្ឋាភិបាលបានសម្រេចលុបគោលការណ៍និងកិច្ចសន្យាវិនិយោគ។ គិតមកដល់ឆ្នាំ២០១៥នេះ ក្រុមហ៊ុនដែលត្រូវបានរាជរដ្ឋាភិបាលលុបគោលការណ៍ និងកិច្ចសន្យាមានសរុបចំនួន៧៨ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន៦៣០.៨៩៥ហិកតា ក្នុងនោះមាន÷

- ក្រុមហ៊ុនមានទំហំផ្ទៃដីធំជាងមួយពាន់ហិកតាមានចំនួន៦៧ក្រុមហ៊ុន លើផ្ទៃដីចំនួន៦២១.៦០៣ហិកតា
- ក្រុមហ៊ុនមានទំហំផ្ទៃដីតូចជាងមួយពាន់ហិកតាមានចំនួន១១ក្រុមហ៊ុន លើផ្ទៃដីចំនួន៩.២៩២ហិកតា ។

ក្រុមហ៊ុនដែលត្រូវបានរាជរដ្ឋាភិបាលលុបគោលការណ៍ និងកិច្ចសន្យាទាំង៧៨ក្រុមហ៊ុននេះមានក្រុមហ៊ុនចំនួន២១ត្រូវបាននិរាករណ៍តាមសំណើរបស់គណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។ ក្រុមហ៊ុនទាំង២១មាន ÷

- ក្រុមហ៊ុនចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន១២ក្រុមហ៊ុន លើផ្ទៃដីចំនួន២២៧.៥៦៧ហិកតា
- ក្រុមហ៊ុនចុះកិច្ចសន្យាជាមួយខេត្តមានចំនួន០៤ក្រុមហ៊ុន លើផ្ទៃដីចំនួន៣.៤៤៣ហិកតា
- ក្រុមហ៊ុនទទួលគោលការណ៍វិនិយោគពីរាជរដ្ឋាភិបាល តែមិនទាន់ចុះកិច្ចសន្យាមានចំនួន៥ក្រុមហ៊ុន លើផ្ទៃដីចំនួន២៩.៥០១ហិកតា ។

**ស្ថានភាពក្រុមហ៊ុនបានបង់ប្រាក់កក់÷** ក្រុមហ៊ុនដែលបានបង់ប្រាក់កក់ធានាកិច្ចសន្យាជូនរដ្ឋ នៅធនាគារជាតិសរុបមានចំនួន១៣៤ក្រុមហ៊ុន លើទំហំទឹកប្រាក់សរុបចំនួន៦.០០២.៩៥៩,៨៦ដុល្លារ និង ៨០,៦៨លានរៀល។

**ការងារចុះបញ្ជីដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ÷** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំចុះបញ្ជីដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចបានចំនួន១១០ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ៩៧៦.៩១៧,៩៥ហិកតា ក្នុងនោះមាន÷ ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចំនួន១០៣ក្រុមហ៊ុន លើផ្ទៃដីចំនួន៩៣០.៤៣០,៩៥ហិកតា និងក្រុមហ៊ុនទទួលបានគោលការណ៍វិនិយោគពីរាជរដ្ឋាភិបាលតែមិនទាន់ចុះកិច្ចសន្យាបានចំនួន០៧ក្រុមហ៊ុន លើផ្ទៃដីចំនួន៤៦.៤៨៧ហិកតា។

ជាលទ្ធផល គិតមកដល់ឆ្នាំ២០១៥ មានក្រុមហ៊ុនចំនួន៤៩ក្រុមហ៊ុន បានធ្វើការចុះបញ្ជីដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្នុងនោះមាន÷

- ក្រុមហ៊ុនចុះកិច្ចសន្យារួចជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (កិច្ចសន្យានៅមានសុពលភាព) សរុបចំនួន៤២ក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុនចំនួន២០ ទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងក្រុមហ៊ុនចំនួន២២ បានផ្តិតមេដៃស្នើសុំចុះបញ្ជីដីរួច និងកំពុងបន្តនីតិវិធីចុះបញ្ជីដី។
- ក្រុមហ៊ុនមិនទាន់ចុះកិច្ចសន្យាសរុបចំនួន០៧ក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុនចំនួន០៣ ទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ក្រុមហ៊ុនចំនួន០៤ បានផ្តិតមេដៃស្នើសុំចុះបញ្ជីដីរួច និងកំពុងបន្តនីតិវិធីចុះបញ្ជីដី។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រគល់សិទ្ធិជូន លោកមន្ទីរកសិកម្មខេត្ត នាយខណ្ឌរដ្ឋបាលព្រៃឈើ និងនាយខណ្ឌរដ្ឋបាលជលផលជាតំណាងនីតិបុគ្គល ក្នុងការបំពេញឯកសារចុះបញ្ជីដីរដ្ឋ តាមរយៈលិខិតលេខ៧៤១៧/៥៨៥ កសក.នផ.ផក និង លិខិតលេខ៧៤១៨/៥៨៦ កសក.នផ.ផក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥។

## ៦.២. ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យកសិកម្ម

ទន្ទឹមនឹងការអនុវត្តកម្មវិធីនីតិកម្មឆ្នាំ២០១៥ អង្គភាពជំនាញនីមួយៗក៏បានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍបទដ្ឋានគតិយុត្ត ដែលជាកម្មវិធីនីតិកម្មវិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀង និងការអភិវឌ្ឍផលិតកម្មកសិកម្មប្រកបដោយចីរភាព រួមមាន÷

### ក. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកដំណាំ

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម និងសេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ កំពុងត្រូវបានរៀបចំយ៉ាងសកម្ម។ ដោយឡែក បទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្មដែលត្រូវបានរៀបចំ និងបានប្រកាសឱ្យប្រើប្រាស់គឺប្រកាសស្តីពីលក្ខខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្ម។ បន្ថែមពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការងាររៀបចំលិខិតបទដ្ឋានសំខាន់ៗមួយចំនួនទៀតដូចជា÷ (១).សេចក្តីព្រាងគោលនយោបាយស្តីពីពូជដំណាំកម្ពុជា (២).សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ (៣).ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈនៅក្នុងសកម្មភាពគ្រប់គ្រងពូជដំណាំ (៤).ប្រកាសស្តីពីស្លាកសញ្ញាព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ពូជដំណាំ (៥).ប្រកាសស្តីពីការសាកល្បងការយកសំណាក ការចាត់ថ្នាក់ ការកំណត់ស្តង់ដារគុណភាពពូជដំណាំ និងនីតិវិធីនៃការត្រួតពិនិត្យលើគុណភាពពូជដំណាំ (៦).ប្រកាសស្តីពីបែបបទនៃការពិន័យអន្តរការណ៍និងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តន៍ការពិន័យអន្តរការណ៍ (៧).ប្រកាសស្តីពីគំរូពាក្យស្នើសុំនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ (៨).សេចក្តីព្រាងប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងកម្ចាត់សមាសភាពចង្រៃ (៩).សេចក្តីព្រាងប្រកាសស្តីពីបញ្ជីរាយមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (១០).សេចក្តីព្រាងប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌ និង (១១).វិសោធនកម្មប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ។

## ខ. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកកៅស៊ូ

ក្រសួងដែលមានអគ្គនាយកដ្ឋានកៅស៊ូជាសេនាធិការ បាននិងកំពុងរៀបចំចងក្រងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូដែលបានចាប់ផ្តើមដំណើរការចាប់តាំងពីឆ្នាំ២០១០មករហូតដល់បច្ចុប្បន្ននេះ។ សេចក្តីព្រាងច្បាប់ត្រូវបានបញ្ចប់នៅត្រឹមថ្នាក់អគ្គនាយកដ្ឋានកៅស៊ូដែលរួមមាន ១១ជំពូក ៩២មាត្រា និងឧបសម្ព័ន្ធ១ ដែលបច្ចុប្បន្នកំពុងពិនិត្យពិភាក្សានៅក្រសួង។ ក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានកៅស៊ូ បានរៀបចំលិខិតបទដ្ឋានគតិយុត្តនានាដូចជា សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ និងសេចក្តីព្រាងប្រកាសស្តីពីការហាមឃាត់ការធ្វើចរាចរជ័រកៅស៊ូមិនទាន់កែច្នៃទៅបរទេស។

## គ. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកផលិតកម្ម និងបសុពេទ្យ

### គ.១. ការកសាងច្បាប់:

ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ មាន២២ជំពូក ១២៤មាត្រា ដែលមានសន្ទានុក្រមចំនួន៥៣ ត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ឡាយព្រះហស្ថលេខា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦។

**រូបថតអនុស្សាវរីយការពារច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វនៅព្រឹទ្ធសភា**



### គ.២. ការរៀបចំអនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផលិតកម្មនិងបសុព្យាបាលៈ

សេចក្តីព្រាងអនុក្រឹត្យស្តីពីការងារដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វត្រូវបានរៀបចំរួច។ ជាមួយគ្នានេះដែរ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វក៏ត្រូវបានរៀបចំនិងកែសម្រួល។ សេចក្តីព្រាងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានរៀបចំហើយ និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យផ្តល់យោបល់។ ជាមួយនោះបានរៀបចំសេចក្តីណែនាំជាច្រើន ក្នុងនោះមានសេចក្តីណែនាំស្តីពីការប្រើប្រាស់ត្រាសម្រាប់បោះសម្គាល់លើផ្ទាំងសាច់។

### គ.៣. ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពសុខភាពសត្វ និងផលិតកម្មសត្វៈ

គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានបញ្ជូនមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យនិងចុះហត្ថលេខា ក្រោយពេលដែលឯកសារនេះ ត្រូវបានធ្វើការប្រជុំពិភាក្សាជាច្រើនលើករួចមកហើយ។ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រលុបបំបាត់ជំងឺឆ្កែឆ្កួតនៅកម្ពុជាឆ្នាំ២០២០ ក៏ត្រូវបានរៀបចំផងដែរ។

### ឃ.ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលទំហំតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតដើម្បីគាំទ្រដល់កម្មវិធីកំណែទម្រង់វិស័យព្រៃឈើ។

### ៦.៣. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចយ៉ាងសកម្ម និងយកចិត្តទុកដាក់ជាសំខាន់ក្នុងការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើនចំណូលនិងវិចារណកម្មនៃចំណាយ ដើម្បីចូលរួមអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលដៅពង្រឹងនិងពង្រីកសេវាសាធារណៈ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

តាមរយៈការអនុវត្តថវិកាកម្មវិធីពេញលេញ ក្រសួងបានចំណាយថវិកាឆ្នាំ២០១៥ មានទឹកប្រាក់សរុបចំនួន ១៤៩.៤៣៧.៥២៧.៧៤៨រៀល ស្មើនឹង៩៩,៤៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ក្នុងនោះ (១) រដ្ឋបាលកណ្តាលអនុវត្តបានចំនួន១០៥.៩៨៨.២០៧.៧៧១រៀល ស្មើនឹង១០០% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ (២) មន្ទីររាជធានីខេត្តអនុវត្តបានចំនួន ៤៣.៤៤៩.៣១៩.៩៧៧រៀល ស្មើនឹង៩៨,៦៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥។ ជាទូទៅការអនុវត្តចំណាយថវិកាកម្មវិធីពេញលេញឆ្នាំ២០១៥ មានសមាមាត្រស្របតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយសារមានការចង្អុលបង្ហាញនិងមានអន្តរាគមន៍ទាន់ពេលវេលាអំពីនីតិវិធីចំណាយជូនដល់បណ្តាអង្គភាពថវិកាថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន (មន្ទីរកសិកម្មរាជធានីខេត្ត)។ ដោយឡែកការអនុវត្តចំណាយថវិកាជំពូកផ្សេងៗ ដែលទាបជាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយសារការសន្សំថវិកាពីការធ្វើលទ្ធកម្ម និងមានចង្កោមសកម្មភាពខ្លះក្នុងអនុកម្មវិធីនៃអង្គភាពថវិកា អនុវត្តមិនទាន់រដូវកាលតាមការគ្រោងទុក។

ការអនុវត្តប្រមូលចំណូលឆ្នាំ២០១៥ សម្រេចបានសរុបចំនួន៥០.៧៥៩.៧០៩.៥១២រៀល ស្មើនឹង៨៦,៥៨% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ (១).រដ្ឋបាលកណ្តាលអនុវត្តបានចំនួន៤៨.៣៨៨.៤៣៧.៧២២រៀល ស្មើនឹង៨៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (២).មន្ទីរកសិកម្មរាជធានីខេត្ត អនុវត្តបានចំនួន២.៣៧១.២៧១.៧៩០រៀល ស្មើនឹង១៣៧,៥៩% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ការអនុវត្តចំណូលនៅថ្នាក់កណ្តាលទាបជាងច្បាប់ហិរញ្ញវត្ថុ ដោយសារការធ្លាក់ចុះនៃការធ្វើសម្បទានព្រៃឈើ ប៉ុន្តែមានការកើនឡើងគួរកត់សម្គាល់អំពីផលចំណូលពីការបង់ចំណូលពីបណ្តាក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច និងផលពីការគ្រប់គ្រងរដ្ឋបាល។

### ៦.៤. ការងារសហប្រតិបត្តិការអន្តរជាតិ

#### ក. លទ្ធផលនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលសិទ្ធិប្រទានពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានលើកទី៣៧ ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀតនៅទីក្រុងម៉ាកាទីនៃសាធារណរដ្ឋហ្វីលីពីន ដោយបានអនុម័តឯកសារមួយចំនួនដូចខាងក្រោម÷

- **ឯកសារដែលបានអនុម័ត ÷**
  1. សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
  2. គោលការណ៍ណែនាំស្តីពីភូតគាមអនាម័យសម្រាប់នាំចូលផ្លែធូរេននិងគ្រាប់កាហ្វេ ដើម្បីប្រើប្រាស់នៅក្នុងបណ្តាប្រទេសអាស៊ាន
  3. កម្រិតអតិបរមានៃកាកសំណល់ថ្នាំកសិកម្មចំនួន ០៥ ប្រភេទ
  4. ស្តង់ដារអាស៊ានសម្រាប់ផ្លែស្រកានាគ (Dragon Fruit) ស្ពៃខ្មៅ (Green Mustard) ស្ពៃស្ពីណេត (Spinach) ត្រកួន (Water Convolvulus) ស្ពៃបូកគោ (Chinese Cabbage) និងផ្សិតខ្មៅ (Fresh Shiitake Mushroom)

៥. នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងចរាចរណ៍វារីជាតិរស់ (Live Aquatic) នៅអាស៊ាន
៦. គំរូតារាងស្តីពីការរៀបចំឲ្យមានសមភាពនៃការត្រួតពិនិត្យផលិតផលជលផលនិងប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ
៧. គោលការណ៍ណែនាំរបស់អាស៊ានសម្រាប់ការទប់ស្កាត់លំហូរនៃត្រី និងផលិតផលនេសាទពីសកម្មភាពនេសាទល្មើសច្បាប់ចូលក្នុងខ្សែចង្វាក់ផ្គត់ផ្គង់
៨. ចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានស្តីពីស្បៀង កសិកម្ម និងព្រៃឈើ ឆ្នាំ២០១៦-២០២៥។

○ **ឯកសារដែលទទួលបានសិទ្ធិប្រទានដើម្បីចុះហត្ថលេខា ÷**

កិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់សុខភាពសត្វនិងជំងឺស្ញូណូស។

○ **គម្រោងកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន ÷**

គម្រោង "ការពង្រឹងសមត្ថភាពលើវិស័យកសិកម្មក្នុងប្រទេសសមាជិកអាស៊ាន" ដំណាក់កាលទី២ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ដែលឧបត្ថម្ភថវិកាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃប្រទេសជប៉ុន។

○ **ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារជំនាញអាស៊ាន ÷**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល បានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារជំនាញបច្ចេកទេសអាស៊ានចំនួន៣ នៅឆ្នាំ២០១៥ ដូចខាងក្រោម ÷

១. សិក្ខាសាលាស្តីពីកម្រិតកាកសំណល់ជាតិពុល និងកិច្ចប្រជុំលើកទី១៥នៃក្រុមការងារជំនាញស្តីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុលនៃថ្នាំពុលកសិកម្ម។
២. កិច្ចប្រជុំលើកទី៦ របស់ក្រុមការងារជំនាញស្តីពីការអនុវត្តកសិកម្មល្អ។
៣. កិច្ចប្រជុំរបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍សហគមន៍កសិកម្មលើកទី២២ និងកិច្ចប្រជុំលើកទី១៧ របស់ក្រុមការងារបច្ចេកទេសអាស៊ានស្តីពីសហគមន៍កសិកម្ម។

## ខ. លទ្ធផលនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងជាមួយអង្គការអន្តរជាតិ

នៅក្នុងអំឡុងឆ្នាំ២០១៥-២០១៦នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបពិភាក្សា ចរចារពិគ្រោះយោបល់ និងសម្របសម្រួលជាមួយប្រទេស ស្ថាប័ននានា សហគមន៍ផ្តល់ជំនួយក្នុងលក្ខណៈជាទ្វេភាគី និងពហុភាគីព្រមទាំងជាមួយអង្គការអន្តរជាតិនានា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍបច្ចេកទេស វិទ្យាសាស្ត្រស្រាវជ្រាវ និងបានចុះហត្ថលេខាលើអនុស្សរណៈ និងកិច្ចព្រមព្រៀងដូចខាងក្រោម ÷

○ **ចុះហត្ថលេខាលើអនុស្សរណៈ ឯកសារគម្រោង និងកិច្ចព្រមព្រៀងគម្រោង ÷**

**១. ចុះហត្ថលេខាលើអនុស្សរណៈ ÷**

| ល.រ | អនុស្សរណៈ ពិធីសារ កិច្ចព្រមព្រៀង ផែនការសកម្មភាព | ជាមួយ | កាលបរិច្ឆេទចុះហត្ថលេខា |
|---|---|---|---|
| ១ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មនិងកសិពាណិជ្ជកម្ម។ | សាធារណរដ្ឋហ្វីលីពីន | ១០ កញ្ញា ២០១៥ |
| ២ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកៅស៊ូធម្មជាតិ។ | សាធារណរដ្ឋប្រជាមានិតចិន | ១៥ តុលា ២០១៥ |
| ៣ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការនាំចេញផ្លែស្វាយស្រស់ពីព្រះរាជាណាចក្រកម្ពុជាទៅសាធារណរដ្ឋកូរ៉េ។ | សាធារណរដ្ឋកូរ៉េ | ០៨ ធ្នូ ២០១៥ |

## ២. គម្រោងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ៖

| ល.រ | ឈ្មោះគម្រោង | ប្រទេសផ្តល់ថវិកា | កាលបរិច្ឆេទចុះហត្ថលេខា | ថវិកាសរុប |
|---|---|---|---|---|
| ១ | Project on Reserch and Development of Vaccines for Cattle and Buffalo | Korea International Cooperation Agency (KOICA) | 08. 06. ២០១៥ | 4,4 million USD |
| ២ | Rice Seed Production and Distribution Project | ODA, Japan | N/A | N/A |
| ៣ | CAM-REED II Project for Facilitating the implementation of REEDD+ Strategy and Policy, Phase II (FA) | ODA, Japan | N/A | N/A |

## គ. ការងារសហប្រតិបត្តិការអន្តរជាតិផ្នែកអភិវឌ្ឍន៍កៅស៊ូ

### គ.១ សមាគមប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)

ព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលជាសមាជិកពេញសិទ្ធិក្នុងសមាគមប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ហើយកម្ពុជាក៏ជាប្រធានសមាគម ANRPC សម្រាប់ឆ្នាំ២០១៥-២០១៦នេះផងដែរ។ ឆ្នាំ២០១៥នេះ ព្រះរាជាណាចក្រកម្ពុជា បានធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៥ របស់សមាគមប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) ដែលបានប្រព្រឹត្តទៅអស់រយៈពេល៦ថ្ងៃ គឺចាប់ពីថ្ងៃទី១៩ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា ដោយមានអ្នកចូលរួមប្រមាណជាង៣០០នាក់ រួមមានៈ អ្នកដាំដុះ អ្នកកែច្នៃ ពាណិជ្ជ សេដ្ឋវិទូ និងកម្មន្តសាលករទាំងក្នុងស្រុកនិងក្រៅស្រុក។ សន្និសីទ កិច្ចប្រជុំ និងសន្និបាតឆ្នាំ២០១៥របស់ ANRPC បានប្រព្រឹត្តិទៅប្រកបដោយភាពជោគជ័យ អាស្រ័យដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងមានការចូលរួមគាំទ្រយ៉ាងសកម្មពីបណ្តាប្រទេសជាសមាជិកពីលេខាធិការដ្ឋាន ANRPC និងពីប្រតិបត្តិករកៅស៊ូនានា។

ក្រៅពីនេះ (១).បានចូលរួមសិក្ខាសាលានៅប្រទេសថៃ រយៈពេលបួនថ្ងៃចាប់ពីថ្ងៃទី២៧ ខែមេសា ដល់ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំម៉ូឌែលស្ថិតិផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ (supply-demand statistics modeling) (២).ចូលរួមប្រជុំANRPC កម្រិតថ្នាក់រដ្ឋមន្ត្រីរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងគូឡាឡាំពួនៃប្រទេសម៉ាឡេស៊ី (៣).ចូលរួមជាមួយអ្នកសេដ្ឋកិច្ច ANRPC ទៅចុះស្រង់ព័ត៌មានពីទម្រង់កៅស៊ូកសិឧស្សាហកម្មនិងកៅស៊ូគ្រួសារកម្ពុជា (៤).ចូលរួមកិច្ចប្រជុំបឋមនៃគណៈកម្មាធិការព័ត៌មាននិងស្ថិតិ និងគណៈកម្មាធិការបញ្ហាឧស្សាហកម្មរបស់ ANRPC រយៈពេល២ថ្ងៃ គឺចាប់ពីថ្ងៃទី៣-៤ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី និង (៥).ចូលរួមសិក្ខាសាលារបស់ ANRPC នៅប្រទេសសិង្ហបុរី រយៈពេលបីថ្ងៃចាប់ពីថ្ងៃទី១៤-១៦ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំម៉ូឌែលស្ថិតិផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិនិងកិច្ច ប្រជុំក្រុមជំនាញផ្នែកស្ថិរភាព នីយកម្មតម្លៃកៅស៊ូពិភពលោក។

### គ.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB: International Rubber Research and Development Board )

ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិ ស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ ដែលមាន៩៥%នៃបរិមាណផលិតផលកៅស៊ូធម្មជាតិ នៅក្នុងពិភពលោកបានកើតឡើងតាំងពីឆ្នាំ១៩៣៤។ កម្ពុជាបានចូលជាសមាជិកទី១៦នៃក្រុមប្រឹក្សា

ស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០០១ នៅទីក្រុង Montpellier នៃសាធារណរដ្ឋបារាំង។ សន្និសិទកៅស៊ូអន្តរជាតិនិងកិច្ចប្រជុំប្រចាំឆ្នាំ២០១៥ បានប្រព្រឹត្តទៅនៅថ្ងៃទី០២-០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងហូជីមិញនៃប្រទេសវៀតណាម។ ក្រៅពីនេះ បានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ សិក្ខាសាលា និងការបណ្តុះបណ្តាល ដែលរៀបចំដោយ IRRDB ចំនួន៧លើក ទទួលបានក្លូនកៅស៊ូចំនួន១០ និងបានបញ្ជូនក្លូន (CMS) ចំនួន៥ទៅវិញ។ ប្រទេសកម្ពុជាទទួលវេនជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំប្រចាំឆ្នាំ IRRDB ជាលើកទី២ ដែលគ្រោងធ្វើនៅថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦។

**គ.៣ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD: Agence Française de Développement)**

បានបន្តអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា ដែលបានបង្កើតតាមអនុសញ្ញាហិរញ្ញប្បទាន CKH 1123 01 H ចុះហត្ថលេខាកាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ រវាងព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ដែលមានរយៈពេល៣ឆ្នាំ (២០១៣-២០១៥) និងទឹកប្រាក់ចំនួន**២.៦៨៨.០០០អឺរ៉ូ** ក្នុងគោលបំណងកែលម្អផលិតភាពនៃដំណាំកៅស៊ូនៅកម្ពុជា តាមរយៈការជំនួសច្បារពូជមិនត្រឹមត្រូវប្រមាណជាង៧០ហ.ត និងរៀបចំរុក្ខសម្ភារដោយមានការបញ្ជាក់ត្រឹមត្រូវ។ សកម្មភាពគម្រោងដែលត្រូវអនុវត្តរួមមាន÷ (១).ការធ្វើបញ្ជីសារពើភ័ណ្ឌច្បារពូជកៅស៊ូនៅទូទាំងប្រទេស (២).ការបង្កើតច្បារពូជនិងថ្នាលកូនកៅស៊ូសម្រាប់ជួសកូនកៅស៊ូក្នុងច្បារពូជណាដែលមិនត្រឹមត្រូវ (៣).ការធ្វើវិភាគ ADN ទៅលើច្បារពូជ (៤).យុទ្ធនាការនៃការជួសកូនកៅស៊ូក្នុងច្បារពូជ និង (៥).ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃច្បារពូជ។ ក្នុងឆ្នាំ២០១៥ ដែលជាឆ្នាំបញ្ចប់នៃគម្រោងនេះ ក្រុមការងារអនុវត្តគម្រោងបានបញ្ចប់ការចុះធ្វើសារពើភណ្ឌលើច្បារពូជកៅស៊ូគ្រួសារឯកជន និងច្បារពូជកៅស៊ូកសិឧស្សាហកម្មសរុបបានចំនួន១២៨ច្បារពូជ ស្មើនឹងផ្ទៃដីទំហំ១២០ហិកតា ក្នុងខេត្តចំនួន១១ និងសំណាកដែលត្រូវយកទៅវិភាគមានចំនួន៤.១៨៣សំណាក។

**គ.៤ កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ**

ក្នុងការសិក្សានិងស្រាវជ្រាវអំពីក្សេត្របរិស្ថានដំណាំកៅស៊ូ បានសហប្រតិបត្តការជាមួយសាកលវិទ្យាល័យអន្តរជាតិរួមមាន÷ (១).ចូលរួមសហកាជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya នៃប្រទេសជប៉ុនក្នុងការថែទាំនិងជួសជុលឧបករណ៍ Sap flow, $CO_2$ profile នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (២).សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kuyshu ដើម្បីស្រាវជ្រាវអំពី leafphotosynthesis និង (៣).សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Hawaii សហរដ្ឋអាមេរិកដើម្បីថែទាំនិងជួសជុលឧបករណ៍ Flux Tower នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**គ.៥ កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន**

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកប្រទេសចិន (CATAS) បានចុះកិច្ចព្រមព្រៀងកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ក្នុងការធ្វើសហប្រតិបត្តិការស្រាវជ្រាវកៅស៊ូ។ ផ្អែកលើកិច្ចព្រមព្រៀងនេះ គណៈប្រតិភូ CATAS បានអញ្ជើញមកធ្វើទស្សនកិច្ចរយៈពេល៥ថ្ងៃគឺថ្ងៃទី១៧-២១ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីស្វែងយល់ពីដំណើរការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូនៅកម្ពុជា។ ប៉ុន្តែមកទល់ពេលនេះ ពុំទាន់មានដំណើរវិវត្តន៍នៅឡើយ ដោយភាគីចិនកំពុងស្ថិតក្នុងដំណាក់កាលស្វែងរកថវិកាសម្រាប់អនុវត្តគម្រោង។

ភាគីចិនបានឯកភាពលើសេចក្តីព្រាងដែលភាគីកម្ពុជាបានផ្ញើជូន ហើយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ អនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ ត្រូវបានចុះហត្ថលេខាផ្លូវការដោយភាគីទាំងពីរក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងប៉េកាំងប្រទេសចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ**

**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Xi Jinping ប្រធានាធិបតីចិន។

**គ.៦ ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម**

សេចក្តីព្រាងរបាយការណ៍ស្តីពីផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម បានធ្វើការប្រជុំពិនិត្យ ពិភាក្សា កែសម្រួលជាច្រើនលើកច្រើនសារ ទាំងនៅអគ្គនាយកដ្ឋានកៅស៊ូ ក៏ដូចនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចុងក្រោយបានពិភាក្សាបញ្ចប់ជាមួយភាគីវៀតណាមនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ដោយបានកែសម្រួល និងបានផ្ញើរជូនលេខាធិការដ្ឋាន CLV នៃក្រសួងពាណិជ្ជកម្ម ដើម្បីអនុវត្តបន្តតាមនីតិវិធី។

ក្រៅពីកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា ក៏បានចូលជាសមាជិកពេញសិទ្ធិនៃ IRA និង ARBC... ផងដែរ។

**ឃ. កិច្ចសហប្រតិបត្តិការផ្នែកផលិតកម្មនិងបសុពេទ្យបាល**

ក្នុងកិច្ចការសហប្រតិបត្តិការអន្តរជាតិលើផ្នែកនេះ ក្រសួងមានកិច្ចសហការយ៉ាងទូលំទូលាយជាលក្ខណៈទ្វេរភាគីៈ ថៃ វៀតណាម សាធារណរដ្ឋប្រជាមានិតចិន កូរ៉េ អូស្ត្រាលី អាហ្សង់ទីន លក្ខណៈពហុភាគីៈ អាស៊ាន អង្គការអន្តរជាតិនានា ដូចជាFAO, OIE, WTO, WHO, EU, JICA, ACIAR, IAEA, KOICA, ADB, WB, USAID, AUAID,។ល។

**ង. កិច្ចសហប្រតិបត្តិការផ្នែកព្រៃឈើ**

- បាននិងកំពុងអនុវត្តគម្រោងគាំទ្រដល់កម្មវិធីព្រៃឈើជាតិជាមួយដៃគូអភិវឌ្ឍន៍ចំនួន១៩ លើគម្រោងចំនួន៤៨ ជាមួយអង្គការមិនមែនរដ្ឋាភិបាលមានចំនួន១៦ លើគម្រោងចំនួន៣៩ និងរាជរដ្ឋាភិបាលកម្ពុជាមានចំនួន៩គម្រោង
- បានរៀបចំសន្និសីទជាតិស្តីពីជីវៈចម្រុះព្រៃឈើ និងការអភិរក្សកាបូនស្តុកក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងបានរៀបចំសិក្ខាសាលាដាក់ឲ្យដំណើរការអនុវត្តគម្រោង ITTO លេខ PD740/14 REV.2(F) "ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេដបូកក្នុងខេត្តកំពង់ធំ"
- បានចុះកិច្ចព្រមព្រៀងជាមួយមូលនិធិបរិស្ថាន AEON (JAPAN) លើការជំរុញការអភិវឌ្ឍ និងការដាំឈើឡើងវិញសម្រាប់ឆ្នាំ២០១៥-២០១៩ ដែលមានទឹកប្រាក់សរុប ១២៣.៧៧២USD។

**ច. កិច្ចសហប្រតិបត្តិជាមួយដៃគូអភិវឌ្ឍន៍នានា**

**១. គម្រោង Cambodia Agricultural Value Chain Program-CAVAC**

កម្មវិធីខ្សែសង្វាក់តម្លៃសិកម្មកម្ពុជា (CAVAC) ក្រោមការគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី ដែលមានថវិកាសរុបប្រមាណ៥៧,២១លានដុល្លាអូស្ត្រាលី ក្នុងរយៈពេល៦ឆ្នាំ គឺពីឆ្នាំ២០១០-២០១៥ នៅក្នុងខេត្តចំនួន៣មានខេត្ត÷ តាកែវ កំពត និងកំពង់ធំ លើសមាសភាគ÷ ១).កសិពាណិជ្ជកម្មនិងប្រព័ន្ធព័ត៌មាន ២).ការគ្រប់គ្រងប្រព័ន្ធស្រោចស្រពនិងធនធានទឹក និង ៣).ការស្រាវជ្រាវដោយមានគោលដៅជួយពន្លឿនការលូតលាស់ក្នុងតម្លៃផលិតផលកសិកម្ម និងប្រាក់ចំណូលដល់កសិករខ្នាតតូចនៅក្នុងប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅក្នុងខេត្តគោលដៅ។

(១). ផ្នែកកសិពាណិជ្ជកម្មនិងប្រព័ន្ធព័ត៌មាន ផ្តោតលើការបង្កើតនិងពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន (Public Private Partnership) ក្នុងការអន្តរាគមន៍នូវបច្ចេកវិទ្យា បច្ចេកទេសថ្មីៗ ព្រមទាំងទីផ្សារ សម្ភារកសិកម្ម ព័ត៌មាននិងសេវាដល់កសិករ និងសហគមន៍កសិកម្មដោយមានកសិករចំនួន២១៤.០០០ គ្រួសារទទួលផលផ្ទាល់ និងចំនួន៣៤០.០០០គ្រួសារទទួលផលមិនផ្ទាល់បើគិតរហូតដល់ឆ្នាំ២០១៧ តាមរយៈការបណ្តុះបណ្តាលផ្សព្វផ្សាយ បច្ចេក-ទេស និងការប្រើប្រាស់ពូជ ជី និងថ្នាំកសិកម្មត្រឹមត្រូវ។ មានកសិករចំនួន២.០០០គ្រួសារ ទទួលផលប្រយោជន៍ពីទីផ្សារនាំ

អង្គុរចេញ។ មានកសិករប្រមាណ២០០.០០០គ្រួសារ បានទទួលព័ត៌មានបច្ចេកទេសកសិកម្មថ្មី និងបានអនុវត្តបច្ចេកទេសកសិកម្មថ្មី តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

(២). ការគ្រប់គ្រងប្រព័ន្ធស្រោចស្រពនិងធនធានទឹក គឺផ្តោតលើការស្តារនិងកសាងប្រព័ន្ធស្រោចស្រព÷ ក្នុងរយៈពេលពីឆ្នាំ២០១០-២០១៥ ដោយបានស្តារនិងកសាងប្រឡាយស្រោចស្រពចំនួន២០ប្រព័ន្ធ មាន៧ប្រព័ន្ធនៅខេត្តតាកែវ ៩ប្រព័ន្ធនៅខេត្តកំពត និង៤ប្រព័ន្ធនៅខេត្តកំពង់ធំ ដែលអាចឲ្យកសិករប្រមាណ១៩.០០០គ្រួសារ បង្កបង្កើនផលយ៉ាងតិចចំនួន២ដងក្នុងមួយឆ្នាំ។ ប្រព័ន្ធស្រោចស្រពទាំងនេះមានសក្តានុពលស្រោចស្រពសរុបដល់២២.៥៦១ហិកតា និងនៅរដូវវស្សាឆ្នាំ២០១៥នេះ មានផ្ទៃដីស្រោចស្រពជាក់ស្តែងចំនួន១៩.១២៨ហិកតា។

(៣). ផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយ÷ កិច្ចសហការជាមួយអគ្គនាយកដ្ឋានកសិកម្មនិងមន្ទីរកសិកម្មខេត្តលើសកម្មភាពសិក្សាស្រាវជ្រាវពូជស្រូវ ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការរៀបចំសហគមន៍កសិកម្ម ការចូលរួមរៀបចំឯកសារគោលនយោបាយ និងជំរឿនកសិកម្ម និងឯកសារផ្សព្វផ្សាយកសិកម្ម។ បានបង្កើតនិងកសាងសមត្ថភាពសហគមន៍កសិកម្មចំនួន៦២ មានសមាជិកសរុប៣.៧៣២នាក់ និងបានបណ្តុះបណ្តាលនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដល់កសិករចំនួន ៤៩.៨៤៨គ្រួសារ។

កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC) ជាកម្មវិធីកសិកម្មដ៏សំខាន់មួយរបស់អូស្ត្រាលី ដែលជួយកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយការបង្កើនផលិតភាពនិងប្រាក់ចំណូលដល់កសិករខ្នាតតូច។ ឆ្នាំ២០១៥ កម្មវិធី CAVAC បានកែលម្អបច្ចេកទេសកសិកម្មរបស់កសិករចំនួន២១៤.០០០គ្រួសារ។ មានកសិករជាង១៩.០០០គ្រួសារ អាចបង្កបង្កើនផល យ៉ាងតិចចំនួន២ដងក្នុងមួយឆ្នាំ ដោយបង្កើតបរិមាណផលស្រូវប្រមាណជាង២០០.០០០តោន ដែលគិតជាប្រាក់ប្រមាណ៤៣លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

**២.គម្រោងកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននៃអនុវិស័យជលផលនិងផលិតកម្មសត្វ**

សហភាពអឺរ៉ុបបានគាំទ្រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមឲ្យសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់វិស័យកសិកម្ម។ ដើម្បីធានាបាននូវការរីកចម្រើនរបស់វិស័យកសិកម្មក្នុងការសម្រេចបានប្រកបដោយសមភាពមានរួមបញ្ចូលទាំងការទទួលខុសត្រូវលើនិរន្តរភាពបរិស្ថានសម្រាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជា។

- ឈ្មោះកម្មវិធី: កម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន: អនុវិស័យជលផល និងផលិតកម្មសត្វ
- ភ្នាក់ងារអនុវត្ត: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លេខកូដគម្រោង: DCI-ASIE/2012/023-197
- ថវិកាសរុប : EUR 26,000,000
- ថ្ងៃខែឆ្នាំចាប់ផ្តើម: ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៤
- ថ្ងៃខែឆ្នាំបញ្ចប់: ថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ២០១៨

**គោលបំណងកម្មវិធី**

"ដើម្បីជំរុញកំណើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពនៃអនុវិស័យជលផល និងផលិតកម្មសត្វ តាមរយៈការគាំទ្រដោយរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ស្របតាមគោលការណ៍អភិក្រមគ្របដណ្តប់នៃកម្មវិធី"

**សង្ខេបលទ្ធផលសម្រេចបាន÷**

- **ការគាំទ្រគោលនយោបាយវិស័យកសិកម្ម**
  - គំនិតផ្តួចផ្តើមធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ២០១៤-២០១៨ បានបញ្ចប់
  - អភិក្រមគ្របដណ្តប់នៃកម្មវិធីសម្រាប់វិស័យកសិកម្ម រង់ចាំការអនុម័តឯកសារពីសហភាពអឺរ៉ុប

- គោលនយោបាយយេនឌ័រ និងគោលនយោបាយអភិវឌ្ឍន៍និងការពារកុមារ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៥-២០១៨ បានបញ្ចប់
- ការរៀបចំគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស និងការវាយតម្លៃសមត្ថភាពមន្ត្រីកំពុងចាប់ផ្តើម និងដំណើរការ
- វគ្គបណ្តុះបណ្តាលអំពីកម្មវិធីចំណាយប្រតិបត្តិការ ការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាពបានបញ្ចប់។ វគ្គកុំព្យូទ័រ ភាសាអង់គ្លេស កំពុងដំណើរការ និងបញ្ចប់ក្នុងឆ្នាំ២០១៦
- ការវាយតម្លៃលើការអភិវឌ្ឍន៍កម្មវិធីសិក្សាកសិកម្មបានចាប់ផ្តើមនៅសាលាកសិកម្មព្រែកលៀប និងកំពង់ចាម
- គម្រោងផ្តល់ហិរញ្ញប្បទានឥតសំណងដល់អង្គការសង្គមស៊ីវិលនានា កំពុងដំណើរការ(ដាក់ជូនទទួលគម្រោង ស្នើសុំ)
- ការសិក្សាអំពីបទពិសោធន៍លើផលិតកម្មតាមកិច្ចសន្យា និងផលិតគោលការណ៍ណែនាំសម្រាប់ផលិតកម្មតាមកិច្ចសន្យាកំពុងរង់ចាំការអនុម័តឯកសារពីសហភាពអឺរ៉ុប ការគាំទ្រកិច្ចប្រតិបត្តិការនៃក្រុមការងារបច្ចេកទេសកសិកម្មនិងទឹកកិច្ចប្រជុំចំនួន៥បានរៀបចំឡើង និងបានជ្រើសរើសលេខាធិការនៃក្រុមការងារនេះរួចហើយ។

- **ការគាំទ្រអនុវិស័យជលផល**
    - អង្គការសហគមន៍នេសាទត្រូវបានពង្រឹង
    - គាំទ្រដើម្បីផលិតឲ្យមានសមមាត្រនិងសមត្ថភាពនៃការបន្តពូជ កំពុងដំណើរការ
    - កែលម្អសមត្ថភាពនៃការផ្សព្វផ្សាយ ការតាមដាន ការត្រួតពិនិត្យ និងឃ្លាំមើល កំពុងដំណើរការ
    - សកម្មភាពស្រាវជ្រាវ ការគាំទ្រប្រកបដោយចីរភាពនូវមច្ឆាជាតិនៅក្នុងស្រែ បានបញ្ចប់
    - ការអភិវឌ្ឍន៍ជីវភាពរស់នៅ កំពុងដំណើរការ
    - ការទទួលយកនូវការទទួលខុសត្រូវលើនិរន្តភាពនិងបរិស្ថាន លើការអនុវត្តជលវប្បកម្ម កំពុងដំណើរការ
    - ការវិនិយោគលើការផ្តល់ចំណីជលវប្បកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃការផ្គត់ផ្គង់ពូជ កំពុងដំណើរការ
    - ការគាំទ្រអ្នកអនុវត្តខ្នាតតូច ខ្នាតមធ្យម ទៅតាមសង្វាក់ផលិតកម្មផ្សេងៗ បានបញ្ចប់
    - ការផ្តោតលើការធ្វើផែនការ ការត្រួតពិនិត្យ ការគ្រប់គ្រងហិរញ្ញវត្ថុនិងថវិកា ការត្រួតពិនិត្យ ប្រព័ន្ធផ្ទៃក្នុង និងវិមជ្ឈការ និងវិសហមជ្ឈការ បានបញ្ចប់
    - គាំទ្រលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសជលផល បានបញ្ចប់។
- **ការគាំទ្រអនុវិស័យផលិតកម្មសត្វ**
    - ពង្រឹងសមត្ថភាពគ្រប់គ្រង និងការអនុវត្តរបស់មន្ត្រីកំពុងដំណើរការ
    - ពង្រឹងសមត្ថភាពក្នុងការកសាងផែនការយុទ្ធសាស្ត្រកំពុងដំណើរការ
    - ពង្រឹងសេវាកម្មបសុពេទ្យស្របតាមអង្គការសុខភាពសត្វពិភពលោកកំពុងដំណើរការ
    - គាំទ្រក្នុងការបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិសម្រាប់កម្មវិធីអប់រំផ្នែកផលិតកម្មសត្វនិងបសុព្យាបាលបានបញ្ចប់
    - ពង្រឹងត្រួតពិនិត្យ និងធ្វើរបាយការណ៍ជម្ងឺសត្វ បានបញ្ចប់
    - គាំទ្រសកម្មភាពមូលដ្ឋានរបស់ភ្នាក់ងារសុខភាពសត្វភូមិ កំពុងដំណើរការ
    - គាំទ្រសកម្មភាពបង្កាត់ពូជជ្រូកតាមបច្ចេកទេសសិប្បនិមិត្ត កំពុងដំណើរការ
    - គាំទ្រសកម្មភាពបង្កាត់ពូជគោតាមបច្ចេកទេសសិប្បនិមិត្ត កំពុងដំណើរការ
    - គាំទ្រដល់ការផលិតចំណីសត្វនៅតាមភូមិ បានបញ្ចប់។

## ៣. គម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ជាកម្មវិធីជាតិមួយមានគោលបំណងកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារកសិករក្រីក្រ និងងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីនេះមានគោលដៅលើកកម្ពស់គំរូសេវាកសិកម្មដែលបានបង្កើតឡើង និងត្រូវអនុវត្តដល់ឆ្នាំ២០២១ សម្រាប់ជួយកសិករខ្នាតតូចទូទៅ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច តាមរយៈបង្កើនប្រាក់ចំណូលនិងភាពធន់ក្នុងមុខរបរកសិកម្ម។

កម្មវិធី ASPIRE មានសមាសភាពសំខាន់ចំនួន៤គឺ÷

- ផ្នែកគោលនយោបាយផ្សព្វផ្សាយមួយមានការជឿជាក់បាន
- ផ្នែកអភិវឌ្ឍន៍សមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម
- ការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម និង
- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ភាពធន់នឹងអាកាសធាតុលើមុខរបរកសិកម្ម។

**ក.** ផ្នែកគោលនយោបាយផ្សព្វផ្សាយមួយមានការជឿជាក់បាន មានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យនូវឯកសារគោលនយោបាយនានា ផែនការយុទ្ធសាស្ត្រ កម្មវិធី គម្រោង និងរបាយការណ៍នានាពាក់ព័ន្ធនឹងការផ្សព្វផ្សាយកសិកម្ម ដើម្បីកំណត់ប្រធានបទសិក្សា។ ជាលទ្ធផលប្រធានសិក្សាគោលនយោបាយចំនួន២ ត្រូវបានកំណត់និងជ្រើសរើសរួមមាន (១). ការសិក្សាប្រៀបធៀបគោលនយោបាយផ្សព្វផ្សាយកសិកម្មរវាងប្រទេសកម្ពុជា វៀតណាម និងប្រទេសថៃ និង (២). សិក្សាពិនិត្យប្រព័ន្ធថវិកាតាមកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគាំទ្រដល់សេវាផ្សព្វផ្សាយកសិកម្ម។

**ខ.** ផ្នែកអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្មនៃកម្មវិធី ASPIRE គឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្មដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ក្រោមជាតិនិងមូលដ្ឋាន តាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្មនិងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ផ្សព្វផ្សាយកសិកម្ម។ លទ្ធផលដែលទទួលបានមានដូចខាងក្រោម÷

– បានរៀបចំលិខិតបទដ្ឋាន និងតួនាទីភារកិច្ច សម្រាប់រៀបចំយន្តការគាំទ្រ សម្របសម្រួលការងារផ្សព្វផ្សាយកសិកម្មទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមាន÷ គណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្ម អនុគណៈកម្មាធិការបច្ចេកវិទ្យាថ្នាក់ជាតិ ក្រុមផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្មខេត្ត និងក្រុមគាំទ្របច្ចេកថ្នាក់ស្រុក
– បានរៀបចំគោលការណ៍ណែនាំស្ដីពីការវាយតម្លៃតម្រូវការកសិករ សាលារៀនស្រែកសិករ និងការបង្កើតក្រុមសិក្សាខ្នាតតូចសម្រាប់រៀបចំក្រុមកសិករសិក្សា និងអនុវត្តសកម្មភាពផ្សព្វផ្សាយនៅមូលដ្ឋានមានៈ សាលារៀនស្រែកសិករ ការធ្វើបង្ហាញបច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តល្អថ្មីៗ (Innovation) **និ**វាស្រែទស្សនៈកិច្ចសិក្សា និងការចងក្រងក្រុមជួយខ្លួនឯង។ល។ និងកំណត់តម្រូវការសំខាន់ៗនូវបច្ចេកវិទ្យា បច្ចេកទេស និងនវានុវត្តន៍ថ្មីៗ ដែលជាការអនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ÷ ពូជធន់ទ្រាំ (Stress Tolerant Varieties-STV), គំរូកសិកម្ម ចំរុះ (Model farming) ការគ្រប់គ្រងដំណាំ (Crop management) និងប្រព័ន្ធប្រតិទិនដាំដុះដំណាំ (Cropping Calendar) និងប្រធានបទដំណាំស្រូវ បន្លែ មាន់ ជ្រូក និងវារីវប្បកម្ម។

**គ.** ផ្នែកកែលម្អសេវាផ្សព្វផ្សាយកសិកម្ម បានជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្មចំនួន៦០នាក់ ក្រុមកសិករសិក្សាខ្នាតតូចចំនួន៣៦០ក្រុម មានគ្រួសារកសិករខ្នាតសរុប៩០០០គ្រួសារចូលរួម ក្នុង៦០ឃុំ និង១៥ស្រុក សម្រាប់ចូលរួមអនុវត្តកម្មវិធី ASPIRE ឆ្នាំ២០១៦ និងបានកំណត់ប្រធានបទ និងសកម្មភាពសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។

**ឃ.** ផ្នែកការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគាំទ្រដល់ភាពធន់នឹងអាកាសធាតុក្នុងរបរកសិកម្ម បានកំណត់ឃុំ គោលដៅចំនួន៦០ឃុំ ក្នុងស្រុក១៥សម្រាប់អនុវត្តកម្មវិធី ASPIRE ឆ្នាំ២០១៦ និងបានធ្វើការវាយតម្លៃបន្ថយភាពងាយរងគ្រោះបានចំនួន៣០ស្រុក សម្រាប់កសាងនិងស្តារហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គាំទ្រដល់ភាពធន់នឹងអាកាសធាតុក្នុងរបរកសិកម្ម។

**ង.** ផ្នែកសម្របសម្រួលនិងគាំទ្រកម្មវិធី÷ បានរៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៦-២០១៨ មន្ទីរកសិកម្មចំនួន៥ មានផែនការសកម្មភាព និងថវិកាសម្រាប់កែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៃកម្មវិធី ASPIRE និងស្របតាមផែនការថវិកាតាមកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៤. គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច តំបន់ទន្លេសាប (TSSD)

– គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច តំបន់ទន្លេសាប (TSSD) ត្រូវបានគ្រោងរចនាឡើងសម្រាប់ជំរុញគាំទ្រការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ គាំទ្រផលិតភាពកសិកម្ម និងការកសាងសមត្ថភាពផ្អែកតាមអាទិភាពរបស់សហគមន៍ តាមរយៈការបង្កើតនិងគាំទ្រក្រុមកែលម្អជីវភាព (លីត) ចំនួន១.២៤១ក្រុម ក្នុងឃុំគោលដៅ ១៩៦ ក្នុង ២៨ស្រុក នៃខេត្ត៥ គឺខេត្តបន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងត្បូងឃ្មុំ។ គម្រោងមានថវិកាសរុប ៥០,៣៧លានដុល្លារសហរដ្ឋអាមេរិក ផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី (៣២,៦៣លាន) មូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម (១៣,៦លាន) រដ្ឋាភិបាលហ្វាំងឡង់ដ៍ (១,៥៩លាន) និងរាជរដ្ឋាភិបាលកម្ពុជា (៥,៥លាន)។ ថវិកាវិភាជសរុបសម្រាប់ក្រសួងកសិកម្មមាន ១១,៨៣លាន (២៣,៣%)។ គម្រោងមាន ៣ សមាសភាគ ហើយត្រូវអនុវត្ត រយៈពេល ៨ឆ្នាំ (ខែមីនា ឆ្នាំ២០១០ដល់ខែកុម្ភៈ ឆ្នាំ២០១៨)។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តសមាសភាគទី២ “បរិយាកាសអំណោយផលដល់ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម” និងសមាសភាគទី ៣ “ការអនុវត្តគម្រោងមានប្រសិទ្ធភាព”

– តាំងពីចាប់ផ្តើមអនុវត្តសកម្មភាពតាមមូលដ្ឋានពាក់កណ្តាលឆ្នាំ២០១២មក គម្រោងសម្រេចបានវឌ្ឍនភាពជាច្រើនសម្រាប់គ្រប់សមាសភាគ។ គិតត្រឹមចុងឆ្នាំ២០១៥នេះ (ពេលវេលាចំណាយអស់៧៣%) គម្រោងបានសម្រេចវឌ្ឍនភាពប្រមាណ៨០% ហើយបានចំណាយថវិកាសរុប៣៤,២៨លាន (៦៧,៥% នៃថវិកាគ្រោងសរុប) ក្នុងនោះ ក្រសួងកសិកម្មបានចំណាយ៧,៩៤លាន (៦៧%) នៃថវិកាវិភាជសរុបសម្រាប់ក្រសួង។ ក្នុងឆ្នាំ២០១៥ លទ្ធផលសម្រេចដូចខាងក្រោម ÷

○ ដំណើរការសាលារៀនចំការកសិករស្តីពីការអនុវត្តកសិកម្មល្អ (GAP) លើដំណាំបន្លែ និងផ្លែឈើចំនួន១២កន្លែង ក្នុងខេត្តសៀមរាប កំពង់ចាម និង ត្បូងឃ្មុំ ដែលមានកសិករចូលរួម ២២៦នាក់/ស្រី៧២នាក់។ បានសម្របសម្រួលរៀបចំ និងអនុវត្តផលិតកម្មតាមកិច្ចសន្យា ដោយអនុវត្តបាន២កិច្ចសន្យា រវាងក្រុមផលិតពូជស្រូវ និងម្ចាស់រោងម៉ាស៊ីនស្រូវ ក្នុងខេត្តកំពង់ធំ និង បន្ទាយមានជ័យ ដែលមានស្រូវសរុប ៤៦តោន

○ រៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី GAPលើដំណាំបន្លែចំនួនពីរ សម្រាប់មន្ត្រីកសិកម្មនិងកសិករគោលដៅនៅខេត្តកំពង់ធំ និងបន្ទាយមានជ័យ ដែលមានអ្នកចូលរួម១២៨នាក់ (ស្រី៣៨នាក់)។ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីផលិតកម្មតាមកិច្ចសន្យាចំនួនបីសម្រាប់មន្ត្រីកសិកម្ម និងក្រុមផលិតពូជស្រូវ និងម្ចាស់រោងម៉ាស៊ីនស្រូវ នៅខេត្តកំពង់ចាម សៀមរាប និងបន្ទាយមានជ័យ ដែលមានអ្នកចូលរួម ១៥០នាក់ ភាគច្រើនជាកសិករ និងម្ចាស់រោងម៉ាស៊ីនស្រូវ

○ បានសិក្សាអង្កេតអំពីទីផ្សារផលិតផល GAP និងការយល់ដឹងរបស់អ្នកប្រើប្រាស់កសិផល ក្នុងខេត្តសៀមរាប និងកំពង់ចាម និងសិក្សារៀបចំផែនការមេចក្ខុវិស័យផលិតកម្មដំណាំនៅកម្ពុជា ឆ្នាំ២០៣០

○ បន្តជួយស្ថានីយកសិកម្មទាំងពីរ(បល្ល័ង្គ/កំពង់ធំនិងទឹកវិល/សៀមរាប) ផ្នែកកសាងសមត្ថភាពថវិកាផលិតពូជ រូបវ័ន្តផលិត និងកែច្នៃវេចខ្ចប់ពូជលក់ និងគ្រឿងចក្រកសិកម្ម។ ស្ថានីយទាំងពីរ បានផលិតពូជស្រូវសុទ្ធអនុញ្ញាតចំនួន៣៦តោនថែមទៀត សម្រាប់លក់ឲ្យក្រុមផលិតពូជស្រូវចំនួន៣៣ក្រុម ដែលគម្រោងបានគាំទ្រ។ ដោយប្រើពូជស្រូវអនុញ្ញាតទិញពីស្ថានីយទាំងពីរ ក្រុមផលិតពូជទាំងនេះ បានផលិតស្រូវពូជសុទ្ធពាណិជ្ជកម្មចំនួន៧៣៥តោន សម្រាប់លក់

ឱ្យកសិករ និងរោងម៉ាស៊ីនស្រូវ។ តាមរយៈផលិតកម្មតាមកិច្ចសន្យា ស្ថានីយទាំងពីរបានទិញស្រូវពូជសុទ្ធពាណិជ្ជកម្មចំនួន ៥១តោនពីក្រុមផលិតពូជ ដើម្បីកែច្នៃ-វេចខ្ចប់សម្រាប់លក់បន្ត ឱ្យអ្នកត្រូវការពូជស្រូវ

○ បានបញ្ចប់វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានហើយបានរៀបចំរបាយការណ៍វិភាគសម្រាប់ឃុំគោលដៅទាំង១៩៦

○ បានរៀបចំធ្វើបង្ហាញបច្ចេកវិទ្យាចំនួន៥១៤ទីតាំង លើប្រធានបទ ស្រូវ បន្លែ ផ្សិត ដំណាំលក់ ចិញ្ចឹមសត្វ (មាន់ ជ្រូក ផ្សំចំណីសត្វ) និង ចិញ្ចឹមត្រី កង្កែប ដោយមានកសិករចូលរួមធ្វើបង្ហាញចំនួន៥១៤នាក់ (២០៨ ស្រី) និង រៀបចំទិវាផ្សព្វផ្សាយលទ្ធផលបង្ហាញចំនួន១៨០ទិវា

○ បន្តផលិតវីដេអូផ្សព្វផ្សាយ និងបោះពុម្ពឯកសារផ្សព្វផ្សាយបន្ថែមទៀត (គោលនយោបាយផ្សព្វផ្សាយកសិកម្ម បច្ចេកទេសផ្សំចំណីសត្វ និងពូជស្រូវទាំង១០មុខ)។ បានប្រមូលឯកសារផ្សព្វផ្សាយបន្ថែម និងដាក់បញ្ចូលក្នុងវេបសាយគម្រោង (www.tssdcambodia.org) សម្រាប់ផ្សព្វផ្សាយ និងគាំទ្រកម្មវិធីតាមមូលដ្ឋាន

○ បានបន្តរៀបចំកម្មវិធីវិទ្យុមានការហៅទូរស័ព្ទចូលសួរតាមខេត្តសម្រាប់គាំទ្រកម្មវិធីផ្សព្វផ្សាយតាមមូលដ្ឋាន ដោយជ្រើសរើសប្រធានបទ ផ្អែកតាមតម្រូវការរបស់កសិករ ក្នុងតំបន់គោលដៅគម្រោង។ មាតិកា/កិច្ចពិភាក្សាក្នុងកម្មវិធីវិទ្យុនេះ ផ្តោតលើទាំងបច្ចេកវិទ្យា/វិធីសាស្ត្រផលិតកម្ម និងបញ្ហាទីផ្សារលក់កសិផល។ ព័ត៌មានស្តីពីការធ្វើបង្ហាញបច្ចេកទេស តម្លៃកសិផលនិងធាតុចូលកសិកម្ម ត្រូវបានប្រមូលនិងចែកចាយជាប្រចាំ ជាមួយមន្ត្រីអនុវត្តកម្មវិធីផ្សព្វផ្សាយ និងសាធារណៈជនតាមរយៈបណ្តាញសង្គម (Facebook)។

## ៥. គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍកសិកម្ម

គម្រោងត្រូវបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១២-២០១៨ ក្នុងខេត្តគោលដៅចំនួនប្រាំរួមមាន ខេត្តកំពត កណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ (ស្រុកចំនួន៣៣)។ លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៥រួមមាន÷

- ចងក្រងកសិករជាក្រុមកែលម្អទុនបង្វិល ចំនួន ៩៨៤ក្រុម ដែលក្រុមនិមួយៗមានសមាជិកចំនួន៥០រូប ក្នុងនោះជាមធ្យម៦៣% ជាស្ត្រី។ ក្រុមដឹកនាំដោយក្រុមប្រឹក្សាភិបាលជ្រើសរើសដោយការបោះឆ្នោត មានសមាសភាពចំនួន៧រូប

- បណ្តុះបណ្តាលកសិករជាសមាជិកអំពីចំណេះដឹងហិរញ្ញវត្ថុ ក្នុងនោះមានពីរវគ្គ (ចំណេះដឹងមូលដ្ឋាននិងចំណេះកម្រិតខ្ពស់) ដើម្បីការគ្រប់គ្រងនិងប្រើប្រាស់ទុនប្រកបដោយគណនេយ្យភាពនិងនិរន្តរភាព។ ក្រោយពីបានទទួលចំណេះដឹងនេះហើយ គម្រោងបានផ្តល់ទុនរយៈពេលបីឆ្នាំបន្តបន្ទាប់នូវថវិកាចំនួន៤.០០០ដុល្លារក្នុងមួយឆ្នាំសម្រាប់ក្រុមនិមួយៗ។ ដើម្បីរក្សាបាននូវប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការគ្រប់គ្រងទុនក្រុម គម្រោងបានសហការជាមួយដៃគូផ្តល់សេវាកម្មពីខាងក្រៅ (ភ្នាក់ងារផ្តល់សេវាកម្មគណនេយ្យចល័ត) ចុះដំណើរការផ្ទៀងផ្ទាត់រៀងរាល់ខែ

- បណ្តុះបណ្តាលកសិករជាសមាជិកអំពីចំណេះដឹងបច្ចេកទេសកសិកម្ម។ ដើម្បីទទួលចំណេះដឹង និងការអនុវត្តបច្ចេកទេសកសិកម្មប្រកបដោយប្រសិទ្ធភាព គម្រោងបានរៀបចំនិងបោះពុម្ពឯកសារបច្ចេកទេសបែបសាមញ្ញ ហើយវិធីសាស្ត្រនៃការបណ្តុះបណ្តាលក៏អនុវត្តដោយមានការចូលរួម តាមរយៈសាលារៀនស្រែកសិករ ដោយក្រុមគ្រូចល័តដែលបានជ្រើសរើសតាមខេត្តនិមួយៗ

- ការងារតាមដាននិងវាយតម្លៃ ត្រូវបានរៀបចំនិងកែលម្អជាបន្តបន្ទាប់តាមអនុសាសន៍នៃក្រុមបេសកកម្មត្រួតពិនិត្យគម្រោងដែលតែងតែមានរៀងរាល់ឆ្នាំ។

### ៦. គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមហាអនុតំបន់មេគង្គ (SPS)

គម្រោងនេះត្រូវអនុវត្តសម្រាប់រយៈពេល៥ឆ្នាំ (ឆ្នាំ២០១២-ឆ្នាំ២០១៧) ដោយស្ថាប័នចំនួន០៣ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងក្រសួងពាណិជ្ជកម្ម មានថវិកាសរុបចំនួន១១,៤លានដុល្លារអាមេរិក។ លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៥រួមមាន÷

**ក. ផ្នែកភូតគាមអនាម័យ (Plant Health CIU)**

- បានចងក្រងបញ្ជីសមាសភាពចង្រៃ (Pest List) លើប្រភេទដំណាំគោលចំនួន២ (ដំណាំស្រូវ និងពោត) ដោយប្រមូលនូវសំណាកបីប្រភេទគឺ សត្វល្អិតចង្រៃ ស្មៅចង្រៃ និងជំងឺ ដោយមានការសហការពីជំនាញការអន្តរជាតិ និងកំពុងបន្តធ្វើការអង្កេតស្រាវជ្រាវអំពីកត្តាចង្រៃលើប្រភេទដំណាំគោលមួយចំនួនទៀតដូចជា ដំឡូង ស្វាយ ក្រូច ម្រេច ចេក បន្លែ គ្រាប់ស្វាយចន្ទី និងសណ្តែក

- សំណង់ផ្ទះកញ្ចក់ចត្តាឡីស័ក (Post Entry Quarantine Green House) ត្រូវបានសាងសង់រួចជាស្ថាពរ កាលពីខែសីហា ឆ្នាំ២០១៥ នៅស្ថានីយ៍ពិសោធន៍ការពារដំណាំពោធិ៍លាស់ ខេត្តព្រៃវែង

- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសស្តីពី “Plant Quarantine Inspector and Stakeholders” ។

**ខ. ផ្នែកសុខភាពសត្វ (Animal Health CIU)**

- បានរៀបចំកម្មវិធីតាមដានឃ្លាំមើលជំងឺសត្វនៅក្នុងខេត្តគោលដៅចំនួន៣គឺ ខេត្តកំពង់ចាម តាកែវ និងស្វាយរៀង សម្រាប់ពង្រឹងសមត្ថភាពមន្ត្រី

- ការឆ្លើយតបនឹងជំងឺឆ្លងសត្វ ដើម្បីធ្វើការទប់ស្កាត់នូវការផ្ទុះឡើងនូវជំងឺឆ្លងសត្វ នៅក្នុងខេត្តព្រៃវែង កំពង់ចាម ស្វាយរៀង និងត្បូងឃ្មុំ

- បានរៀបចំនូវវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីបច្ចេកទេស និងមន្ត្រីមន្ទីរពិសោធន៍

- បានរៀបចំនូវយុទ្ធនាការផ្សព្វផ្សាយស្តីពីការគ្រប់គ្រងការនាំចូលសត្វនិងផលិតផលមានដើមកំណើតពីសត្វ។

**គ. ផ្នែកសុវត្ថិភាពចំណីអាហារ (Food Safety CIU)**

- បានចុះតាមដានអង្កេតអំពីអនាម័យចំណីអាហារ និងសុវត្ថិភាពចំណីអាហារ នៅតាមភោជនីយ៍ដ្ឋាន នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងសៀមរាប

- បានចុះអង្កេតតាមដានការចម្លងរោគគីមីនៅក្នុងម្ហូបអាហារនៅលើទីផ្សារក្នុងប្រទេសកម្ពុជា

- បណ្តុះបណ្តាលបច្ចេកទេសមន្ទីរពិសោធន៍ដល់មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម “Advance Separation Methods”

- ទស្សនកិច្ចសិក្សានៅប្រទេសថៃ និងប្រទេសសិង្ហបុរី ដើម្បីសិក្សាស្វែងយល់បន្ថែមពីការងារបច្ចេកទេសពាក់ព័ន្ធ និងសុវត្ថិភាពចំណីអាហារ។

**ឃ. ផ្នែកអប់រំ (Education CIU)**

-បានសហការជាមួយជំនាញការអន្តរជាតិ ធ្វើការកែប្រែកម្មវិធីសិក្សាសម្រាប់មហាវិទ្យាល័យចំនួនបីគឺ កម្មវិធីសិក្សាថ្មីសម្រាប់មហាវិទ្យាល័យកសិ-ឧស្សាហកម្ម មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ និងវេជ្ជសាស្ត្រសត្វ និងមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

- សាងសង់អាគារមន្ទីរពិសោធន៍អតិសុខុមសាស្ត្រ និងរៀបចំនូវវគ្គបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធ Food Safety

- វគ្គបណ្តុះបណ្តាលពាក់ព័ន្ធសុខភាពសត្វ ភូតគាមអនាម័យ និងសុវត្ថិភាពចំណីអាហារដល់សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

## ៦.៥. ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

### ក. ការគ្រប់គ្រងធនធានមនុស្ស

ក្នុងទិសដៅជំរុញឱ្យកាន់តែមានប្រសិទ្ធភាពនៃការគ្រប់គ្រងការចាត់ចែងការងារ ដោយបានកំណត់ឱ្យបានច្បាស់លាស់អំពីតួនាទីនិងភារកិច្ចនិងពីតម្រូវការ នៃធនធានមនុស្សទាំងបរិមាណនិងគុណភាព លើទំហំការងារជាក់ស្តែងដើម្បីចូលរួមចំណែកអនុវត្តន៍យ៉ាងសកម្មនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាឱ្យបានសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស និងមានផែនការរៀបចំបែបបទ ការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង។ ព្រមជាមួយនោះដែរ ក្រសួងបានចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីការគ្រប់គ្រងមន្ត្រីរាជការ នៅតាមបណ្តាអង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ក្នុងឆ្នាំ២០១៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន៦.៥៦០នាក់ ស្ត្រី១.៣៨៣នាក់ ស្មើនឹង២១% ក្នុងនោះថ្នាក់កណ្តាលមានចំនួន៤.០២១នាក់ ស្ត្រី៨១៣នាក់ ស្មើនឹង២០% ថ្នាក់រាជធានី ខេត្តមានចំនួន២.៥៣៩នាក់ ស្ត្រី៥៧០នាក់ ស្មើនឹង២២%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន១៨៧នាក់ ដាក់មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន២៦៩នាក់ និងបានលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៦៨នាក់ (បោះបង់ការងារ លាឈប់ពីការងារ មរណៈភាព)។ ក្រសួងបានធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីចំនួន២៧៧នាក់ (ក្របខ័ណ្ឌ"ក" ចំនួន២០៨នាក់ និង"ខ"ចំនួន៦៩នាក់។ ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការ ដែលបានខិតខំអនុវត្តការងារទទួលបានស្នាដៃឆ្នើម ក្រសួងបានតែងតាំង និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការបានចំនួន២១៧នាក់ ព្រមទាំងបានផ្តល់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការចំនួន៧១៩នាក់ នារីចំនួន១១៨នាក់ (ពីមេដាយសំរិទ្ធដល់ជាតូបការ)។




ផ្អែកតាមក្រាហ្វិកនៃស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការក្នុងរយៈពេល០៥ឆ្នាំ (២០១១-២០១៥) ឃើញថា ចំនួនក្របខ័ណ្ឌបានថយចុះជាបន្តបន្ទាប់ទន្ទឹមនឹងក្របខ័ណ្ឌថ្មីទទួលបានមិនមានតុល្យភាព និងក្របខ័ណ្ឌដែលបានបាត់បង់។ ករណីនេះជា

បញ្ហាប្រឈមក្នុងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការធ្វើឱ្យសម្រេចជោគជ័យនូវផែនការយុទ្ធសាស្ត្ររបស់ក្រសួង ក្នុងនោះ ក្រសួងបានពង្រីករចនាសម្ព័ន្ធកសិកម្មឱ្យដល់មូលដ្ឋានឃុំ សង្កាត់ ដើម្បីជំរុញការបញ្ជ្រាបនិងផ្ទេរបច្ចេកទេសកសិកម្ម ឱ្យកាន់តែមានប្រសិទ្ធភាពដល់កសិករតាមរយៈការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មរបស់ក្រសួង។

**ខ. ការអភិវឌ្ឍន៍ធនធានមនុស្ស**

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស" របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកបដោយគុណវុឌ្ឍិខ្ពស់ តាមរយៈការបណ្ដុះបណ្ដាលរយៈពេលខ្លី និងរយៈពេលវែង ទាំងក្នុងនិងក្រៅប្រទេស។ ជាក់ស្ដែងក្នុងឆ្នាំ២០១៥ ក្រសួងបានបណ្ដុះបណ្ដាលមន្ត្រីរាជការបានចំនួន១.៩៥១នាក់។ វគ្គបណ្ដុះបណ្ដាលក្នុងប្រទេសរយៈពេលខ្លីបានចំនួន១.១០៦នាក់ និងវគ្គបណ្ដុះបណ្ដាលរយៈពេលវែងបានចំនួន៣៤នាក់ ដែលក្នុងនោះថ្នាក់បណ្ឌិតចំនួន១៥នាក់ និងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន១៩នាក់។ ដោយឡែកចំពោះវគ្គបណ្ដុះបណ្ដាលក្រៅប្រទេសបានចំនួន៨១៥នាក់។ វគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីបានចំនួន៧៨០នាក់ និងវគ្គបណ្ដុះបណ្ដាល រយៈពេលវែងបានចំនួន៣៥នាក់ ពោលគឺថ្នាក់បណ្ឌិតបានចំនួន ១០នាក់ និងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន២៥នាក់។

**គ. ការងារបណ្ដុះបណ្ដាលនិស្សិត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគ្រឹះស្ថានអប់រំជំនាញបីគឺ÷ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.វ.ភ.ក.) សាលាជាតិកសិកម្មព្រែកលៀប(ក.ព.ល.) និងសាលាជាតិកសិកម្មកំពង់ចាម(ស.ជ.ក.ក.ច.) ។

គិតចាប់ពីឆ្នាំ២០១១ និស្សិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ដែលបានចុះឈ្មោះចូលសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាទាំងបី មានការកើនឡើងជារៀងរាល់ឆ្នាំគិតត្រឹមឆ្នាំ២០១៣ ដែលមាននិស្សិតសរុបរហូតដល់៣០០០នាក់ ដោយឡែកចំនួននេះបានថយចុះមកវិញក្នុងឆ្នាំ២០១៤និង២០១៥ បណ្ដាលមកពីចំនួននិស្សិតប្រលងជាប់សញ្ញាបត្រទុតិយភូមិ មានការថយចុះ។ ក្នុងឆ្នាំសិក្សា២០១៥-២០១៦ គ្រឹះស្ថានទាំងបីមាននិស្សិតកំពុងសិក្សាសរុបចំនួន៥.៩២១នាក់ នារី១.៩១៨នាក់ ដែលចែកចេញជាថ្នាក់បរិញ្ញារងចំនួន៥៦០នាក់ បរិញ្ញាចំនួន៥.២៦១នាក់ បរិញ្ញាជាន់ខ្ពស់ចំនួន៨៤នាក់ និងថ្នាក់បណ្ឌិតចំនួន១៦នាក់ សិក្សាលើមុខជំនាញឯកទេសចំនួន១០ រួមមាន÷ វិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមុខជំនាញវិទ្យាសាស្ត្រកៅស៊ូ។ និស្សិតត្រូវសិក្សារយៈពេល២ឆ្នាំចំពោះថ្នាក់បរិញ្ញាបត្ររង និង ៤ឆ្នាំចំពោះថ្នាក់បរិញ្ញាបត្រ ២ឆ្នាំចំពោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង៣ឆ្នាំចំពោះថ្នាក់បណ្ឌិត។ គិតចាប់ពីឆ្នាំ២០១១មកជារៀងរាល់ឆ្នាំមាននិស្សិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង សរុបដែលបញ្ចប់ការសិក្សាពីគ្រឹះស្ថានអប់រំជំនាញទាំងបីចំនួន ១.២៤០នាក់ រហូតដល់ចំនួន២.១៤២នាក់។

តាមរយៈការស្ទង់មតិនិស្សិតបញ្ចប់ការសិក្សាពីគ្រឹះស្ថានអប់រំជំនាញទាំងបី បាននិងកំពុងបម្រើការនៅស្ថាប័នផ្សេងៗ ក្នុងនោះ ប្រមាណ៥០%បម្រើការនៅក្នុងវិស័យឯកជន ប្រមាណ២០%ក្នុងស្ថាប័នរដ្ឋាភិបាល និងបម្រើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ឬប្រកបអាជីវកម្មផ្ទាល់ខ្លួន ក្នុងអត្រាប្រហាក់ប្រហែលគ្នាគឺ១៥%។

បច្ចុប្បន្ននេះ គ្រឹះស្ថានទាំងបីមានសាស្ត្រាចារ្យ គ្រូបង្រៀន និងបុគ្គលិក សរុបចំនួន៣២១នាក់ នារី៩២នាក់។ ដើម្បីអភិវឌ្ឍន៍សមត្ថភាពបង្រៀន និងគ្រប់គ្រងគ្រឹះស្ថាន ទាំងបីបានធ្វើការអភិវឌ្ឍធនធានសាស្ត្រាចារ្យនិងគ្រូបង្រៀនរបស់ខ្លួន តាមរយៈការបញ្ជូនមន្ត្រីសាស្ត្រាចារ្យ និងគ្រូបង្រៀនចូលរួមសន្និសីទ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលផ្សេងៗ ទាំងក្នុងនិងក្រៅ

ប្រទេស និងបានបញ្ជូនឱ្យទៅបន្តការសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតបន្ថែមទៀត នៅសាកលវិទ្យាល័យដៃគូ។ ដោយឡែក គ្រឹះស្ថានទាំងបីក៏បានបញ្ជូននិស្សិតទៅធ្វើកម្មសិក្សា នៅសាកលវិទ្យាល័យដៃគូ នៅបរទេសបានចំនួន២៤៥នាក់ផងដែរ។

**ក្រាហ្វិកបង្ហាញអំពី ស្ថិតិនិស្សិតចូលសិក្សា និងបញ្ចប់សិក្សាពីគ្រឹះស្ថានអប់រំជំនាញទាំងបី (សម្រាប់សវភក គិតចំពោះតែថ្នាក់បរិញ្ញាបត្រ ចំពោះ កពល និង សជកកច គិតរួមទាំងបរិញ្ញាបត្ររង និងបរិញ្ញាបត្រ)**




សម្គាល់ ស.វ.ភ.ក.÷ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក.ព.ល.÷ សាលាជាតិកសិកម្មព្រែកលៀប ស.ជ.ក.ក.ច.÷ សាលាជាតិកសិកម្មកំពង់ចាម

**ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីសាស្ត្រាចារ្យ និងមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅគ្រឹះស្ថានឧត្តមសិក្សាទាំងបី**

| ប្រភេទបណ្តុះបណ្តាល | ទីកន្លែង | ស.វ.ភ.ក. | ក.ព.ល. | ស.ជ.ក.ក.ច. |
|---|---|---|---|---|
| វគ្គបណ្តុះបណ្តាលខ្លី | ក្នុងប្រទេស | ២០ | ៤០ | ៣៣ |
| | ក្រៅប្រទេស | ៤០ | ១៥ | ៥ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ក្នុងប្រទេស | ១៩ | ៩ | ២ |
| | ក្រៅប្រទេស | ១២ | ១ | |
| បណ្ឌិត | ក្នុងប្រទេស | ១៥ | ១ | ៤ |
| | ក្រៅប្រទេស | ៥ | ១ | |

គ្រឹះស្ថានអប់រំជំនាញទាំងបី បាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រដើម្បីអនុវត្តកម្មវិធីសិក្សា ដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសេវាកម្មសម្រាប់សហគមន៍ ក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសកលភាវូបនីយកម្ម។

លើផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិ មានអ្នកជំនាញការបរទេសចំនួន១៣នាក់ កំពុងបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា ក្នុងនោះមានជនជាតិជប៉ុន កូរ៉េ អាល្លឺម៉ង់ សហរដ្ឋអាមេរិក ហ្វីលីពីន និងមានគ្រឹះស្ថានដៃគូសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេភាគីនិងពហុភាគី សរុបចំនួន៥៨សាកលវិទ្យាល័យ។ លើសពីនេះ សាលាជាតិកសិកម្មកំពង់ចាម បាន

បង្កើតកិច្ចសហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA ដើម្បីអនុវត្តគម្រោងការបណ្តុះបណ្តាល និងផ្សព្វផ្សាយ គោលការណ៍ចលនាភូមិថ្មី និងបានសាងសង់មន្ទីរពិសោធន៍ថ្មីមួយខ្នងមានពីរជាន់បានរួចរាល់ ព្រមទាំងបានបំពាក់បន្ថែមនូវឧបករណ៍ និងមធ្យោបាយសម្ភារសិក្សាពិសោធន៍ នៅក្នុងបន្ទប់ពិសោធន៍ដែលមានស្រាប់ នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម តាមរយៈគម្រោងកែលម្អគុណភាពអនាម័យ និងភូតគាមអនាម័យ (SPS)។

ចំពោះការងារស្រាវជ្រាវ គ្រឹះស្ថានអប់រំជំនាញទាំងបី បាននិងកំពុងអនុវត្តគម្រោងស្រាវជ្រាវចំនួន៣០គម្រោង ពាក់ព័ន្ធលើផ្នែកវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ ព្រៃឈើ ជលផល កសិឧស្សាហកម្ម រៀបចំដែនដី។ល។ ប្រភពហិរញ្ញវត្ថុសំខាន់ៗទទួលបានពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបរិស្ថាន អូស្ត្រាលី កាណាដា សាធារណៈរដ្ឋឆេកូស្លាវ៉ាគី សហគមអ៊ឺរ៉ុប ប្រទេសកូរ៉េ ប្រទេសជប៉ុន សហរដ្ឋអាមេរិក។ល។ ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវសាកលវិទ្យាល័យភូមិន្ទកសិកម្ម បានរៀបចំសន្និសីទវិទ្យាសាស្ត្រថ្នាក់ជាតិចំនួន១លើក និងសន្និសិទវិទ្យាសាស្ត្រថ្នាក់អន្តរជាតិចំនួន២លើក ដែលមានអ្នកចូលរួមធ្វើបទបង្ហាញជាតិនិងអន្តរជាតិជាង១០០ប្រធានបទក្នុងសន្និសិទនីមួយៗ។

## ៦.៦. ការអភិវឌ្ឍការងារយេនឌ័រក្នុងវិស័យកសិកម្ម

ក្រសួងបានយកចិត្តទុកដាក់ខ្ពស់អំពីកិច្ចអភិវឌ្ឍយេនឌ័រនិងកុមារ។ ក្រសួងបានគាំទ្រនូវការអនុវត្តតាមគោលការណ៍រួមស្តីពី "**ការវិនិយោគលើសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍប្រកបដោយចីរភាព**" ដែលមានភាពស៊ីចង្វាក់ជាមួយនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ថ្មីជាសកល ក្នុងជំពូកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ និងគោលដៅទាំង១៧ចំណុចនៃការអភិវឌ្ឍប្រកបដោយចីរភាព។ ក្រសួងបានតម្រង់ទិសការអភិវឌ្ឍនេះតាមរយៈអាទិភាពគន្លឹះគឺ÷ (១).ការបង្កើនការវិនិយោគលើសមភាពយេនឌ័រ (២).ការធានានូវការការពារសិទ្ធិរបស់ស្ត្រី ព្រមទាំងការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត (៣).ការពង្រឹងយន្តការគណនេយ្យភាពសម្រាប់សមភាពយេនឌ័រ និង (៤).ការបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចកសិកម្ម និងបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ដោយត្រូវបង្កើនការយល់ដឹងអំពីកិច្ចអភិវឌ្ឍអាជីវកម្ម សម្រាប់សហគ្រាសស្ត្រីខ្នាតតូចនិងខ្នាតមធ្យម ការបង្កើននូវកម្មវិធីនានាដើម្បីជួយឱ្យស្ត្រីទទួលបាននូវជំនាញបច្ចេកទេស សហគ្រិនភាព គាំទ្រស្ត្រីក្នុងការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មលើវិស័យកសិកម្ម ព្រមទាំងកិច្ចសហការជាមួយភាគីពាក់ព័ន្ធនានានៅក្នុងទីផ្សារការងារ។ យើងអាចវាយតម្លៃជាវិជ្ជមានថា ក្នុងរយៈពេលកន្លងមកនេះ សមភាពយេនឌ័រនៅក្នុងផ្នែកកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយការចូលរួមរបស់ស្ត្រីបានធ្វើឱ្យមានភាពចម្រើនជឿនលឿនទៅមុខយ៉ាងធំធេង និងការស្រូបយកកម្លាំងពលកម្មនារីជនបទប្រមាណជាង៦០%។ ដូច្នេះ ស្ត្រីជាអ្នកចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ដូចជាធ្វើស្រែចម្ការ ដាំដុះដំណាំ ចិញ្ចឹមសត្វ ត្រី សិប្បកម្មខ្នាតតូចជាដើម។ ក្រៅពីនេះ ស្ត្រីជាកសិករបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រែក្លាយផលិតកម្មកសិកម្មឱ្យទៅជាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

**ក. ការងារយេនឌ័រ**

- បានរៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម២០១៦-២០២០ និងបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥

- បានរៀបចំផែនការសកម្មភាពបញ្ជ្រាបយេឌ័រក្នុងវិស័យកសិកម្មសម្រាប់រយៈពេល៥ឆ្នាំ (២០១៦-២០២០)

- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលយេនឌ័រ និងការប្រែប្រួលអាកាសធាតុដល់សមាជិកក្រុមការងារយេនឌ័រ និងកុមារព្រមទាំងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធសរុបចំនួន២០រូប

- បានពិភាក្សាត្រៀមរៀបចំវគ្គបណ្តុះបណ្តាលបន្ត មានស្ត្រី១៨រូបមកពីខេត្តនិងសហគមន៍ ដោយសហការជាមួយអង្គការអភិវឌ្ឍន៍ហូឡង់

- បានចូលរួម និងជួយសម្របសម្រួលក្នុងដំណើការរៀបចំវេទិការកសិករស្ត្រីថ្នាក់ក្រោមជាតិចំនួន០៥តំបន់ ដូចជា ខេត្ត ក្រចេះ បាត់ដំបង សៀមរាប កំពត និងព្រៃវែង ជាមួយកសិករស្ត្រីឆ្នើមចំនួន១០០នាក់ ក្នុងគម្រោងលើកកម្ពស់ស្ត្រីឲ្យក្លាយជាកសិករឆ្នើមគាំទ្រដោយអង្គការ Oxfam

- បានចូលរួមក្នុងកិច្ចពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពី សេចក្តីសង្កេតសន្និដ្ឋានអនុសាសន៍ទី១៥ និងទី២១របស់គណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិ

- បានបើកវគ្គបណ្តុះបណ្តាលស្តីពី ចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំង និងនារីភេទ (ស៊ី-ដ)ចំនួន០២វគ្គ ដល់មន្ទីរកសិកម្មខេត្ត កំពង់ចាម និងបាត់ដំបង មានសមាជិកចូលរួមសរុបចំនួន១១៦នាក់ (ស្ត្រីចំនួន៣១នាក់)

- បានចូលរួមសិក្ខាសាលាស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ និងបានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារយេនឌ័រឆ្នាំ២០១៥ និងទិសដៅបន្តឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ

- ក្រុមការងារយេនឌ័រនិងកុមារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមក្នុងវេទិការជ្រើសរើសស្ត្រីឆ្នើម ក្នុងនោះជ្រើសរើសបានកសិករស្ត្រីឆ្នើមចំនួន១០០នាក់ នៅទូទាំង២៥រាជធានី ខេត្ត

- បានធ្វើរបាយការណ៍៩ខែនិងប្រចាំឆ្នាំ ដែលទាក់ទងនិងការអនុវត្តអនុសាសន៍ទាំង១២ចំណុចរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាចូលរួមកិច្ចប្រជុំបូកសរុបការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) ប្រចាំឆ្នាំ២០១៥ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៦ និងតែងតែចូលរួមសហការជាប្រចាំជាមួយក្រុមការងារបច្ចេកទេស (TWGG) ក្រសួងកិច្ចការនារី។ ក្រុមការងារយេនឌ័រនិងកុមារ មានកិច្ចសហការល្អប្រសើរជាមួយអន្តរក្រសួងទាំងថ្នាក់ជាតិ និងអន្តរជាតិ។

**២.ការងារកុមារៈ**

- បានរៀបចំគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ ដែលប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥

- បានរៀបចំសិក្ខាសាលាស្តីពី ការធ្វើផែនការសកម្មភាពលើកគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារ គាំទ្រដោយថវិកាតាមកម្មវិធី

- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីស្ថានភាពកុមារកសិកម្មនៅខេត្តតាកែវ និងបានផ្សព្វផ្សាយឲ្យអនុវត្តគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្ម នៅខេត្តកំពង់ឆ្នាំង

- បានចូលរួមផ្សព្វផ្សាយបានចូលរួមផ្សព្វផ្សាយពីគោលនបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅខេត្តមួយចំនួនដូចជា កំពង់ឆ្នាំង ក្រចេះ ព្រៃវែង កំពង់ធំ ស្វាយរៀង កំពត និងឧត្តរមានជ័យ

- បានចូលរួមសក្ខាសាលាស្តីពី ការរៀបចំ M&E លើក្របខណ្ឌយុទ្ធសាស្រ្តអនុវត្តការងារគាំពារ និងអភិវឌ្ឍន៍កុមារតូចរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តសៀមរាប។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឆន្ទៈយ៉ាងមុតមាំ ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តបញ្រ្ជាបយេនឌ័រក្នុងវិស័យកសិកម្ម និងលើកទឹកចិត្តដល់គ្រប់អង្គភាពក្រោមឱវាទ រួមទាំងអង្គការជាតិអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ទាំងអស់ជួយគាំទ្រដល់ការអនុវត្តគោលនយោបាយនេះ ដើម្បីទទួលបានលទ្ធផលរួមគ្នាប្រកបដោយជោគជ័យ។

## IV- បញ្ហាប្រឈម

ក្នុងឆ្នាំ២០១៥នេះ បញ្ហាប្រឈមក្នុងផលិតកម្មដំណាំកសិកម្ម ត្រូវបានកត់សម្គាល់ឃើញថា ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ដោយសារកត្តាប្រែប្រួលអាកាសធាតុ និងកង្វះខាតប្រព័ន្ធស្រោចស្រព គឺជាបញ្ហាមួយដែលបានជួបប្រទះជារៀងរាល់ឆ្នាំ។ បន្ថែមលើនេះ កង្វះខាតធនធានសម្រាប់ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គឺជាបញ្ហាមួយទៀតដែលត្រូវពិនិត្យពិចារណាបន្ថែម ឱ្យស្របតាមទំហំការងារដែលចេះតែកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការស្រាវជ្រាវ អភិវឌ្ឍន៍ ការផលិត និងផ្សព្វផ្សាយពូជដំណាំដែលមានគុណភាពខ្ពស់នៅមានកម្រិត។ ម៉្យាងវិញទៀត សមត្ថភាពសហគមន៍កសិកម្ម ដែលជាតួអង្គសេដ្ឋកិច្ចជនបទដ៏សំខាន់ ក៏នៅមានកម្រិតនៅឡើយ តម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់នាពេលខាងមុខ។ លើសពីនេះ លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មក៏នៅមានកម្រិតផងដែរ។ សមត្ថភាពស្រូបយកចំណេះដឹងបច្ចេកទេសដាំដុះ និងការប្រើប្រាស់ធាតុចូលកសិកម្មឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលក្នុងចំណោមប្រជាកសិករនៅមានកម្រិត។ ការចូលរួមវិនិយោគក្នុងវិស័យកសិកម្មរបស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍផលិតកម្មកសិកម្មនៅមានទំហំតូច បើប្រៀបធៀបនឹងវិស័យពីរផ្សេងទៀត ជាពិសេសការវិនិយោគជាលក្ខណៈសហគ្រាសខ្នាតមធ្យមនិងធំក្នុងការកែច្នៃផលិតផលកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែមនៅមានកម្រិតទាប។ ចំពោះផលិតកម្មកៅស៊ូ បញ្ហាកំពុងគំរាមកំហែងដល់ការអភិវឌ្ឍដំណាំនេះ គឺបញ្ហាថ្លៃធ្លាក់ចុះ ដែលបណ្តាលមកពីកត្តាទីផ្សារខាងក្រៅជះឥទ្ធិពលជាអវិជ្ជមានដល់ផលិតករកៅស៊ូ។ កង្វះធនធានមនុស្សអ្នកបច្ចេកទេសនៅមូលដ្ឋានថ្នាក់មូលដ្ឋាន ពិសេសថ្នាក់ស្រុក ដើម្បីអប់រំផ្សព្វផ្សាយបច្ចេកទេសឱ្យដល់កសិករកំពុងជួបបញ្ហាប្រឈម និងទាមទារឱ្យមានការយកចិត្តខ្ពស់បំផុត។

ផលិតកម្មសត្វមិនសូវមានការរីកចម្រើនខ្លាំងក្លានៅឡើយ ពិសេសផលិតកម្មគោក្របីមានការថយចុះ ដោយសារកង្វះកម្លាំងពលកម្មនៅជនបទ ចំណាកស្រុក ជាហេតុធ្វើឱ្យកសិករភាគច្រើនប្រើប្រាស់សេវាគ្រឿងយន្តកសិកម្ម ការថយចុះវាលស្មៅចិញ្ចឹមសត្វ ការបម្រែបម្រួលអាកាសធាតុ ខ្វះប្រភពទឹក។ ជាការកត់សម្គាល់ អត្រាឈឺ ស្លាប់សត្វ និងជំងឺឆ្លងសត្វនៅតែជាការគំរាមកំហែងដល់ផលិតកម្មសត្វធ្វើឱ្យផលិតភាពសត្វថយចុះ ហើយកង្វះខាតថ្នាំការពារ ព្យាបាលសត្វ និងឧបករណ៍សម្ភារបរិក្ខាបសុពេទ្យនៅតែត្រូវបានជួបប្រទះ។ លើសពីនេះ បទល្មើសដឹកជញ្ជូនសត្វ និងផលិតផលសត្វ ការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វនៅអនុវត្តមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ការស្រាវជ្រាវផលិតកម្មនិងបសុព្យាបាល ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មបសុព្យាបាលអនុវត្តនៅមានកម្រិតអាស្រ័យដោយធនធាន និងមធ្យោបាយមានកម្រិត។

បទល្មើសនេសាទនៅតែកើតមាន និងការទន្ទ្រានយកដីក្នុងដែនព្រៃលិចទឹកធ្វើជាកម្មសិទ្ធឯកជន នៅតែមានសកម្មភាព។ ការយល់ដឹងរបស់ប្រជានេសាទពីសារៈប្រយោជន៍នៃធនធានជលផលនៅមានកម្រិត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់។ ការអនុវត្តច្បាប់នៅមានកម្រិត និងកិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធមួយចំនួននៅមិនទាន់ស៊ីជម្រៅ។ សហគមន៍នេសាទពុំមានធនធានគ្រប់គ្រាន់ សម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសមត្ថភាពរបស់សមាជិកសហគមន៍នេសាទនៅមានកម្រិត។

ការយល់ដឹងពីសារៈសំខាន់ព្រៃឈើក្នុងចំណោមប្រជាជនមូលដ្ឋាន ពឹងអាស្រ័យអនុផលព្រៃឈើនៅមានកម្រិតទាបនៅឡើយ ដែលទាមទារឱ្យមានការពន្យល់ផ្សព្វផ្សាយបន្ថែមទៀត។ ការងារបង្ក្រាបបទល្មើស និងការកាប់រានដីព្រៃយកដីធ្វើជាកម្មសិទ្ធិល្មើសច្បាប់មានការលំបាក។ ការតាំងទីលំនៅរបស់ជនចំណាកស្រុកក្នុងតំបន់ព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃត្រូវបានពិនិត្យឃើញមានការកើនឡើង។ ថវិកាដៃគូអភិវឌ្ឍន៍ចូលរួមក្នុងការបោះបង្គោលព្រំនៅមានកម្រិត។ សហគមន៍ព្រៃឈើមួយចំនួនដែលមានទីតាំងក្នុងព្រៃសម្បទាន ឬសម្បទានដីសេដ្ឋកិច្ច ពុំទាន់មានប្រកាសទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឡើយ។ ថវិការដ្ឋដែលគាំទ្រដល់ដំណើរការអនុវត្តសហគមន៍ព្រៃឈើមានចំនួនតិចតួច ស្របពេលការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍មានការថយចុះ និងដំណើរការនៃការរៀបចំបង្កើតព្រៃការពារមានភាពស្មុគស្មាញ និងត្រូវការពេលវេលាយូរ។

## V- ទិសដៅអនុវត្តឆ្នាំ២០១៦-២០១៧

សម្រាប់ឆ្នាំ២០១៦-២០១៧នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅ និងផែនការអនុវត្តដូចខាងក្រោម÷

### ១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

#### ក. សូចនាករទិសដៅ

– ជំរុញការដាំដុះដំណាំស្រូវទូទាំងប្រទេសឆ្នាំ២០១៦-២០១៧ យ៉ាងតិចបំផុតឱ្យបាន២,៩លានហ.ត ដោយត្រូវបង្កើនផ្ទៃដីស្រូវបង្កើនរដូវលើផ្ទៃដីស្រូវរដូវវស្សានិងប្រាំង។ ទិន្នផលស្រូវប្រចាំឆ្នាំត្រូវជំរុញឱ្យមានកំណើន០,១៧% គឺកើនពី៣,០៨៥តោន/ហត ឆ្នាំ២០១៥-២០១៦ ទៅដល់៣,០៩០តោន/ហត នៅឆ្នាំ២០១៦-២០១៧ ក្នុងនោះទិន្នផលស្រូវវស្សាត្រូវជំរុញឱ្យកើនដល់២,៨៥តោន/ហត និងទិន្នផលស្រូវប្រាំង៤,៤៤តោន/ហត

– បរិមាណផលស្រូវសរុបនឹងត្រូវបង្កើនឱ្យបានយ៉ាងតិចជាង៩លានតោននាឆ្នាំ២០១៦-២០១៧ ក្នុងនោះ បរិមាណផលស្រូវវស្សាត្រូវសម្រេចឱ្យបានយ៉ាងតិចជាង៧លានតោន និងស្រូវប្រាំងជាង២លានតោន

– ជំរុញការដាំដុះដំណាំរួមផ្សំនិងឧស្សាហកម្ម (ពោត ដំឡូងឈើ ដំឡូងជ្វា បន្លែ សណ្តែកបាយ សណ្តែកដី សណ្តែកសៀង អំពៅ ល្ង) ឱ្យបានកើនឡើងពី៩៣២ពាន់ហ.ត ទៅដល់៩៥០ពាន់ហ.តនៅឆ្នាំ២០១៥-២០១៦ ពោលគឺត្រូវបង្កើនផ្ទៃដីដាំដុះក្នុងកម្រិត២%។

#### ខ. វិធានការអនុវត្តដើម្បីសម្រេចបានទិសដៅកំណត់

– បង្កើនការផលិត ផ្សព្វផ្សាយ និងចែកចាយគ្រាប់ពូជស្រូវ១០មុខ ដែលមានគុណភាពល្អ ពិសេសពូជស្រូវក្រអូបឱ្យចូលជ្រៅដល់ស្រទាប់កសិករនិងវិស័យឯកជន ហើយបន្តសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផលិតផ្សព្វផ្សាយពូជស្រូវក្រអូបប្រកាន់រដូវនិងមិនប្រកាន់រដូវ ដែលមានឧត្តមភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិ និងពិសេសពូជដំណាំរួមផ្សំផ្សេងៗ។ ដើម្បីសម្រេចឱ្យបាននូវវិធានការនេះ ត្រូវពង្រឹងតួនាទី បង្កើនសមត្ថភាព និងបង្កើនធនធាន (មនុស្ស សម្ភារ និងថវិកា) ដល់បណ្តាកសិដ្ឋាន ស្ថានីយពិសោធន៍ ស្រាវជ្រាវ មណ្ឌលអភិវឌ្ឍន៍ឱ្យមានដំណើរការកាន់តែសកម្ម ពិសេសស្ថានីយស្រាវជ្រាវដំណាំបន្លែ

– ពង្រឹងសមត្ថភាពគ្រប់គ្រងនិងបង្កើនធនធានហិរញ្ញវត្ថុគាំទ្រដល់សហគមន៍កសិកម្ម និងប្រែក្លាយសហគមន៍កសិកម្មទៅជាសហគ្រាសកសិកម្មជនបទ តាមរយៈការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ផែនការអាជីវកម្ម និងធនធានដល់សហគមន៍ទាំងនោះ។ អគ្គនាយកដ្ឋានកសិកម្ម ត្រូវខិតខំរៀបចំនិងផ្តល់ការបំពាក់បំប៉ន សម្រាប់បង្កើនសមត្ថភាពគ្រប់គ្រងរៀបចំអាជីវកម្ម និងប្រតិបត្តិដល់សហគមន៍អភិវឌ្ឍន៍កសិកម្មឱ្យមានប្រសិទ្ធភាព និងត្រូវជំរុញបង្កើតសហគមន៍អភិវឌ្ឍន៍កសិកម្ម និងប្រែក្លាយសហគមន៍កសិកម្មទាំងនោះ ទៅជាសហគ្រាសកសិកម្មជនបទឱ្យបានច្រើនថែមទៀតនៅឆ្នាំ២០១៦

– ពង្រឹងសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់មូលដ្ឋានពិសេសថ្នាក់ស្រុក ដោយត្រូវខិតខំយកចិត្តទុកដាក់ដល់មន្ត្រីផ្សព្វផ្សាយ និងបង្កើនធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់។ អគ្គនាយកដ្ឋានកសិកម្ម ត្រូវពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ជំរុញការបណ្តុះបណ្តាលបច្ចេកទេសបន្ថែមដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ឱ្យបានកាន់តែច្រើនថែមទៀត

– ខិតខំរៀបចំយន្តការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ឱ្យមានដំណើរការល្អប្រសើរ ពិសេសការរៀបចំបង្កើតទម្រង់កិច្ចសន្យាសម្រាប់សហគមន៍កសិករ ក្រុមអ្នកប្រមូលទិញ ដើម្បីជាមូលដ្ឋានអនុវត្តឱ្យបានកាន់តែទូលំទូលាយ

– ស្វះស្វែងរកប្រភពធនធានដើម្បីរៀបចំកំណត់តំបន់ដាំដុះ និងការកសាងផែនទីប្រើប្រាស់ដីកសិកម្ម

– បង្កើនការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការងារផលិតកម្មកសិកម្ម

– ត្រៀមលក្ខណៈឱ្យបានល្អក្នុងការជួយអន្តរាគមន៍សង្គ្រោះ ពីផលប៉ះពាល់ដោយគ្រោះធម្មជាតិ និងកត្តាចង្រៃផ្សេងៗនៃដំណាំ ដោយត្រូវត្រៀមបម្រុងស្រូវពូជ ពូជបន្លែឱ្យបានគ្រប់គ្រាន់

– ជំរុញការកសាងច្បាប់ដូចជាច្បាប់ការពារដំណាំ ច្បាប់ជីកសិកម្ម។ល។ និងបទដ្ឋានក្រោមច្បាប់នានា ដើម្បីដឹកនាំគ្រប់គ្រងការងារឱ្យមានប្រសិទ្ធភាពខ្ពស់។

## ២. ផែនការផលិតកម្មដំណាំកៅស៊ូ

### ក. សូចនាករទិសដៅ

– ជំរុញផលិតកម្មនិងបង្កើនផ្ទៃដីដំណាំកៅស៊ូនៅឆ្នាំ២០១៦ ក្នុងកំណើនប្រមាណ២,៨២% ធៀបនឹងឆ្នាំ២០១៥ ដោយត្រូវសម្រេចឱ្យបានលើផ្ទៃដី៣៩៩ពាន់ហ.ត ទោះបីជាកត្តាតម្លៃកៅស៊ូដែលនៅបន្តធ្លាក់ចុះ ដែលធ្វើឱ្យវិនិយោគិនផ្នែកនេះរុញរាក្នុងការដាំដំណាំនេះ

– ផលិតផលកៅស៊ូស្ងួតនៅក្នុងឆ្នាំ២០១៦ នឹងត្រូវបង្កើនដល់១៤៨,៧០ពាន់តោន ក្នុងកំណើន៧,២១%/ឆ្នាំ បង្កើនការនាំចេញកៅស៊ូឱ្យបាន១៤១ពាន់តោននៅឆ្នាំ២០១៦។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

– បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងនិងអភិវឌ្ឍន៍កៅស៊ូ

– ជំរុញការពង្រីកផ្ទៃដីដំណាំកៅស៊ូរបស់ក្រុមហ៊ុនឯកជននិងកៅស៊ូគ្រួសារ ពិសេសចូលរួមពិនិត្យ តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន

– រៀបចំផែនការយុទ្ធសាស្ត្រថវិកា (បីឆ្នាំរំកិល) និងគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៧ ដោយពិនិត្យឡើងវិញនូវការកំណត់សកម្មភាព សូចនាករ គោលដៅសូចនាករ និងថវិកាចំណាយ ដើម្បីឱ្យសមស្របតាមស្ថានភាព និងលទ្ធភាពជាក់ស្តែង

– ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា២០១១-២០២០

– បន្តអនុវត្ត និងពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៦ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី

– ធ្វើការប្រមូលចំណូលពីការជួលអចលនវត្ថុ

– បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្ដីពីការដាំដុះ ថែទាំកូនកៅស៊ូ ការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ

– បន្តការពង្រីកទីតាំងស្ថានីយនិងមន្ទីរពិសោធន៍ និងបង្កើនសមត្ថភាពស្រាវជ្រាវ ផ្សព្វផ្សាយនិងបង្ហាញ

– បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ

– ជំរុញការចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ

– អនុវត្តបែបបទវិញ្ញាបនប័ត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញកៅស៊ូ អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ ជំរុញការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគី ក្នុងរង្វង់ប្រទេសជា សមាជិកនៃ IRRDB

– បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក និងសមត្ថកិច្ចនៅតាមច្រកព្រំដែន) ដើម្បីជួយទប់ស្កាត់សកម្មភាពការបើកស្នាក់ការប្រមូលទិញកៅស៊ូគ្រួសារ ដែលគ្មានលិខិតអនុញ្ញាត និងការនាំចេញកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសដោយខុសច្បាប់

– បន្តចូលរួមសន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ និងក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ហើយឆ្នាំ២០១៦ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះសន្និសិទកៅស៊ូអន្តរជាតិ

- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្រ្ត ព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ អំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- ពង្រីកដៃគូសហប្រតិបត្តិការក្នុងការស្វែងរកថវិកា និងបច្ចេកទេស ដើម្បីគាំទ្រអភិវឌ្ឍន៍កៅស៊ូគ្រួសារ និងបន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានា ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ខាងវិស័យកៅស៊ូ។

## ៣. ផែនការផលិតកម្មសត្វនិងសុខភាពសត្វ

### ក. សូចនាករទិសដៅ

- ជំរុញការចិញ្ចឹមគោជាលក្ខណៈគ្រួសារនៅទូទាំងប្រទេសឱ្យបានដល់ចំនួន២,៩៣លានក្បាល (កំណើន១% ធៀបឆ្នាំមុន) និងការចិញ្ចឹមក្របីឱ្យបានដល់ចំនួន៥០៨ពាន់ក្បាល (កំណើន០,៥%) នៅឆ្នាំ២០១៦
- ជំរុញការចិញ្ចឹមជ្រូកទូទាំងប្រទេសនៅឆ្នាំ២០១៦ ឱ្យបានដល់ចំនួន២,៤លានក្បាល (កំណើន២%)
- ជំរុញការចិញ្ចឹមបក្សីទូទាំងប្រទេសនៅឆ្នាំ២០១៦ ឱ្យបានដល់ចំនួន២៨លានក្បាល (កំណើន៥%)
- ជំរុញការចាក់វ៉ាក់សាំងគោក្របីឱ្យបាន១,៦១លានក្បាលនៅឆ្នាំ២០១៦
- បង្កើនការអនុវត្តវិធានការនានា ដើម្បីឱ្យសត្តឃាតដ្ឋានចំនួន៥០កន្លែង បានអនុវត្តអនាម័យសាច់សត្វស្របតាមស្តង់ដារបច្ចេកទេសត្រឹមត្រូវ។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- ជំរុញការរៀបចំអនុក្រឹត្យ ប្រកាសនានាដែលមានចែងក្នុងច្បាប់ស្តីពី សុខភាពសត្វនិងផលិតកម្មសត្វ និងបញ្ចប់ការរៀបចំឯកសារគោលនយោបាយ និងផែនការយុទ្ធសាស្រ្តស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងរៀបចំកសាងគោលនយោបាយស្តីពីការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា
- ពង្រឹងសមត្ថភាពមន្រ្តីរាជការផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីបង្កើនប្រសិទ្ធភាពការងារសម្រាប់ជំរុញការអភិវឌ្ឍន៍ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ ផ្តល់សេវាកម្មគាំទ្រលើផ្នែកចិញ្ចឹមសត្វគ្រប់ប្រភេទ ឲ្យមានការរីកចម្រើនទាំងបរិមាណនិងគុណភាព តាមរយៈការផ្តល់បច្ចេកទេសសមស្របដូចជាការកែលំអពូជ ចំណី ការចាក់ថ្នាំ ការពារ និងជីវសុវត្ថិភាព
- ជំរុញការចិញ្ចឹមសត្វតាមគ្រប់រូបភាព ដើម្បីទទួលបាននូវផលិតភាពខ្ពស់ មានគុណភាព និងសុវត្ថិភាព ជំរុញនិងលើកទឹកចិត្តការវិនិយោគផលិតចំណីសត្វ និងពង្រឹងការត្រួតពិនិត្យគុណភាព សុវត្ថិភាពចំណីសត្វនិងបសុឱសថ
- ធ្វើការកែទម្លាប់កសិករពីការចិញ្ចឹមសត្វលែង មកជាការចិញ្ចឹមសត្វដាក់ទ្រុង និងពីការចិញ្ចឹមសម្រាប់ការហូបចុកប្រចាំថ្ងៃមកជាការចិញ្ចឹមបែបពាណិជ្ជកម្ម
- ជំរុញបន្ថែមទៀតលើការគ្រប់គ្រងកាកសំណល់សត្វ និងសាងសង់ឡជីវឧស្ម័ន
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ សំដៅទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ និងជំងឺស្វាណូស តាមរយៈការអនុវត្តវិធានបសុពេទ្យរួមមាន÷ ការចាក់ថ្នាំការពារសត្វ ការព្យាបាលសត្វ ការគ្រប់គ្រងជីវសុវត្ថិភាព ការធ្វើអនាម័យ និងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វចេញ ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ តាមរយៈការបណ្តុះបណ្តាល និងបំពាក់បំប៉នបន្ថែម និងខិតខំធ្វើយ៉ាងណាឱ្យមាននិរន្តរភាព
- ចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វ និងភ្នាក់ងារសុខភាពសត្វភូមិ
- ពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងការធ្វើអាជីវកម្មពិឃាតសត្វ

– បង្កើនការងារស្រាវជ្រាវ អង្កេតតាមដាន ឃ្លាំមើលលើសុខភាពសត្វ និងជំងឺឆ្លងសត្វដើម្បីទប់ស្កាត់ការរាលដាលជំងឺឆ្លងសត្វ ពង្រឹងសមត្ថភាពក្នុងការធ្វើរោគវិនិច្ឆ័យជំងឺឆ្លងសត្វ និងជំងឺស្វូណូស ការវិភាគកាកសំណល់ បសុឱសថ ក្នុងសាច់ និងផលិតផលសត្វ

– រៀបចំចងក្រង បោះពុម្ពឯកសារបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ដើម្បីជំរុញនិងបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វ

– ជំរុញការអនុវត្តថវិកាតាមកម្មវិធី និងសកម្មភាពគម្រោងនានាពាក់ព័ន្ធនឹងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ

– ជំរុញការលើកទឹកចិត្តដល់ផ្នែកឯកជននិងអ្នកវិនិយោគលើវិស័យចិញ្ចឹមសត្វ និងសេវាកម្មផ្នែកសុខភាពសត្វ និងជួយស្វែងរកទីផ្សារសត្វឲ្យកសិករចិញ្ចឹមសត្វដោយយកចិត្តទុកដាក់បំផុត

– បន្តនិងធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យផលិតកម្មនិងបសុព្យាបាល ជាមួយបណ្តាប្រទេសជាមិត្ត ដៃគូរអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ពន្ធ័ និងកិច្ចសហការ ជាមួយផ្នែកឯកជន។

## ៤ ផែនការផ្នែកជលផល

### ក. សូចនាករទិសដៅ

– ការប្រមូលផលនេសាទទឹកសាបទូទាំងប្រទេស នឹងត្រូវរក្សាឱ្យបានយ៉ាងតិច៤៩៤ពាន់តោន នៅឆ្នាំ២០១៦ ដោយផ្អែកលើកំណើនប្រមាណ១,៣% ធៀបនឹងឆ្នាំមុន

– ការធ្វើផលិតកម្មនេសាទសមុទ្រទូទាំងប្រទេស នឹងត្រូវរក្សាឱ្យបាន១១០ពាន់តោន នៅឆ្នាំ២០១៦

– ជំរុញការធ្វើផលិតកម្មវារីវប្បកម្មឱ្យបាន១៧២ពាន់តោន (កំណើន២០%ធៀបនឹងឆ្នាំមុន) និងផលិតកូនត្រីពូជឱ្យបាន១៨០លានកូន

– ដាំព្រៃលិចទឹកនិងព្រៃកោងកាងឱ្យបាន១០០ហ.តក្នុងឆ្នាំ២០១៦

– សហគមន៍នេសាទចំនួន១០០ក្នុង២០១៦ នឹងត្រូវបានពង្រឹងសមត្ថភាពគ្រប់គ្រងនិងប្រតិបត្តិប្រសើរជាងមុន។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

– ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធ តាមរយៈការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី មធ្យម និងវែងទាំងក្នុងនិងក្រៅប្រទេស

– បន្តជំរុញការងារត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសជលផល

– បន្តរៀបចំបោះបង្គោលបេតុង សាងសង់ស្លាក់ការល្បាតនៅកន្លែងអភិរក្សជលផល និងក្នុងដែននេសាទទឹកសាប

– បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីជំរុញការចូលរួមរបស់សហគមន៍នេសាទ ក្នុងការគ្រប់គ្រងជលផលបន្ថែមទៀត

– បន្តបង្កើតនិងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

– បន្តរៀបចំទិវាមច្ឆជាតិ១កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផល

– បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីជំរុញការងារអភិវឌ្ឍវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល

– បន្តផលិតឯកសារបច្ចេកទេសជលផលដើម្បីផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ

– ពង្រីកសកម្មភាពផ្សព្វផ្សាយវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល

– បង្កើនការយល់ដឹងនិងសមត្ថភាពរបស់អ្នកកែច្នៃឱ្យកាន់តែល្អប្រសើរឡើង លើការអនុវត្តការធ្វើអនាម័យល្អ និង

ការអនុវត្តការផលិតល្អ ក្នុងខ្សែសង្វាក់ផលិតកម្មកែច្នៃជលផល។

## ៥. ផែនការផ្នែកព្រៃឈើ

### ក. សូចនាករទិសដៅ

- ការដាំដើមឈើឡើងវិញ នឹងត្រូវសម្រេចឱ្យបានប្រមាណ២៤.៥០០ហ.ត ដោយត្រូវយកចិត្តទុកដាក់លើការជំរុញការដាំដុះពីវិស័យឯកជននិងគ្រួសារ និងត្រូវបណ្តុះកូនឈើឱ្យបាន១០លានដើមក្នុងឆ្នាំ២០១៦
- ចំនួនសហគមន៍ព្រៃឈើនៅ២០១៦ នឹងកើនដល់៥៥០សហគមន៍
- បង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបោះឱ្យបានយ៉ាងតិចចំនួន៥០០បង្គោល។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បន្តពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ចល្អ ដោយធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទបញ្ញាលេខ០១ ០២ និងសេចក្តីជូនដំណឹងនានា
- បន្តជំរុញបង្កើនសហគមន៍ព្រៃឈើឱ្យបានកាន់តែច្រើន ផ្តល់ការលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋាន រួមទាំងវិស័យឯកជនចូលរួមដាំដុះដើមឈើបង្កើតជាចម្ការព្រៃដាំ
- បន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ
- បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញ ឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្ម និងថែរក្សាការពារចម្ការព្រៃពូជ និងប្រមូលគ្រាប់ពូជឈើ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា ជាពិសេសព្រះរាជអាជ្ញាស្ថាប័នតុលាការក្នុងការគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់
- បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងតំបន់ និងជាមួយប្រទេសជិតខាង ដើម្បីចូលរួមអនុវត្តកម្មវិធីថ្នាក់តំបន់ និងអន្តរជាតិ។

# VI- សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលពេញមួយឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា យើងអាចវាយតម្លៃជារួមថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ ពិសេសគ្រោះរាំងស្ងួត តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការរីកចម្រើនគួរឱ្យកត់សម្គាល់។

ជារួមផលិតកម្មដំណាំ ពិសេសដំណាំស្រូវតាមការកត់សម្គាល់ឃើញថា បានទទួលលទ្ធផលល្អប្រសើរ ហើយអាចសល់សៀង (ជាអង្ករ) សរុបចំនួនប្រមាណ៣លានតោន (ឬ៤,៦៥លានតោនស្រូវ) នៅឆ្នាំ២០១៥ ដែលនេះជាជោគជ័យមួយសម្រាប់កសិកម្មកម្ពុជា។ ជាការកត់សម្គាល់ កត្តាកើនឡើងនៃទិន្នផលផលិតកម្មកសិកម្មកម្ពុជា ពិសេសផលិតកម្មស្រូវពីមួយឆ្នាំទៅមួយឆ្នាំ មានការវិវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺ (១). ការពង្រីកផ្ទៃដីដាំដុះ ដែលរួមទាំងការធ្វើបង្កើនរដូវនិងប្រពលវប្បកម្ម (២). សមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពូជថ្មី បច្ចេកទេសដាំដុះសមស្រប ការថែទាំប្រកបដោយប្រសិទ្ធភាព ពិសេសការកែប្រែទម្លាប់របស់ប្រជាកសិករ។ បន្ថែមពីនេះ បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករកាលពីឆ្នាំ២០១០ ចំពោះគោលដៅទីមួយ យើងសម្រេចបានជាង៨៧,៥% ក្នុងនោះ បរិមាណស្រូវដែលលើសតម្រូវការក្នុងស្រុកសម្រេចបានទាំងស្រុង គឺកើនឡើងពី៣,៥លានតោននៅឆ្នាំ២០០៩មកដល់ប្រមាណ៤,៦៥លានតោននៅឆ្នាំ២០១៥ ចំណែកឯការនាំចេញអង្ករគឺយើងសម្រេចបានប្រមាណជាងពាក់កណ្ដាល គឺជាង៥៣ម៉ឺនតោននៃគោលដៅ១លានតោន។ ចំពោះគោលដៅទីពីរយើងសម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់ ដោយកម្ពុជាបាននាំអង្ករទៅកាន់ទីផ្សារនានាលើពិភពលោកជាង៦០ប្រទេស ជាមួយគ្នានេះ អង្ករពូជស្រូវផ្ការំដួលរបស់កម្ពុជាត្រូវបានជាប់ជាចំណាត់ថ្នាក់អង្ករឆ្ងាញ់បំផុតលើពិភពលោករយៈពេលបីឆ្នាំ ជាបន្តបន្ទាប់គឺក្នុងឆ្នាំ២០១២ ២០១៣ និង២០១៤។

ដំណាំឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ ជាក់ស្តែងផ្ទៃដីកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារ មានការវិវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ផលិតកម្មសត្វគ្រប់ប្រភេទ ទាំងការចិញ្ចឹមជាលក្ខណៈគ្រួសារនិងកសិដ្ឋាន បានកើនឡើងគួរឱ្យកត់សម្គាល់ ពោលគឺមានកំណើនប្រមាណជាង៥% ដោយការកើនឡើងខ្លាំងនៃការចិញ្ចឹមសត្វស្លាប (៩%)។ ការកើនឡើងនៃផលិតកម្មសត្វនេះគឺអាស្រ័យដោយការបង្កើនការងារផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វដល់ប្រជាកសិករបានទូលាយជាងមុន។ ទោះជាយ៉ាងនេះក្ដី ការចិញ្ចឹមគោក្របី កំពុងត្រូវបានធ្លាក់ចុះ ដោយកត្តាសត្យានុម័តមួយចំនួន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ក្នុងផ្នែកនេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវបង្កើនការលើកកម្ពស់ការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មបន្ថែមទៀត ក្នុងទិសដៅបង្កើនបរិមាណនិងគុណភាពផលិតផលកសិកម្ម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា បច្ចេកទេស និងនុវានុវត្តថ្មីៗ ក្នុងបរិបទបម្រែបម្រួលអាកាសធាតុ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ។

ការគ្រប់គ្រងធនធានព្រៃឈើនិងជលផល ពិសេសកំណែទម្រង់ក្នុងផ្នែកទាំងពីរនេះ កំពុងស្ថិតនៅតែជាប្រធានបទមួយសំខាន់ ហើយដែលត្រូវតែខិតខំបង្កើនសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ក្នុងការទប់ស្កាត់និងបង្រ្កាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ត្រូវបន្តពង្រឹងកិច្ចសហការជាមួយគណៈកម្មការឯកភាពរាជធានីខេត្ត តាមស្មារតីក្នុងអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ លើសពីនេះទៀត ការបន្តចូលរួមសហការជាមួយគណៈកម្មការជាតិ ក៏ជាការងារសំខាន់មួយទៀត ដើម្បីទប់ស្កាត់និងបង្រ្កាបបទល្មើសព្រៃឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅភាគពាយ័ព្យ។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់ រួមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលងបានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

លើសពីនេះទៅទៀត ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ គ្រប់ផ្នែកទាំងអស់ក៏មិនដែលមើលរំលងអំពីការចូលរួមយ៉ាងសកម្មរបស់កិច្ចការយេនឌ័រផងដែរ។ ទន្ទឹមនឹងនេះ អង្គភាពជំនាញនីមួយៗជាសេនាធិការនឹងបន្តអនុវត្តតាមទិសដៅ និងផែនការយុទ្ធសាស្ត្រ ដែលបានដាក់ចុះសម្រាប់ឆ្នាំ២០១៦-២០១៧ ដោយស្មារតីទទួលខុសត្រូវខ្ពស់។ តែទោះយ៉ាងណាក្តី ផ្លូវនៅវែងឆ្ងាយទៀត ដើម្បីសម្រេចបានគោលដៅ និងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមួយតាមលក្ខណៈវិទ្យាសាស្ត្រទំនើប និងមានប្រសិទ្ធភាពខ្ពស់ ជាពិសេសការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជាក្នុងបរិបទនៃសកលភាវូបនីយកម្ម ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិតដ៏ត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ុក រ៉ាប៊ុន

# ឧបសម្ព័ន្ធ

## ផែនការផលិតកម្មដំណាំស្រូវឆ្នាំ២០១៦-២០១៧

ឧបសម្ព័ន្ធទី ១

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥-២០១៦ | | | ទិសដៅសម្រាប់ឆ្នាំ២០១៦-២០១៧ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុបម្រែបម្រួល |
| **១** | **ផ្ទៃដីដាំដុះស្រូវប្រចាំឆ្នាំ** | **ហ.ត** | **2,984,455** | **3,051,412** | **102.24** | **2,903,801** | ដោយសារលក្ខខណ្ឌធម្មជាតិ (ជំនន់និងរាំងស្ងួត) មិនអាចព្យាករណ៍ជាមុនបាន។ ដូចនេះផែនការដាំដុះស្រូវរដូវវស្សានឹងអាចសម្រេចបាន ២,៤៧ លានហិកតានៅឆ្នាំ២០១៦។ |
| | ផ្ទៃដីដាំដុះស្រូវវស្សា | ហ.ត | 2,567,130 | 2,561,957 | 99.80 | 2,474,446 | |
| | ផ្ទៃដីដាំដុះស្រូវប្រាំង | ហ.ត | 417,325 | 489,455 | 117.28 | 429,355 | |
| **២** | **ទិន្នផលស្រូវ** | **តោន/ហ.ត** | **3.090** | **3.085** | **99.84** | **3.090** | |
| | ទិន្នផលស្រូវវស្សា | តោន/ហត | 2.900 | 2.827 | 97.48 | 2.855 | |
| | ទិន្នផលស្រូវប្រាំង | តោន/ហត | 4.448 | 4.422 | 99.42 | 4.444 | |
| **៣** | **បរិមាណផលប្រចាំឆ្នាំ** | **តោន** | **9,220,699** | **9,335,284** | 101.24 | **8,973,312** | |
| | បរិមាណផលស្រូវវស្សា | តោន | 7,386,677 | 7,170,684 | 97.08 | 7,065,211 | |
| | បរិមាណផលស្រូវប្រាំង | តោន | 1,834,022 | 2,164,600 | 118.02 | 1,908,101 | |

# ផែនការផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្ម២០១៦-២០១៧

ឧបសម្ព័ន្ធទី ២

| ល.រ | ប្រភេទដំណាំ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥-១៦ | | | ទិសដៅសម្រាប់ផែនការឆ្នាំ២០១៦-១៧ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ ២០១៥-១៦ | សម្រេចបាន ២០១៥-១៦ | % ធៀបផែនការ | ផែនការ ២០១៦-១៧ | បញ្ជាក់បម្រែបម្រួល |
| ១ | ពោត | ហ.ត | 146,387 | 112,574 | 76.90 | 114,825 | កំណើននឹងសម្រេចបានកើនឡើង២% ក្នុងលក្ខខណ្ឌធម្មជាតិអំណោយផល |
| ២ | ដំឡូងមី | ហ.ត | 531,417 | 573,624 | 107.94 | 585,096 | |
| ៣ | ដំឡូងជ្វា | ហ.ត | 6,033 | 5,757 | 95.42 | 5,872 | |
| ៤ | បន្លែ | ហ.ត | 52,656 | 47,373 | 89.97 | 48,320 | |
| ៥ | សណ្ដែកបាយ | ហ.ត | 54,360 | 57,172 | 105.17 | 58,315 | |
| | **សរុប** | | **790,854** | **796,500** | **100.71** | **812,430** | |
| ១ | សណ្ដែកដី | ហ.ត | 18,174 | 15,519 | 85.39 | 15,829 | កំណើននឹងសម្រេចបានកើនឡើង២% ក្នុងលក្ខខណ្ឌធម្មជាតិអំណោយផល |
| ២ | សណ្ដែកសៀង | ហ.ត | 73,931 | 66,824 | 90.39 | 68,160 | |
| ៣ | ល្ង | ហ.ត | 28,689 | 26,544 | 92.52 | 27,075 | |
| ៤ | អំពៅ | ហ.ត | 49,324 | 19,514 | 39.56 | 19,904 | |
| ៥ | ក្រចៅ | ហ.ត | 196 | 135 | 68.93 | 138 | |
| ៦ | ថ្នាំជក់ | ហ.ត | 10,942 | 6,545 | 59.82 | 6,676 | |
| | **សរុប** | ហ.ត | **181,255** | **135,081** | **74.53** | **137,783** | |
| | **សរុបរួម** | | **972,109** | **931,581** | **95.83** | **950,213** | |

# ផែនការផលិតកម្មដំណាំកៅស៊ូឆ្នាំ២០១៦

ឧបសម្ព័ន្ធទី ៣

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥ | | | ទិសដៅសម្រាប់ផែនការឆ្នាំ២០១៦ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ២០១៥ | សម្រេចបាន | ភាគរយ | ផែនការ | បញ្ជាក់ បម្រែបម្រួល |
| I | ផ្ទៃដីដាំដុះកៅស៊ូ | | | | | | |
| ១ | កៅស៊ូកសិឧស្សាហកម្ម□ | ហិកតា | 221,834 | 239,102 | 107.78 | 245,319 | កើនប្រមាណ២,៦%ក្នុងមួយឆ្នាំ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ហិកតា | 143,106 | 149,853 | 104.71 | 153,749 | កើនប្រមាណ២,៦%ក្នុងមួយឆ្នាំ |
| | សរុបរួម | | **364,940** | **388,955** | ***106.58*** | **399,068** | 1.03 |
| II | ផលិតកម្មកៅស៊ូ | | | | | | |
| | ផលិតផលកៅស៊ូ | តោន | **106,480** | **126,860** | ***119.14*** | **148,426** | កើនប្រមាណ១៧%ក្នុងមួយឆ្នាំ |

# ផែនការផលិតកម្មសត្វជាលក្ខណៈគ្រួសារឆ្នាំ២០១៦

ឧបសម្ព័ន្ធទី ៤

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥ | | | ទិសដៅផែនការឆ្នាំ ២០១៦ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | ភាគរយ | ផែនការ | បញ្ជាក់ បម្រែបម្រួល |
| ១ | ការចិញ្ចឹមគោ | ក្បាល | 3,090,526 | 2,903,420 | *93.95* | **2,932,454** | កំណើន១% |
| ២ | ការចិញ្ចឹមក្របី | ក្បាល | 544,568 | 506,165 | *92.95* | **508,696** | កំណើន០,៥% |
| ៣ | ការចិញ្ចឹមជ្រូក | ក្បាល | 2,790,431 | 2,357,839 | *84.50* | **2,404,996** | កំណើន២% |
| ៤ | ការចិញ្ចឹមបក្សី | ក្បាល | 33,162,840 | 26,688,675 | *80.48* | **28,023,109** | កំណើន៥% |
| ៥ | ចាក់វ៉ាក់សាំងគោក្របី | លានក្បាល | 1.69 | 1.53 | *90.51* | **1.61** | កំណើន៥% |
| ៦ | សត្តឃាតដ្ឋានអនុវត្ត GHP | ចំនួន | 50 | 25 | *50.00* | **50** | |

# ផែនការផលិតកម្មជលផលឆ្នាំ២០១៦

ឧបសម្ព័ន្ធទី ៥

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥ | | | ទិសដៅសម្រាប់ឆ្នាំ២០១៦ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុ បម្រែបម្រួល |
| ១ | នេសាទទឹកសាប | តោន | 512,000 | 487,905 | 95.29 | 494,248 | កំណើន ១,៣% ធៀបឆ្នាំ២០១៥ |
| ២ | នេសាទសមុទ្រ | តោន | 110,000 | 120,055 | 109.14 | 110,000 | មិនមានផែនការឱ្យមានកំណើនទេ |
| ៣ | វារីវប្បកម្ម | តោន | 144,000 | 143,141 | 99.40 | 171,769 | កំណើន ២០% ធៀបឆ្នាំ២០១៥ |
| ៤ | សហគមន៍នេសាទត្រូវបានពង្រឹងសមត្ថភាព | សហគមន៍ | 100 | 85 | 85.00 | 100 | |
| ៥ | ការដាំព្រៃលិចទឹកនិងព្រៃកោងកាង | ហ.ត | 100 | 75 | 75.00 | 100 | |

# ផែនការវិស័យព្រៃឈើឆ្នាំ២០១៦

ឧបសម្ព័ន្ធទី ៦

| ល.រ | សូចនាករលទ្ធផល | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥ | | | ទិសដៅអនុវត្តឆ្នាំ២០១៦ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | (%) ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុបម្រែបម្រួល |
| ១ | ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ | លានហ.ត | 1.60 | 1.60 | 100.00 | 1.65 | |
| ២ | ផ្ទៃដីដាំព្រៃឡើងវិញ | ហិកតា | 22,300 | 4,690 | 21.03 | 24,500 | វិស័យឯកជននឹងចូលក្នុងសកម្មភាពនេះ |
| ៣ | បណ្តុះកូនឈើចំនួន១០លានដើម/ឆ្នាំ | លានដើម | 10.00 | 2.00 | 20.00 | 10.00 | ថ្នាលបណ្តុះកូនឈើជាលក្ខណៈគ្រួសារនិងឯកជននឹងកើនឡើង |
| ៤ | ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើន និងពង្រឹងសមត្ថភាព | ចំនួនសហគមន៍ | 520 | 499 | 95.96 | 550 | រៀបចំឱ្យបាន៥១សមគមន៍បន្ថែមទៀតដើម្បីសម្រេចបានតាមផែនការ |
| ៥ | ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ | បង្គោល | 455 | 574 | 126.15 | 500 | ដៃគូអភិវឌ្ឍន៍នឹងមានការចូលរួម |

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០១៥

ឧបសម្ព័ន្ធទី ៧

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្ដាល | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | |
| 01 | បន្ទាយមានជ័យ | 244,000 | 246,522 | 45 | 0.02 | 246,477 | 99.98 | 48 | 54,693 | 36,388 | 132,708 | 48,505 | - | 10,115 | 246,021 | 100.83 |
| 02 | បាត់ដំបង | 295,400 | 290,786 | 1,783 | 0.61 | 289,003 | 99.39 | 416 | 60,937 | 30,322 | 127,998 | 92,732 | 435 | 7,954 | 290,056 | 98.19 |
| 03 | កំពង់ចាម | 87,300 | 87,151 | 20,771 | 23.83 | 66,380 | 76.17 | 1,439 | 22,745 | 5,129 | 33,699 | 29,652 | - | 1,050 | 87,146 | 99.82 |
| 04 | កំពង់ឆ្នាំង | 121,800 | 173,882 | 48,919 | 28.13 | 124,963 | 71.87 | 12,777 | 5,048 | 938 | 90,486 | 26,707 | - | 340 | 122,581 | 100.64 |
| 05 | កំពង់ស្ពឺ | 107,900 | 305,542 | 209,781 | 68.66 | 95,761 | 31.34 | 10,059 | 15,190 | 718 | 67,537 | 28,746 | 1,174 | - | 112,647 | 104.40 |
| 06 | កំពង់ធំ | 213,300 | 215,878 | 53,086 | 24.59 | 162,792 | 75.41 | 3,611 | 28,288 | 6,997 | 106,787 | 62,961 | 3,225 | 12,165 | 213,426 | 100.06 |
| 07 | កំពត | 136,500 | 136,537 | 38,624 | 28.29 | 97,913 | 71.71 | 12,029 | 20,891 | - | 69,949 | 45,697 | - | - | 136,537 | 100.03 |
| 08 | កណ្ដាល | 40,100 | 46,459 | 8,816 | 18.98 | 37,643 | 81.02 | 1,315 | 9,749 | 3,153 | 12,659 | 11,704 | 1,121 | 47 | 35,280 | 87.98 |
| 09 | កោះកុង | 10,400 | 9,183 | 2,280 | 24.83 | 6,903 | 75.17 | 778 | 2,032 | - | 6,161 | 992 | 1,220 | - | 10,405 | 100.05 |
| 10 | ក្រចេះ | 33,000 | 33,235 | 10,025 | 30.16 | 23,210 | 69.84 | 3,345 | 13,142 | 821 | 15,301 | 3,595 | 248 | - | 32,286 | 97.84 |
| 11 | មណ្ឌលគិរី | 23,000 | 23,875 | 273 | 1.14 | 23,602 | 98.86 | 2,835 | 2,750 | - | 11,383 | 5,169 | 3,627 | - | 22,929 | 99.69 |
| 12 | ភ្នំពេញ | 11,300 | 11,156 | 3,686 | 33.04 | 7,470 | 66.96 | 836 | 5,536 | - | 3,612 | 2,005 | - | - | 11,153 | 98.70 |
| 13 | ព្រះវិហារ | 76,600 | 82,558 | 4,066 | 4.93 | 78,492 | 95.07 | 2,888 | 14,489 | - | 41,851 | 24,104 | 2,944 | - | 83,388 | 108.86 |
| 14 | ព្រៃវែង | 272,800 | 269,415 | 13,061 | 4.85 | 256,354 | 95.15 | 24 | 66,580 | 30,000 | 143,440 | 58,141 | - | 154 | 268,315 | 98.36 |
| 15 | ពោធិសាត់ | 111,200 | 111,014 | 6,693 | 6.03 | 104,321 | 93.97 | 3,432 | 44,491 | 380 | 36,009 | 19,759 | 396 | 7,674 | 108,329 | 97.42 |
| 16 | រតនគិរី | 26,100 | 14,486 | 4,966 | 34.28 | 9,520 | 65.72 | 1,241 | 3,901 | - | 5,414 | 5,172 | 11,531 | - | 26,018 | 99.69 |
| 17 | សៀមរាប | 184,200 | 222,180 | 48,370 | 21.77 | 173,810 | 78.23 | 5,804 | 38,425 | - | 93,530 | 41,405 | 5,430 | 7,260 | 186,050 | 101.00 |
| 18 | ព្រះសីហនុ | 16,600 | 16,600 | 4,153 | 25.02 | 12,447 | 74.98 | 373 | 1,484 | - | 10,415 | 4,715 | - | - | 16,614 | 100.08 |
| 19 | ស្ទឹងត្រែង | 27,900 | 25,905 | 6,943 | 26.80 | 18,962 | 73.20 | 2,365 | 13,014 | - | 11,749 | 1,142 | 2,784 | - | 28,689 | 102.83 |
| 20 | ស្វាយរៀង | 167,000 | 168,641 | 7,305 | 4.33 | 161,336 | 95.67 | 280 | 51,409 | 9,936 | 108,014 | 8,523 | - | - | 167,946 | 100.57 |
| 21 | តាកែវ | 199,800 | 415,882 | 50,053 | 12.04 | 365,829 | 87.96 | 1,418 | 79,766 | 33,703 | 107,416 | 10,052 | - | - | 197,234 | 98.72 |
| 22 | ឧត្ដរមានជ័យ | 72,100 | 81,545 | 565 | 0.69 | 80,980 | 99.31 | 296 | 16,664 | - | 40,571 | 12,117 | 2,648 | - | 72,000 | 99.86 |
| 23 | កែប | 3,500 | 3,588 | 1,488 | 41.47 | 2,100 | 58.53 | 470 | 836 | 239 | 2,235 | 517 | - | - | 3,588 | 102.51 |
| 24 | ប៉ៃលិន | 6,230 | 5,003 | | - | 5,003 | 100.00 | 2 | 1,837 | - | 3,107 | 57 | - | - | 5,001 | 80.27 |
| 25 | ត្បូងឃ្មុំ | 79,100 | 78,318 | 3,467 | 4.43 | 74,851 | 95.57 | 2,040 | 11,448 | 1,966 | 30,812 | 36,058 | - | - | 78,318 | 99.01 |
| សរុប | | **2,567,130** | **3,075,341** | **549,219** | **17.86** | **2,526,122** | **82.14** | **70,121** | **585,345** | **160,690** | **1,312,843** | **580,227** | **36,783** | **46,759** | **2,561,957** | **99.80** |
| តួលេខឆ្នាំមុន | | **2,411,207** | **2,980,117** | **715,184** | **24.00** | **2,264,933** | **76.00** | **113,362** | **661,106** | **176,242** | **1,256,259** | **550,580** | **44,088** | **52,539** | **2,564,572** | **106.36** |
| ប្រៀបធៀប | | **155,923** | **95,224** | **-165,965** | **-6.14** | **261,189** | **6.14** | **-43,241** | **-75,761** | **-15,552** | **56,584** | **29,647** | **-7,305** | **-5,780** | **-2,615** | **-6.56** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

ឧបសម្ព័ន្ធទី ៨

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជយ័ | 246,021 | 97,251 | | | **97,251** | 10,799 | | | **10,799** | - | 10,799 |
| 02 | បាត់ដំបង | 290,056 | 64,828 | | | **64,828** | 23,885 | | | **23,885** | 12,952 | 10,933 |
| 03 | កំពង់ចាម | 87,146 | 3,755 | | | **3,755** | - | | | - | - | - |
| 04 | កំពង់ឆ្នាំង | 122,581 | 2,920 | | | **2,920** | 98 | | | **98** | - | 98 |
| 05 | កំពង់ស្ពឺ | 112,647 | 4,039 | | | **4,039** | 327 | | | **327** | 305 | 22 |
| 06 | កំពង់ធំ | 213,426 | 4,390 | | | **4,390** | - | | | - | - | - |
| 07 | កំពត | 136,537 | | | | **-** | | | | - | | - |
| 08 | កណ្តាល | 35,280 | 2,167 | | | **2,167** | - | | | - | - | - |
| 09 | កោះកុង | 10,405 | | 110 | | **110** | | | | - | | - |
| 10 | ក្រចេះ | 32,286 | 477 | | | **477** | 83 | | | **83** | 83 | - |
| 11 | មណ្ឌលគិរី | 22,929 | | | | **-** | | | | - | | - |
| 12 | ភ្នំពេញ | 11,153 | 170 | | | **170** | - | | | - | | - |
| 13 | ព្រះវិហារ | 83,388 | | | | **-** | | | | - | - | - |
| 14 | ព្រៃវែង | 268,315 | 10,879 | | | **10,879** | - | | | - | - | - |
| 15 | ពោធិសាត់ | 108,329 | 24,327 | | | **24,327** | 2,936 | | | **2,936** | 200 | 2,736 |
| 16 | រតនគិរី | 26,018 | | | | **-** | | | | - | | - |
| 17 | សៀមរាប | 186,050 | 830 | | | **830** | 830 | | | **830** | - | 830 |
| 18 | ព្រះសីហនុ | 16,614 | | 730 | | **730** | | | | - | | - |
| 19 | ស្ទឹងត្រែង | 28,689 | | | | **-** | | | | - | | - |
| 20 | ស្វាយរៀង | 167,946 | 10,323 | | | **10,323** | 1,138 | | | **1,138** | 850 | 288 |
| 21 | តាកែវ | 197,234 | 13,638 | | | **13,638** | 1,252 | | | **1,252** | 1,252 | - |
| 22 | ឧត្តរមានជ័យ | 72,000 | 12,027 | | | **12,027** | - | | | - | - | - |
| 23 | កែប | 3,588 | 2 | | | **2** | | | | - | | - |
| 24 | ប៉ៃលិន | 5,001 | 166 | | | **166** | 121 | | | **121** | 45 | 76 |
| 25 | ត្បូងឃ្មុំ | 78,318 | | | | **-** | | | | - | | - |
| សរុប | | **2,561,957** | **252,189** | **840** | **-** | **253,029** | **41,469** | **-** | **-** | **41,469** | **15,687** | **25,782** |
| តួលេខឆ្នាំមុន | | **2,564,572** | **116,129** | **1,654** | **81,083** | **198,866** | **20,289** | **1,551** | **24,100** | **45,940** | **19,344** | **26,596** |
| ប្រៀបធៀប | | **-2,615** | **136,060** | **-814** | **-81,083** | **54,163** | **21,180** | **-1,551** | **-24,100** | **-4,471** | **-3,657** | **-814** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០១៥

ឧបសម្ព័ន្ធទី ៩ក

| ល.រ | រាជធានី-ខេត្ត | ស្រូវស្រាល | | | | ស្រូវកណ្តាល | | | | ស្រូវធ្ងន់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល |
| | | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) |
| 01 | បន្ទាយមានជយ័ | 54,693 | 52,943 | 3.034 | 160,655 | 132,708 | 127,353 | 2.325 | 296,034 | 48,505 | 45,761 | 2.906 | 132,970 |
| 02 | បាត់ដំបង | 60,937 | 58,744 | 3.415 | 200,608 | 127,998 | 122,428 | 2.541 | 311,064 | 92,732 | 89,562 | 3.003 | 268,971 |
| 03 | កំពង់ចាម | 22,745 | 22,745 | 3.406 | 77,462 | 33,699 | 33,699 | 3.256 | 109,708 | 29,652 | 29,652 | 3.054 | 90,566 |
| 04 | កំពង់ឆ្នាំង | 5,048 | 4,960 | 1.995 | 9,895 | 90,486 | 90,486 | 2.709 | 245,140 | 26,707 | 26,697 | 3.431 | 91,590 |
| 05 | កំពង់ស្ពឺ | 15,190 | 15,190 | 3.053 | 46,372 | 67,537 | 67,515 | 3.011 | 203,319 | 28,746 | 28,746 | 2.990 | 85,963 |
| 06 | កំពង់ធំ | 28,288 | 28,288 | 2.693 | 76,190 | 106,787 | 106,787 | 2.577 | 275,218 | 62,961 | 62,961 | 2.425 | 152,682 |
| 07 | កំពត | 20,891 | 20,891 | 3.849 | 80,410 | 69,949 | 69,949 | 3.047 | 213,105 | 45,697 | 45,697 | 2.989 | 136,577 |
| 08 | កណ្តាល | 9,749 | 9,749 | 3.813 | 37,174 | 12,659 | 12,659 | 2.662 | 33,697 | 11,704 | 11,704 | 3.032 | 35,482 |
| 09 | កោះកុង | 2,032 | 2,032 | 2.407 | 4,891 | 6,161 | 6,161 | 2.871 | 17,690 | 992 | 992 | 3.198 | 3,172 |
| 10 | ក្រចេះ | 13,142 | 13,142 | 2.851 | 37,463 | 15,301 | 15,301 | 2.570 | 39,326 | 3,595 | 3,595 | 2.476 | 8,903 |
| 11 | មណ្ឌលគិរី | 2,750 | 2,750 | 2.583 | 7,104 | 11,383 | 11,383 | 2.804 | 31,922 | 5,169 | 5,169 | 2.264 | 11,705 |
| 12 | ភ្នំពេញ | 5,536 | 5,536 | 2.811 | 15,561 | 3,612 | 3,612 | 2.844 | 10,273 | 2,005 | 2,005 | 3.097 | 6,209 |
| 13 | ព្រះវិហារ | 14,489 | 14,489 | 2.599 | 37,654 | 41,851 | 41,851 | 2.854 | 119,443 | 24,104 | 24,104 | 2.680 | 64,590 |
| 14 | ព្រៃវែង | 66,580 | 66,580 | 3.599 | 239,641 | 143,440 | 143,440 | 2.804 | 402,145 | 58,141 | 58,141 | 2.783 | 161,778 |
| 15 | ពោធិសាត់ | 44,491 | 41,755 | 3.227 | 134,747 | 36,009 | 36,009 | 3.002 | 108,109 | 19,759 | 19,759 | 2.724 | 53,821 |
| 16 | រតនគិរី | 3,901 | 3,901 | 1.894 | 7,389 | 5,414 | 5,414 | 2.431 | 13,162 | 5,172 | 5,172 | 2.481 | 12,831 |
| 17 | សៀមរាប | 38,425 | 38,365 | 2.377 | 91,179 | 93,530 | 93,230 | 2.493 | 232,400 | 41,405 | 40,935 | 2.803 | 114,743 |
| 18 | ព្រះសីហនុ | 1,484 | 1,484 | 2.625 | 3,896 | 10,415 | 10,415 | 2.759 | 28,732 | 4,715 | 4,715 | 2.770 | 13,061 |
| 19 | ស្ទឹងត្រែង | 13,014 | 13,014 | 2.541 | 33,064 | 11,749 | 11,749 | 2.628 | 30,880 | 1,142 | 1,142 | 3.590 | 4,100 |
| 20 | ស្វាយរៀង | 51,409 | 51,409 | 3.030 | 155,778 | 108,014 | 107,726 | 2.490 | 268,239 | 8,523 | 8,523 | 2.379 | 20,277 |
| 21 | តាកែវ | 79,766 | 79,766 | 3.403 | 271,428 | 107,416 | 107,416 | 3.186 | 342,268 | 10,052 | 10,052 | 3.348 | 33,655 |
| 22 | ឧត្តរមានជ័យ | 16,664 | 16,664 | 1.954 | 32,561 | 40,571 | 40,571 | 2.278 | 92,408 | 12,117 | 12,117 | 2.230 | 27,025 |
| 23 | កែប | 836 | 836 | 3.449 | 2,883 | 2,235 | 2,235 | 3.123 | 6,979 | 517 | 517 | 3.319 | 1,716 |
| 24 | ប៉ៃលិន | 1,837 | 1,810 | 2.394 | 4,334 | 3,107 | 3,084 | 2.714 | 8,369 | 57 | 31 | 3.290 | 102 |
| 25 | ត្បូងឃ្មុំ | 11,448 | 11,448 | 2.971 | 34,007 | 30,812 | 30,812 | 3.248 | 100,077 | 36,058 | 36,058 | 3.304 | 119,134 |
| សរុប | | **585,345** | **578,491** | **3.116** | **1,802,346** | **1,312,843** | **1,301,285** | **2.720** | **3,539,707** | **580,227** | **573,807** | **2.878** | **1,651,623** |
